# បទសម្ភាសន៍ជាមួយ គុល សែម ភេទប្រុស អាយុ៥១ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ កម្មកររោងចក្រក្រឡឹងដែក ដ-១

មុខងារបច្ចុប្បន្នៈ នៅផ្ទះ(ពិការជើងស្តាំ)

ស្រុកកំណើតនៅភូមិពោធិ៍ទន្លេ ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល

សព្វថ្ងៃរស់នៅភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០២:២៧:៣៤

៥២ទំព័រ

ដានីៈ ខ្ញុំសុំស្គាល់ឈ្មោះពូផង?

សែមៈ ខ្ញុំឈ្មោះ គុល សែម!

ដានីៈ ហើយឈ្មោះពីឪពុកម្តាយក៏ឈ្មោះ គុល សែម អញ្ចឹងដែរ?

សែមៈ បាទ! ម៉ោពីនាយអញ្ចឹងហ្នឹង!

ដានីៈ ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

សែមៈ អាយុ៥០ឆ្នាំ!

ដានីៈ ៥០គត់?

សែមៈ បាទបើគិតទៅវា៥០គត់ហើយព្រោះយើងឆ្នាំ៧០ អាស់៨០វា២០!

ដានីៈ ពូកើតនៅឆ្នាំប៉ុន្មាន?

សែមៈ កើតនៅឆ្នាំ១៩៦០!

ដានីៈ ១៩៦០?

សែមៈ បាទ!

ដានីៈ ពូសព្វថ្ងៃរស់នៅភូមិអីគេពូ?

សែមៈ ភូមិនេះគេហៅភូមិក្បាលស្ពាន!

ដានីៈ ភូមិក្បាលស្ពាន?

សែមៈ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ដានីៈ ខេត្តបន្ទាយមានជ័យ?

សែមៈ បាទ!

ដានីៈ ប្រពន្ធពូឈ្មោះអីដែរ?

សែមៈ ឈ្មោះ អ៊ួច សារ៉េត!

ដានីៈ គាត់អាយុប៉ុន្មានដែរ?

សែមៈ អាយុ៥១!

ដានីៈ សព្វថ្ងៃពូមានកូនចៅប៉ុន្មាននាក់?

សែមៈ មាន៥នាក់!

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សែមៈ ស្រី១ ប្រុស៤!

ដានីៈ ហើយសព្វថ្ងៃពូប្រកបមុខរបរធ្វើអីដែរ?

សែមៈ សព្វថ្ងៃខ្ញុំអ្នកពិការទេ តែប្រពន្ធខ្ញុំធ្វើស្រែធ្វើចំការតិចតួច!

ដានីៈ ហើយពីពិការ?

សែមៈ បាទខ្ញុំពិការជើងខាងស្តាំ!

ដានីៈ ពូពិការដោយសារអីកាលហ្នឹង?

សែមៈ ដោយសារជាន់មីនពេលប្រយុទ្ធគ្នាហ្នឹង!

ដានីៈ ប្រយុទ្ធឆ្នាំកាលហ្នឹង?

សែមៈ ឆ្នាំ១៩៩០!

ដានីៈ ពេលហ្នឹងយើងប្រយុទ្ធយ៉ាងម៉េច?

សែមៈ ពេលហ្នឹងយើង ពីមុនគេហៅថាទាហ៊ានខ្មែរហ្នឹង យួនដកចេញនៅសល់ទាហ៊ានខ្មែរហ្នឹងយើងវ៉ៃគ្នាទៅដើម្បីយកទឹកដីនៅវិញ ដល់យកទឹកដីយើងសម្រុលវ៉ៃទៅ ដល់អញ្ចឹងគេចេញទៅគេដាក់មីនយើងវ៉ៃគ្នាទៅក៏ជាន់មីន គ្រោះថ្នាក់ដោយសារមីន ។

ដានីៈ ជើងខាងណាពូ?

សែមៈ ជើងខាងស្តាំ! ដាច់ជើងនៅឆ្នាំ១៩៩០ ខែកុម្ភះ ។

ដានីៈ ចុះពូស្រុកកំណើតពូនៅណាដែរ នៅភូមិអីដែរ?

សែមៈ ស្រុកកំណើតរបស់ខ្ញុំនៅភូមិពោធិ៍ទន្លេ ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល ។

ដានីៈ ឪពុកម្តាយរបស់ពូឈ្មោះអីដែរ?

សែមៈ ឪពុកឈ្មោះទូច តែខ្ញុំអត់ដឹងជីតារបស់គាត់ទេ!

ដានីៈ ចុះម្ដាយ?

សែមៈ ម្ដាយឈ្មោះ យិន!

ដានីៈ សព្វថ្ងៃគាត់នៅកោះធំហ្នឹងដែរ?

សែមៈ ឪពុកខ្ញុំគាត់ស្លាប់ហើយតែខ្ញុំមិនបានជួបមុខគាត់ទេតាំងពីចេញម៉ោ!

ដានីៈ ស្លាប់នៅឆ្នាំណា?

សែមៈ ឆ្នាំ... កាលពីដើមគេហៅថាក«៥» ហើយគេម៉ោក«៥»ហ្នឹងក៏គាត់ទៅវិញទៅក៏គ្រុនចាញ់ស្លាប់ទៅនៅតែម្ដាយ!

ដានីៈ ពូមានបងប្អូនប៉ុន្មាននាក់?

សែមៈ បងប្អូនបង្កើតមាន៦នាក់! ខ្ញុំបងគេ!

ដានីៈ ទីមួយ?

សែមៈ បាទ!

ដានីៈ ចុះប្អូនៗស្រីប៉ុន្មាននាក់?

សែមៈ ស្រីមួយនាក់!

ដានីៈ ស្រីមួយនាក់ប្រុស៥នាក់?

សែមៈ បាទ!

ដានីៈ អញ្ចឹងពីទីមួយ?

សែមៈ បាទ!

ដានីៈ ពូចេញពីផ្ទះនៅឆ្នាំណា?

សែមៈ ចេញឆ្នាំចុង៧៣!

ដានីៈ ចុង៧៣?

សែមៈ បាទ!

ដានីៈ កាលហ្នឹងពូរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរ?

សែមៈ ខ្ញុំរៀនសាលាលោកថ្នាក់ទី១១ រៀននៅនេះបាន២ឆ្នាំ រៀននៅរាស្ត្ររាជានិយមនោះបាន២ឆ្នាំ ដល់រដ្ឋប្រហារទៅខ្ញុំរៀនបានមួយឆ្នាំទៀត ។

ដានីៈ នៅសាលាធម្មតាហ្នឹងបាន២ឆ្នាំ?

សែមៈ បាទ!

ដានីៈ ដល់ចុងឆ្នាំ៧៣ហ្នឹងពូចេញពីផ្ទះ?

សែមៈ បាទ!

ដានីៈ មូលហេតុអីបានពូចេញពីផ្ទះ?

សែមៈ ចេញម៉ោដូចថាខ្ញុំគេអត់ឲ្យបួសអញ្ចឹងទៅ ខ្ញុំនៅវត្តៗអញ្ចឹងទៅត្រូវការបួស ដល់ចង់បួសគេអត់ឲ្យបួសគេឲ្យម៉ោផ្ទះវិញ ដល់ម៉ោផ្ទះវិញមានបងប្អូន មានតាម្នាក់ដែលគាត់ធ្វើប្រធានកងពលហ្នឹងគាត់សុំឲ្យខ្ញុំទៅនៅជាមួយគាត់ហើយក៏គាត់យកចេញទៅ ។

ដានីៈ តាហ្នឹងគាត់ធ្វើប្រធានកងពល តាហ្នឹងឈ្មោះអីគេ?

សែមៈ ឈ្មោះ សុក កងពលលេខ១២ ។

ដានីៈ ម៉ោសុំពូ?

សែមៈ បាទ! ហើយមានមីងនៅជាមួយតាសុកហ្នឹងគាត់យកខ្ញុំជាក្មួយមានពីរនាក់ ។

ដានីៈ អញ្ចឹងតាសុកនិងមីងហ្នឹងគាត់មកសុំពូហើយនឹងម្នាក់ទៀត?

សែមៈ បាទ! ម្នាក់ទៀតឈ្មោះ វី!

ដានីៈ ឈ្មោះ វី?

សែមៈ បាទ! ឥលូវមិនទាន់បានជួបមុខគ្នាផង ជួបតែសម្លេងតាំងពីហ្នឹងម៉ោរហូតម៉ោមិនដែលបានជួបមុខគ្នានៅឡើយទេ ហើយមានតែពីរនាក់ហ្នឹងឯង ជីដូនមួយ ។

ដានីៈ កាលហ្នឹងស្របាលៗទេពូ?

សែមៈ បាទ! ស្របាលៗគ្នា! ចេញថ្ងៃជាមួយគ្នា ភូមិជាមួយគ្នា ។

ដានីៈ ជីដូនមួយនឹងគ្នា?

សែមៈ បាទជីដូនមួយ!

ដានីៈ ចេញទៅៗធ្វើអីគេពូ?

សែមៈ មកនៅក្នុងកុមារមន្ទីរកងនារសា ធ្វើនារសាមន្ទីរកងពលលេខ១២ ។

ដានីៈ ធ្វើនារសា! កាលហ្នឹងពូអាយុប៉ុន្មាន?

សែមៈ អាយុ១៤ឆ្នាំ!

ដានីៈ មន្ទីរកងពលនៅណាកាលហ្នឹង?

សែមៈ មន្ទីរកងពលលេខ១២នៅខាងកើតអាស៊ីស្រុកហ្នឹង! ដូចថាមិនកោះអន្ទុងចិនបេះ វត្តកោះអន្ទុងនៅចំខាងកើតហ្នឹងឯង!

ដានីៈ បាទ!

សែមៈ អាហ្នឹងគេហៅស្អីទេខ្ញុំវាភ្លេចដែរ!

ដានី៖ នៅហ្នឹងគេឲ្យធ្វើអីខ្លះទៅ?

សែម៖ គេឲ្យរត់សំបុត្រកងពលមួយទៅកងពលមួយ ពីកន្លែងមួយទៅកន្លែងមួយ ដល់ដកពីកន្លែងហ្នឹងទៅគេឲ្យមកនៅជិតឈូងលាប ។

ដានី៖ ឈូងលាប?

សែម៖ បាទ! ដល់ម៉ោឈូងលាបហ្នឹងខ្ញុំដឹកគ្រាប់ ចាំមើលខ្ញុំនៅមន្ទីរសំរេាង នៅមន្ទីរសំរេាងហ្នឹងពេលហ្នឹងគាត់ចាត់តាំងឲ្យខ្ញុំហ្នឹងម៉ូតូមួយគ្រឿងដើម្បីទៅយកគ្រាប់ពីកន្លែងគាចាន់ហ្នឹង ខ្ញុំទៅយកគ្រាប់ពីហ្នឹងម៉ោគ្រាប់កៃច្នៃហ្នឹងក៏ដឹកយកម៉ោ!

ដានី៖ ដឹកតាមរយៈអីដែរ?

សែម៖ ដឹកតាមម៉ូតូ! ពេលនោះនៅក្រោមគ្រាប់ផ្លោងដែលគេទម្លាក់ គេបាញ់ពីទួលក្រសាំងទៅ ។

ដានី៖ ពីចេះជិះម៉ូតូតាំងពីពេលណាម៉ោ?

សែម៖ ចេះជិះយូហើយតាំងពីអាយុ១៨ឆ្នាំ!

ដានី៖ យូហើយអញ្ចឹង?

សែម៖ បាទ!

ដានី៖ កាលហ្នឹងមួយជួរហ្នឹងមានតែកងពល១២មួយទេ?

សែម៖ បាទ! មានតែកងពល១២មួយទេ ក្រោយម៉ោទៀតខ្ញុំទៅកោះអាការទៅវៃអាម៉ារីន ប្អូនមានបានឃើញអាម៉ារីនទេ គេដាក់អន្ទាក់អាម៉ារីនហ្នឹង?

ដានី៖ បាទ! ខ្ញុំធ្លាប់

សែម៖ ឃើញអាម៉ារីនលិចនៅកោះតាឈឹងទេ?

ដានី៖ អត់បានឃើញតែខ្ញុំធ្លាប់ជួប...

សែម៖ ឃើញឯកសារទេ?

ដានី៖ ធ្លាប់ជួបគ្រូៗគាត់និយាយគាត់ទៅស្ទាក់អាម៉ារីនដែរ!

សែម៖ ដូច្នេះការតស៊ូនោះវានៅក្មេងមែនក៏ប៉ុន្តែវានៅប្រឡូកចលនាជាមួយក្នុងកុមារឈានមុខក្លាហានមួយ ជំនាន់នោះគេហៅថាកុមារក្លាហាន ។

ដានី៖ អញ្ចឹងបន្ទាប់ពីធ្វើជានារសារនៅមន្ទីរកងពលពូត្រូវបានគេផ្លាស់ឲ្យទៅនៅខាងវៃម៉ារីនវិញ?

សែម៖ ខ្ញុំមិនមែនជាអ្នកវៃទេ ខ្ញុំជាកុមារនៅក្នុងមន្ទីរព្រោះកងពល បើប្រធានកងពលគាត់ដកអាហ្នឹងទិសខាងលើហ្នឹងឲ្យទៅកាត់ ដូចថាផ្តាច់បំពង់ក ផ្តាច់បំពង់កតាំងពីប្រេង តាំងពីស្បៀងតាំងពីអី

ទៅកន្លែងនោះឯគឺផ្តាច់បានគឺយើងវ៉ៃភ្នំពេញបានហើយ អាហ្នឹងទិសដៅអញ្ចឹងហើយ គេថាជាប់ជាមួយកងពលទីមួយរបស់អ្នកកាន់អន្ទាក់ព្រៃ ។

ដានី: ហ្នឹងខាងបូព៌?

សែម: បាទ! ខាងបូព៌ា ដល់ខាងនេះទៅខាងវន វើត!

ដានី: គាត់នៅខាង ខាងវន វើត?

សែម: គាត់នៅខាងភូមិភាគពិសេស គាត់នៅក្តាប់រួមនៅហ្នឹង ប្រធានលើកងពលទៀត ។

ដានី: តើគាត់នៅមុំណា?

សែម: ទិសដៅរបស់គាត់នៅច្រើនកន្លែង នៅតាយោតាសាទក៏នៅ នៅព្រែកអាសីក៏នៅ តែគាត់នៅខេត្តកណ្តាល នៅខាងបឹងណា៎!

ដានី: បាទ! នៅបន្ទាយធំ?

សែម: បាទ! តែគាត់អត់ច្បាស់លាស់ទេ នៅកន្លែងណាក៏អត់ច្បាស់លាស់ព្រោះគាត់នៅចល័ត ម្តងនៅកន្លែងនេះ ម្តងនៅកន្លែងនោះ ហើយខ្ញុំទៅជាមួយគាត់កាលទៅវ៉ៃអ្នកលឿងហ្នឹងខ្ញុំក៏ទៅជាមួយគាត់តែខ្ញុំនៅត្រឹមព្រែកតាលាប់ទេ!

ដានី: ទៅជាមួយវន វើត ដែរ?

សែម: បាទទៅជាមួយ!

ដានី: ចុះពូស្គាល់វន វើត ដែរ?

សែម: ខ្ញុំនៅជាមួយគាត់!

ដានី: ធ្វើនារសាឲ្យគាត់?

សែម: ជាកុមារនារសា!

ដានី: ជាកុមារនារសា អញ្ចឹងពូចេញពីកងពល១២ហើយអញ្ចឹង?

សែម: ពេលនោះគាត់ប្រើខ្ញុំៗនៅក្នុងកម្រិតកុមារក្លាហានមួយដែលដូចថាយកសំបុត្រទៅណាក៏បានសម្រេច ។

ដានី: បាទ!

សែម: តែនៅក្នុងកងពល១២ទេ!

ដានី: បាទ!

សែម: តែគាត់នៅជាមួយយើង ដូចថាបន្តិចគាត់មកនៅជាមួយយើងចឹងទៅ បន្តិចគាត់ចល័តទៅនោះចឹងទៅ!

ដានី៖ អ៊ំ!

សែម៖ ដល់បែកភ្នំពេញហើយបានខ្ញុំនៅជាមួយគាត់!

ដានី៖ បាទ! កាលហ្នឹងកងពល១២មានតាសុក តាណាត?

សែម៖ បាទមានតាសុក តាណាត!

ដានី៖ ចុះកាលហ្នឹងពូស្គាល់តាណាតច្បាស់ទេ?

សែម៖ មិនស្គាល់ម៉េចបើខ្ញុំនៅជាមួយគាត់ហើយ! តាណាត តាពីន!

ដានី៖ តាពីន?

សែម៖ តាណាត តាពីន តាសុក!

អ្នកភូមិ៖ ចុះគាត់ស្គាល់ដែរ?

សែម៖ និយាយមិនស្គាល់ម៉េចបើអ្នកស្រុកហ្នឹងដែរ ប៉ុន្តែគាត់ស្គាល់តាមឯកសារទេ គាត់មិនអាចស្គាល់ទេព្រោះគាត់មេគេ ។

អ្នកភូមិ៖ គាត់អ្នកនេះដែរ?

ដានី៖ ខ្ញុំអ្នកកំពង់ចាមតែខ្ញុំធ្វើការច្រើនកន្លែង ។ អញ្ចឹងពេលពូនៅខាងកងពល១២ហ្នឹងរហូតដល់បែក?

សែម៖ រហូតដល់បែកឆ្នាំ៧៥ ថ្ងៃ១៧មេសា ឆ្នាំ៧៥ ក្រោយម៉ោបានលោកតាវន វើតហ្នឹងគាត់សុំខ្ញុំកុមារដែលគាត់ធ្លាប់ប្រើបានសម្រេចហ្នឹងគាត់យកមកនៅជាមួយ គាត់រៀបចំខ្ញុំហ្នឹងប្រុងឲ្យទៅចិន តែដោយក្រោយម៉ោហ្នឹងមិនដឹងជាយ៉ាងម៉េចទេបានឲ្យខ្ញុំហ្នឹងមកនៅរោងចក្រវិញ ។

ដានី៖ គាត់ប្រាប់ថាបំរុងឲ្យពូទៅចិន?

សែម៖ បាទ! កុមារ១០នាក់បំរុងរៀបចំឲ្យទៅចិនប៉ុន្តែក្រោយម៉ោដឹងម៉េចគាត់ឲ្យខ្ញុំទៅនៅរោងចក្របានជាខ្ញុំនៅរោងរហូតដល់ចុងឆ្នាំ១៩៧៥ ។

ដានី៖ អញ្ចឹងកាលពី៧៥ហ្នឹងនៅជាមួយគាត់?

សែម៖ នៅជាមួយគាត់ នៅជាមួយគាត់ដែលបែកភ្នំពេញហ្នឹងខ្ញុំនៅជាមួយគាត់មួយរយៈ ។

ដានី៖ នៅកន្លែងណាកាលហ្នឹង?

សែម៖ ខ្ញុំនៅផ្ទះឡុង វ៉េត!

ដានី៖ អញ្ចឹងវន វ៉េតគាត់នៅផ្ទះហ្នឹងដែរ?

សែម៖ នៅផ្ទះហ្នឹងដែរ!

ដានី៖ មុំណាផ្ទះឡុង វ៉េត កាលហ្នឹង?

សែមៈ ផ្ទះឡុង រ៉េតនៅជិតវិមានឯករាជ្យផ្លូវធំហ្នឹងណា៎ ចេញពីវិមានឯករាជ្យហ្នឹងម៉ោ ខ្ញុំវាអត់សូវចាំដែរទេ ក៏ប៉ុន្តែភ្នំពេញរាល់ថ្ងៃខ្ញុំអត់ដែលបានទៅចំចន្លោះហ្នឹង! អាផ្លូវនរោត្តមហ្នឹងណា៎ បើចេញពីនេះទៅវានៅខាងឆ្វេងដៃ បើចេញពីវិមានឯករាជ្យទៅវានៅខាងស្តាំដៃ ផ្ទះហ្នឹងឥលូវខ្ញុំអត់ដឹងអ្នកណានៅទេ!

ដានីៈ ផ្ទះធំទេកាលហ្នឹង?

សែមៈ ផ្ទះវីឡា!

ដានីៈ ពូនៅប៉ុន្មាននាក់កាលហ្នឹង?

សែមៈ ពេលនោះខ្ញុំនៅចំនួនគ្នាកុមារ១០នាក់ហើយនឹងបង១ប៉ុន្មាននាក់ទៀត ។

ដានីៈ កុមារ១០ហ្នឹងម៉ោពីកងពលទាំងអស់?

សែមៈ បាទម៉ោពីកងពល! តែនៅជាមួយគាត់ដែលថាឲ្យទៅណាម៉ោណានោះស្រេចលើគាត់ ដល់ពេលក្រោយម៉ោគាត់យកកុមារ៨នាក់យកមកចែកចាយឲ្យនៅតាមរោងចក្រ គាត់បានណែនាំខ្ញុំថាក្មួយៗឯងធ្វើការរោងចក្រទៅអនាគតក្មួយឯងនឹងជួយកសាងប្រទេសបានចំរើនលូតលាស់មហាអស្ចារ្យដើម្បីឲ្យយើងឆាប់បានសហករណ៍យើងហ្នឹងចំរើនលូតលាស់ ។

ដានីៈ ឈ្មោះ វី ដែលនៅជាមួយពូហ្នឹងមកនៅផ្ទះជាមួយឡុង សារ៉េត ដែរ?

សែមៈ អត់នៅទេ! គាត់នៅកងពលគាត់អត់មានបានមកនៅជាមួយខ្ញុំទេ!

ដានីៈ អត់បានមកនៅជាមួយគ្នាទេ?

សែមៈ គាត់នៅជាមួយតាពីន!

ដានីៈ នៅជាមួយតាពីន?

សែមៈ បាទ! គាត់នៅជាមួយតាពីនដូចថាគាត់ទៅជាមួយពួកជាយដែន! ហើយពេលជ័យជំនះហ្នឹងអត់មានសេចក្តីសុខទេ ប្រទេសកម្ពុជាយើងអត់មានសេចក្តីសុខទេ!

ដានីៈ បាទ!

សែមៈ មានការឈ្លានពាន មានការវ៉ៃគ្នាដោយសារព្រំដែន ស្ងាត់តែតាមភ្នំពេញនឹងតាមជាយដែនខាងលិចទេដែលស្ងាត់ ខាងកើតអត់ស្ងាត់ទេ!

ដានីៈ ចុះពេលដែលបែកឆ្នាំ៧៥ ទៅកងពល១២ហ្នឹងតាណាគ តាសុកហ្នឹងគាត់ទៅណា?

សែមៈ ខ្ញុំលែងដឹងហើយពេលនោះតាពីនបើតាមខ្ញុំដឹង តាណាគមិនដឹងទៅចិនឬក៏ទៅណាទេតែគាត់ទៅការប្រពន្ធ ពេលឆ្នាំ៧៥ហ្នឹងគាត់ទៅការប្រពន្ធព្រោះពេលមុនគាត់អត់ដែលមានប្រពន្ធទេគាត់នៅកម្លោះ ។

ដានី៖ អ៊ំ!

សែម៖ គាត់និស្សិតណាំ!

ដានី៖ បាទ!

សែម៖ ដល់ពេលចុឹងកាលដែលខ្ញុំនៅជាមួយហ្នឹងគាត់អត់ទាន់មានប្រពន្ធទេ គ្រាន់តែខ្ញុំចេញមោគាត់មានប្រពន្ធអង្គការរៀបការប្រពន្ធឲ្យ ។

ដានី៖ បាទ!

សែម៖ ហើយក្រោយមោទៀតខ្ញុំក៏មកនៅជាមួយលោកតា វ៉ន វើត ហ្នឹងទៅខ្ញុំក៏អត់ដឹងអត់ទទួលពត៌មានពីពួកគេបានទេ ព្រោះកាលហ្នឹងអ្នកណានៅកន្លែងណាគឺនៅកន្លែងហ្នឹង ឲ្យដឹងតែមួយកន្លែង១ទេ ។

ដានី៖ អត់ដឹងថា វី គាត់ទៅនៅកន្លែងណាទេ?

សែម៖ វី ហ្នឹងគាត់អត់បានមោជាមួយខ្ញុំទេ កាលជ្រើសរើសគាត់អត់បានមោជាមួយខ្ញុំគាត់នៅជាមួយតាពីន ហើយមិនដឹងជាគាត់ចាត់តាំងទៅណា រាល់ថ្ងៃមិនដែលបានជួបគ្នាទេក្រៅតែតាមទូរស័ព្ទ ។

ដានី៖ គាត់នៅឯណាឥលូវ?

សែម៖ នៅកំពង់ឆ្នាំង!

ដានី៖ នៅកំពង់ឆ្នាំង?

សែម៖ បាទ!

ដានី៖ ធ្លាប់ទាក់ទងតាមទូរស័ព្ទដែរ?

សែម៖ ធ្លាប់ទាក់ទងគ្នាឥលូវ១នេះ!

ដានី៖ នៅកំពង់ឆ្នាំងនៅកន្លែងណា?

សែម៖ នៅសាលាលេខ៥!

ដានី៖ ម៉េចបានពូបានទាក់ទងជាមួយគាត់ មានលេខទូរស័ព្ទ?

សែម៖ ទាក់ទងបានលុះត្រាតែយើងទៅផ្ទះហើយដឹងពីផ្ទះទៅវិញ ព្រោះគេក៏ទៅផ្ទុម្តាយឪពុកគេ ខ្ញុំក៏ទៅផ្ទះម្តាយខ្ញុំ ពេលគេទៅភ្ជុំហ្នឹងខ្ញុំអត់បានទៅទេខ្ញុំទៅចូលឆ្នាំ គេទៅចូលឆ្នាំខ្ញុំអត់បានទៅពេលណាដែលខ្ញុំមានសោហ៊ុយទៅព្រោះវាឆ្ងាយដែរ អញ្ចឹងខ្ញុំទៅតាមលទ្ធភាពដែលខ្ញុំមានលុយ ។

ដានី៖ គាត់នៅភូមិអីដែរ?

សែមៈ អត់ដឹងភូមិអីទេ តែមានលេខទូរស័ព្ទសម្រាប់ទាក់ទងគ្នា!

ដានីៈ គាត់មានប្រពន្ធនូវ?

សែមៈ បាទមានប្រពន្ធ មានកូន មានចៅហើយ!

ដានីៈ អ៊ំ!

សែមៈ ព្រោះអាយុប្រហែលគ្នា អាយុពាក់កណ្តាលមនុស្សហើយ!

ដានីៈ បាទ! ចុះពូកាលនៅជាមួយតាវ៉ន វើតហ្នឹងគាត់ធ្វើអីគេ?

សែមៈ ឧបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច!

ដានីៈ កន្លែងគាត់ធ្វើការនៅកន្លែងណា?

សែមៈ កន្លែងធ្វើការមិនដឹងនៅកន្លែងណាពិតទេ ក្រោយម៉ោដែលខ្ញុំចេញពីគាត់ទៀតម៉ោខ្ញុំក៏លែងនេះព្រោះដូរកន្លែងច្រើនហើយខ្ញុំអត់ចាំ ។

ដានីៈ អញ្ចឹងពេលដែលពូចេញម៉ោកន្លែងរោងចក្រហ្នឹងនៅក្រោមការគ្រប់គ្រងរបស់តាវ៉ន វើត ឬក៏គេផ្សេង?

សែមៈ កាលពីមុនគាត់គ្រប់គ្រងនៅក្រសួងឧស្សាហកម្ម គ្រប់គ្រងពីលើតាចេង អន ដូច្នេះតាចេង អន គាត់គ្រប់គ្រងក្រសួងឧស្សាហកម្ម ក្រសួងឧស្សាហកម្មមានចេង អន ហើយមានប៉ុន្មាននាក់ទៀតទេ មានតាម៉ៅមានអី ប៉ុន្តែខ្ញុំវាមិនសូវចាំវាភ្លេចអស់ហើយ តែពីលើកាលដែលខ្ញុំនៅជាមួយតាវ៉ន វើតហ្នឹងខ្ញុំអត់ទាន់ចេញម៉ោរោងចក្រហ្នឹងគាត់នៅគ្រប់គ្រងហ្នឹងនៅឡើយទេ គ្រាន់តែខ្ញុំចេញម៉ោគាត់ទទួលជាឧបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច គាត់ទទួលអាលើផងអាធំផង! មិនដឹងជាគាត់ទទួលបានប៉ុន្មាន ព្រួសម្ដេចថាវ៉ន វើតឧបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចទូទាំងប្រទេស ។

ដានីៈ ពេលហ្នឹងពូចេញពីគាត់ហើយ?

សែមៈ បាទ! ខ្ញុំចេញហើយ!

ដានីៈ ទៅនៅរោងចក្រ“ក”មួយ?

សែមៈ បាទ!

ដានីៈ កាលហ្នឹងអ្នកគ្រប់គ្រងរោងចក្រតាចេង អន?

សែមៈ បាទ!

ដានីៈ ចេង អន គាត់ខាងឧស្សាហកម្មអញ្ចឹង?

សែមៈ បាទ! ចេង អន ខាងឧស្សាហកម្ម ខ្ញុំធ្លាប់គាត់នាំដើរតែខ្ញុំដូចថាការពារគាត់មិនបានដូចថាគេ ក្មេងវារវល់តែដេកណា៎!

ដានីៈ បាទ!

សែមៈ កាលហ្នឹងអាយុ១៥ឆ្នាំ អាយុ១៥កំពុងពេញដេកណា៎ ដល់ខ្យល់វ៉ូៗទៅវាអត់បានទៅឆ្ងាយដូចជាទៅកំពង់សោមអីហ្នឹងអត់បានទៅទេ បានទៅត្រឹមលោកតាមីប្រាំង!

ដានីៈ មីប្រាំង?

សែមៈ បាទ! មីប្រាំងហ្នឹងគាត់ទទួលខាងគមនាគមន៍ ដល់ពេលអញ្ចឹងខ្ញុំនៅជាមួយលោកតាវន វើត ឧស្សាហ៍ទៅមើលផ្លូវ ធ្វើស្ពាន ខ្ញុំទៅដើរតាមគាត់ហ្នឹង។

ដានីៈ ដើរតាមវន វើត?

សែមៈ វន វើតហ្នឹង! ហើយដល់ពេលត្រឹមប៉ុណ្ណឹងម៉ោខ្ញុំក៏ចេញម៉ោចុង៧៥ហ្នឹង ដើមឆ្នាំ៧៦ហ្នឹងខ្ញុំមកនៅរោងចក្រលែងដឹងអីទាំងអស់។

ដានីៈ មកនៅរោងចក្រម៉េចលែងអញ្ចឹង?

សែមៈ ចុះវាអត់មានជាប់ពាក់ព័ន្ធអីនឹងគ្នាផង ព្រោះកាលណាតែចូលដល់ក្នុងអង្គភាពមួយវាអត់មានទាក់ទងគ្នាទេ ជំនាន់នោះគឺអត់មានទាក់ទងគ្នាទេ អត់មានត្រូវទាក់ទងជាផ្លូវការអីទេ ហើយក៏យើងអត់មានការងារអីទៅនិយាយជាមួយគេដែរ! គេរឿងគេ! យើងរឿងយើង។

ដានីៈ អញ្ចឹងចាប់ពីឆ្នាំ៧៦ពូមកនៅរោងចក្រហើយ?

សែមៈ បាទ!

ដានីៈ ចុះតា ទុយ គឿន?

សែមៈ តា ទុយ គឿនខ្ញុំអត់ស្គាល់ទេព្រោះគេផ្នែកផ្សេង! តាគឿនគាត់ខាងអីផ្សេងទេអាហ្នឹងខ្ញុំយល់អត់ដល់ទេ!

ដានីៈ បាទ!

សែមៈ ព្រោះខ្ញុំក៏មិនចាំដែរ!

ដានីៈ បាទ! ចុះម៉ោរោងចក្រគេឲ្យធ្វើអីទៅ?

សែមៈ ខ្ញុំម៉ោក្រឡឹងដែក ផ្សារដែក តំឡើងម៉ាស៊ីន វ៉ៃគ័ ហើយត្រូវតំឡើងម៉ាស៊ីនស្ទូងទៀត តែគ្រាន់តែចេញពីម៉ាស៊ីនវ៉ៃគ័រនោះខ្ញុំធ្វើបាន៣០ទៅ៤០គ្រឿង ខ្ញុំឲ្យធ្វើម៉ាស៊ីនបោកស្រូវ ពេលនោះខ្ញុំក្រោយពីក្រឡឹងដែកម៉ោគេឲ្យខ្ញុំធ្វើកម្លាំងចល័តទៀត ឈូសឈើក៏បាន ដែកក៏បាន តំឡើងគ្រឿងម៉ាស៊ីក៏ចេះ តែចេះទៅតាមអ្នកបច្ចេកទេសឲ្យធ្វើ។

ដានី៖ មានអ្នកបច្ចេកទេសដែរ?

សែម៖ មានអ្នកបច្ចេកទេស!

ដានី៖ អ្នកបច្ចេកទេសម៉ោពីណាម៉ោ?

សែម៖ អ្នកបច្ចេកនៅហ្នឹង! ពិសោធន៍ម៉ាស៊ីនបោកស្រូវអាវិលកង់មូលៗដាក់ម៉ាស៊ីនកណ្តាលមួយទាញដូចជាសំណាញ់អញ្ចឹងណា៎ អាតៗគ្នាហ្នឹង អាយើងដាក់កណ្តាប់ពីលើហ្នឹងអាហ្នឹងហើយម៉ាស៊ីនខ្ញុំធ្វើ យើងគិតតែក្រឡឹងដុំនេះដុំនោះហើយយើងយកមកធ្វើខ្លួនឯង យើងផ្សាយើងវៃអាធ្មេញនោះខ្លួនឯងហើយពេលដែលខ្វះឈើយើងទៅឈូសឈើតែយើងមិនមែនឈូសដៃដូចឥឡូវទេ យើងឈូសម៉ាស៊ីនហើយក៏មិនមែនម៉ាស៊ីនដៃដែរ ម៉ាស៊ីនតាមយើងយើងដាក់ទ្រិតអញ្ចឹងទៅកាត់វាជារាងពងក្រពើឬក៏ខ្នងអណ្តើកអញ្ចឹងទៅ ។

ដានី៖ ហើយកាលហ្នឹងអ្នកបច្ចេកទេសៗសល់ពីសង្គមមុនម៉ោឬក៏អ្នកបច្ចេកទេសដែល...?

សែម៖ មានសល់ពីមុនខ្លះ ថាកម្មករចាស់ អតីតកម្មករចាស់ ហើយគេនិយាយថាដូចខ្ញុំអញ្ចឹងធ្លាប់ធ្វើសម័យរាស្ត្រនិយមអញ្ចឹងទៅហើយខ្ញុំនៅកាន់ការងាររោងចក្រអញ្ចឹងទៅអ្នកបច្ចេកទេសវាថាធ្វើឆ្នាំងធ្វើចានអីចឹងទៅ គេធ្វើពុម្ពចាន ពុម្ពឆ្នាំងចឹងទៅក៏គេយកមនុស្សហ្នឹងប្រើ ហើយយើងហ្នឹងធ្វើតាមគាត់ទៅថាឥឡូវក្រឡឹងពុម្ពអញ្ចេះយើងបេះក្រឡឹងយើងក្រឡឹងតាមគាត់ទៅ គូសតែគំនូរម៉ោឲ្យធ្វើតាមថាពុម្ពរាងអញ្ចេះហើយយើងក្រឡឹងតាមហ្នឹងទៅហើយយកឲ្យគេប្រើទៅគេប្រើមិនកើតគេឲ្យយើងធ្វើទៀតទៅ អាហ្នឹងវាទាក់ទងគ្នារហូត ពុម្ពស្បែកជើងអាហ្នឹងគេហៅដាប់ ធ្វើស្លាបព្រា ធ្វើចានធ្វើច្រើនមុខណាស់រោងចក្រហ្នឹង ។

ដានី៖ រោងចក្រ«ដ»មួយ?

សែម៖ រោងចក្រ«ដ»មួយ!

ដានី៖ មានមនុស្សច្រើន?

សែម៖ មាន៨០០នាក់! ផ្នែកក្រឡឹងហ្នឹងវាមានផ្នែកវា មានផ្នែកក្រឡឹង មានផ្នែកតំឡើងគ្រឿងមានផ្នែកឆ្នាំង មានផ្នែកម៉ាស៊ីនប៉េម៉ាស៊ីនសង្កត់ ពីមុនគេហៅម៉ាស៊ីនសង្កត់តែឈ្មោះវាប៉េបានន័យថាវាបុកជាន់ជាពុម្ព ជាន់ស្លាបព្រា ជាន់ចាន ជាន់ឆ្នាំង ហើយវាមានច្រើនវាមាននៅផ្នែកក្រូមេ៉ ។

ដានី៖ សុទ្ធតែកុមារអាយុប្រហែលពូឬក៏អាយុប៉ុន្មាន?

សែម៖ មានប្រហែលខ្ញុំហ្នឹងច្រើនហើយមានបងៗក៏ច្រើនដែរដែលម៉ោពីបូព៌ា គេម៉ោដូចថាសឹកពីលោកហើយម៉ោក៏ចូលរួមធ្វើការនៅរោងចក្រទាំងស្រីទាំងប្រុស ។

ដានី៖ មានស្រីមានប្រុស?

សែម៖ មានស្រីមានប្រុស ពេលនោះមុនដំបូងគេហៅប្រធានប្រុសៗទេ ដល់ពេលឆ្នាំ១៩៧៧គេចាត់តាំងឲ្យមនុស្សស្រីធ្វើប្រធាន ប្រធានតាំងពីប្រធានផ្នែកស្រី ប្រធានក្រុមក៏ស្រី ប្រធានពួកក៏ស្រីដែរ តែក្នុងហ្នឹងមានតែមនុស្សប្រុសមួយៗដូចថាមនុស្សស្រីធ្វើប្រធាន ព្រោះគេចូលចិត្តយកស្រីអញ្ចឹងណា៎ធ្វើឲ្យវាចូលក្នុងការងារ មនុស្សស្រីប្រធានប្រុសអនុ គេឲ្យធ្វើអញ្ចឹងហ្នងៗ

ដានី៖ ចុះពីដំបូងប្រុសទេ?

សែម៖ ប្រុស!

ដានី៖ ហើយពីណាគេដំបូង?

សែម៖ ប្រុសហ្នឹងវាមានច្រើនដូចថាប្រធានរោងចក្រហ្នឹងឈ្មោះ ហ៊ាញ! ឈ្មោះ ហ៊ាញ ហ្នឹងប្រធានរោងចក្រៗ

ដានី៖ គាត់ម៉ោពីណា?

សែម៖ អតីតគាត់ហ្នឹងខ្ញុំអត់ដឹងម៉ោពីណាទេ! ប៉ុន្តែបើតាមខ្សែចង្វាក់គាត់ចេញពីវ៉ន វើត អាស៊ំចេញពីចេង អនៗ

ដានី៖ ចេញពីចេង អន?

សែម៖ ហ្នឹងអើយព្រោះការដឹកនាំច្រើនចេញពីអញ្ចឹងៗ ហើយដឹងគាត់អត់ច្បាស់ទេប៉ុន្តែខ្ញុំដឹងខ្សែហ្នឹងព្រោះខ្ញុំធ្វើអីអត់ដែលចេះខុស ទោះខុសក៏គេអត់ហ៊ានថាឲ្យខ្ញុំដែរ! តែអត់ដឹងទើបតែឥលូវទើបដឹងថាអ្នកចេញពីអញ្ចឹងយើងចេញម៉ោគេខ្លាចយើងៗ

ដានី៖ អញ្ចឹងកាលជំនាន់ហ្នឹងពូចេញពីខ្សែវ៉ន វើត?

សែម៖ បាទ! ខ្ញុំចេញពីវ៉ន វើត តែការរស់នៅ ចេង អន ក៏នៅ វ៉ន វើត ក៏នៅកាលដែលខ្ញុំនៅប៉ុន្តែគ្រាន់ផ្ទះគាត់ដោយឡែក ចង្ក្រានតែមួយតែការហូបផ្សេងគ្នា! ខ្ញុំនៅជាមួយវ៉ន វើតនៅផ្ទះវ៉ន វើត គេនារសាចេង អន គេនៅជាមួយចេង អន ទៅ អ្នកណានៅជាមួយគាម៉ោហ្នឹងនៅជាមួយគាម៉ោទៅ គេនៅជិតគ្នាៗក៏ប៉ុន្តែគេដូចថាពិភាក្សាអីគេងាយស្រួលពិភាក្សាគ្នាព្រោះកាលនោះគេសន្សំសំចៃណាស់ សូម្បីតែឡានក៏ជិះឡាំម៉ាគាដែរៗ

ដានី៖ ជិះឡាំម៉ាគា?

សែម៖ ហ្នឹងអើយ! អាស៊ីបអីគេឈប់ជិះហើយព្រោះវាស៊ីសាំងពេកៗ

ដានី៖ ចុះដល់ពេលពូនៅរោងចក្រពូមានតួនាទីអីដែរប្អូនអត់?

សែមៈ	នៅរោងចក្រអត់មានតួនាទីអីទេ! មុនដំបូងអត់មានតួនាទីអីទេ តួនាទីខ្ញុំដឹងតែពីធ្វើក្រឡឹង ដឹងតែពីខំរៀនៗតាមបងៗពេលនោះខ្ញុំខស្បាហ៍ណាស់បងៗស្រលាញ់ណាស់ ធ្វើការរហ័សរហួន ហើយម៉ត់ចត់ទៀតបានគាត់ស្រលាញ់ហ្នឹង ។

ដានីៈ	បងៗដែលធ្វើការជាមួយពូហ្នឹងឬក៏បងៗផ្សេងៗ ?

សែមៈ	អ្នកនៅជាមួយ កាលណាអ្នកនៅជាមួយពេញចិត្តយើងហើយកិច្ចការអត់ចេះខុសទេ យើងអត់រើសទីរើសឆ្អឹងអីទេព្រោះយើងចេះតែខំធ្វើដើម្បីឲ្យការងារហ្នឹងបម្រើបក្សបម្រើប្រជាជន កាលជំនាន់នោះគេប្រើអញ្ចឹងណា៎ បម្រើបក្សប្រជាជនយើងឲ្យបានជឿនលឿនមហាលោតផ្លោះ មហាអស្ចារ្យ ។

ដានីៈ	ចុះកាលនោះការហូបចុកយ៉ាងម៉េចដែរ?

សែមៈ	ការហូបចុកពេលនោះខ្ញុំនៅក្មេងយើងអត់សូវចេះគិតអីទេ ប៉ុន្តែដោយការពេលនោះបងៗគាត់ស្រលាញ់ខ្ញុំ ការហូបចុកហូបមិនឆ្អែតទេព្រោះយើងពេញហូបណាស់ យើងហូបនំបុ័ងមួយឬក៏មួយម៉ាកាណាត់នោះបានហូបឆ្អែតហើយជាមួយសម្ល តែអនិច្ចាអីកាលនោះពេញរូបពេញរាងហូបហើយបានតែនំបុ័ងមួយកាណាត់ របបមួយពេលបាននំបុ័ងមួយម៉ាណាត់ ហើយសម្លហ្នឹងគឺថាម៉ោតែស្លាបព្រាវួម ចានដោយឡែកៗហ្នឹង តែវើអាគាំងម៉ឺងលាងដៃព្រុសប្រាស់ៗប្រុចមកដល់កន្លែងហ្នឹងគ្រប់១០នាក់ឬ៨នាក់ដែលគេកំណត់ហ្នឹងយើងចូលឲ្យគ្រប់៨នាក់ទៅបានយើងចូលហូប ហើយនំបុ័ងគេកាត់ឲ្យម្នាក់មួយៗហើយអត់ឲ្យមានលើសទេ៨នាក់គឺ៨កាណាត់ ហើយសម្លមួយចាននៅកណ្តាលតុហ្នឹង ហើយមានចានមានស្លាបព្រាវួម អត់មានសិទ្ធដើរដួសអីអាញ៉ែអាញ៉ៃដណ្តើមគ្នាអត់ទេ របបមានត្រឹមត្រូវប៉ុន្តែគ្រាន់តែហូបអត់ឆ្អែត ។

ដានីៈ	ហូបអត់ឆ្អែតធ្វើម៉េចទៅអញ្ចឹង?

សែមៈ	អ្នកអត់ឆ្អែតហ្នឹងចេះតែហូបដូងទុំឬញក៏ប៉ោចនេះប៉ោចនោះហូបអញ្ចឹងទៅ តែដូចខ្ញុំមួយថាកំសត់ក៏ថាបានថាមិនកំសត់ក៏ថាបានព្រោះមានបងៗគាត់ស្រលាញ់ ដល់ស្រលាញ់អញ្ចឹងទៅគាត់ឲ្យដូចថាគាត់ត្រូវជាមួយចុងភៅខ្លះទៅគាត់យកអានំបុ័ងហ្នឹងយកមកឲ្យខ្ញុំហូប ប៉ុន្តែថែមឲ្យខ្ញុំមួយកំណាត់ទៀត យកមកឲ្យខ្ញុំបានរាល់ថ្ងៃ តែដោយសារការស្រលាញ់យើងធ្វើឲ្យគេស្រលាញ់គាត់បីយើងត្រកងយើងមកឲ្យផ្ទូតទឹក ដូចថាយើងនៅពីក្មេងមានរូបរាងធ្វើឲ្យគេពេញចិត្ត ហើយគាត់ចេះតែយកអាហ្នឹងមកឲ្យខ្ញុំក៏ចេះតែបានឆ្អែតអញ្ចឹងទៅ ។

ដានីៈ	ចុះអ្នកផ្សេង?

សែមៈ	អ្នកផ្សេងដឹងធ្វើម៉េចវាអត់ចឹងទៅ ។

ដានី: កាលហ្នឹងម៉េចបានគេអត់ឲ្យយើងហូបបាយឲ្យហូបនំបុ័ងវិញ?

សែម: មិនដឹងយ៉ាងម៉េចព្រោះតាមដែលដឹកនាំនិយាយថាយើងខ្វះខាតស្បៀង ។

ដានី: ពីព្រោះយើងធម្មតាខ្មែរយើងចូលចិត្តតែហូបបាយ!

សែម: បាទហូបបាយ! ហូបបាយហ្នឹងគឺហូបឲ្យឆ្អែត ពេលនោះអ្នកដែលឃ្លានខ្លាំងដូងទុំជ្រុះម៉ោនាំគ្នាហូបលេងហូបបន្ថែមក្រពះអញ្ចឹងទៅ តែដោយសារតែថាវាអត់មានការគំរាមគំហែងខ្លាំងវានៅក្នុងទីក្រុងភ្នំពេញវាមានការស្ងៃស្ងាំង តែការគំរាមកំហែងវាអត់មានទេ តែគ្រាន់ថាវិន័យវាគំរាមកំហែងតែពាក្យសំដីអត់មានមកអាញ៉ែអាញ៉ែអីជាមួយយើងទេ តែបើអ្នកមិនសូវគោរពវិន័យនោះអាហ្នឹងវាមានបញ្ហា ។

ដានី: អញ្ចឹងពូហូបនំបុ័ងរហូតដល់?

សែម: ហូបមិនដឹងប៉ុន្មានខែទេ! ពេលហ្នឹងហូបនំបុ័ងក្នុងពេលវេលាដែលត្រូវអត់ទាន់ចេញ ដល់អញ្ចឹងទៅចេះតែសួដែរថាហេតុអីបានឲ្យតែខ្ញុំហូបនំបុ័ងដូចបារាំងអញ្ចឹង? ហើយគេអ្នកដឹកនាំចេះតែមានពាក្យឆ្លើយថាម៉ោពីយើងវាខ្វះខាតអង្ករព្រោះយើងនៅរោងចក្រយើងធ្វើខបត្តម្ភទៅដល់កសិករសហករណ៍មិនបានពេញលេញ ដល់អញ្ចឹងធ្វើស្រូវធ្វើស្រែហ្នឹងវាអត់បានពេញលេញប្អូនទាំងអស់ហ្នឹងខំផលិតគ្រឿងអីឲ្យលឿនទៅ អាហ្នឹងទៅតាមការឃោសនាពេលហ្នឹងហើយយើងក៏មិនដឹងដែរចេះតែធ្វើទៅ សូម្បីតែទៅផ្ទះអីក៏គេអត់ឲ្យទៅដែរ ពេលនោះបើខ្ញុំលួចទៅផ្ទះដឹងតែងាប់ហើយព្រោះស្រុកនោះគេវៃចោល ឃើញកន្លែងពោធិ៍ទន្លេជាកន្លែងមួយដែលគេធ្វើសារៈមន្ទីរហើយដាក់សុទ្ធតែឆ្អឹងមនុស្ស ។

ដានី: ពូធ្លាប់ឃើញដែរ?

សែម: ចុះខ្ញុំនៅហ្នឹងខ្ញុំមិនឃើញ!

ដានី: អ៊ំ! ពូទើបតែឃើញក្រោយឬ?

សែម: ឃើញក្រោយ ទើបតែឃើញខ្ញុំផ្ដាច់ខ្លួនហើយហ្នឹងខ្ញុំទៅ ។

ដានី: កាលពីជំនាន់ហ្នឹងពូអត់ដែលឃើញទេ?

សែម: អត់ដែលឃើញផ្ទះម៉េចទេ! ម្ដាយខ្ញុំគេជម្លៀសទៅកោះអាការនោះមិនមែននោះហ្នឹងណា៎! ផ្ទះធំហ្នឹងរុះរើខ្ទេចខ្ទីអស់ ។

ដានី: អញ្ចឹងកាលពីជំនាន់ពាឆ្នាំកាលពីមុនហ្នឹងអត់ដែលទៅទេ? អត់ដែលដឹងថាកន្លែងពោធិ៍ហ្នឹងជាកន្លែងអីទេ?

សែម: អត់ដឹង!

ដានី៖ អញ្ចឹងកាលហ្នឹងពូអត់ដែលទៅផ្ទះទេ?

សែម៖ អត់សោះ! ពេលនៅវៃគ្នាកាលវៃជាមួយលន់ នល់នោះអាហ្នឹងយើងចេញចូលដោយសារតែ យើងយកសំបុត្រទៅព្រែកតូច ទៅឫស្សី កន្លែងមន្ទីរមួយៗ ។

ដានី៖ អញ្ចឹងក្រោយម៉ោពូមានបានហូបបាយដែរឬទេ?

សែម៖ ក្រោយម៉ោហូប!

ដានី៖ ហូបឆ្អែតទេ?

សែម៖ ហូបឆ្អែត!

ដានី៖ ចុះតាវន វើត តាចេង អន អីគាត់ធ្លាប់ទៅសួសុខទុក្ខដែរទេ?

សែម៖ គាត់ទៅសួសុខទុក្ខ មែនទែនពេលដែលចេង អនគាត់ទៅមើលគាត់ដើរមើលក្នុងរោងចក្រ គាត់មានបានទៅមើលការហូបចុកទេ!

ដានី៖ អ៎!

សែម៖ អាហ្នឹងស្រេចតែការរាយការណ៍របស់គេ!

ដានី៖ រាយការណ៍របស់គេ?

សែម៖ ហ្នឹងអើយ! វាមិនទៅឃើញពេលហូបចុកតាមដានឲ្យល្អិតណាអត់ទេ គេដឹងតែតាមដានថាឲ្យ យើងតំឡើងផែនការណ៍តំឡើងគ្រឿង គ្រឿងម៉ាស៊ីនវៃគោហ្នឹងបាន៣០គ្រឿងហ្នឹង ព្រោះ ផែនការគេឲ្យ យើងធ្វើ៣០ហើយយើងធ្វើបាន៣៥អីគេថាយើងធ្វើលើសផែនការព្រោះនោះ ខ្ញុំប្រឹងខ្លាំង ហើយប្រឹងដោយចិត្តស្មោះចំពោះជាតិចំពោះប្រជាជន តែអត់ដឹងថាអ្នកណាក្បត់ អ្នកណាទេ អ្នកណាធ្វើបាបអ្នកណាទេ! បើហ៊ានតែធ្វើបាបខ្ញុំកាចហ្មងកាលហ្នឹងមិនស្ងួតទេ ហើយខ្ញុំហ៊ានថា ឲ្យអ្នកណាក៏ដោយឲ្យតែរំលោភសិទ្ធខ្ញុំអត់បានទេ! អាហ្នឹងបានតែម្នាក់ខ្ញុំ និយាយហ្នឹងពីបុគ្គល ទេមិនមែននិយាយរួមថានេះទេ ប៉ុន្តែពេលនោះខ្ញុំហ៊ានធ្វើបានសម្រេច ហើយអ្នកណាមកនិយាយជាមួយខ្ញុំអត់បានទេ ដែលថាខុសរំលោភជាមួយខ្ញុំអត់បានទេ សូម្បី តែគណៈរោងចក្រក៏ដោយក៏ខ្ញុំថាដែរ! ពេលនោះខ្ញុំវាអត់ដឹងថាអ្នកណារំលោភអ្នកណាខ្ញុំអត់ ទេ តែក្រោយម៉ោគេផ្លាស់តាហេងហ្នឹងចេញទៅគេថាក្បត់ថាអីអញ្ចឹងទៅគេមានម្នាក់មកទៀត

ដានី៖ ពីណាគេហ្នឹង?

សែម៖ ឈ្មោះ វើត ឬក៏ឈ្មោះអីទេ!

ដានី៖ ស្រី?

សែម៖ ប្រុស គណៈរោងចក្រសុទ្ធតែប្រុសៗទេ តែបើប្រធានផ្នែកគឺស្រីៗ ។

ដានី៖ ឆ្នាំណា៧៧?

សែម៖ ៧៨

ដានី៖ ចុះតាចេង អន តាវន វើតគាត់...?

សែម៖ ខ្ញុំអត់ដឹងទេពេលនោះគាត់នៅក្នុងមន្ទីរខសូវ្យាហកម្មដឹងតែចេង អនទេ តែវន វើតដឹងតែគាត់ទៅនោះហើយដូច្នេះវាត្រូវតែដាច់ការទំនាក់ទំនងគ្នា គ្រាន់តែថាអ្នកធ្លាប់នៅជាមួយគ្នាអញ្ចឹងខ្ញុំចេះតែហៅអញ្ចឹងទៅពេលនោះខ្ញុំចង់បើកឡានតែគេមិនឲ្យខ្ញុំបើកទេព្រោះយើងនៅក្មេងហើយម្យ៉ាងទៀតគ្មានភារកិច្ចអីត្រូវបើកផង ។

ដានី៖ ចុះក្រោយម៉ោតាចេង អន នឹងវន វើតគាត់ទៅមើលរោងចក្រនៅទីណា?

សែម៖ វន វើត អត់ដែលទៅមើលទេគ្រាន់តែឮសូរថាគាត់ខុបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចទូទាំងប្រទេសម៉ោ បើចេង អន យូៗឃើញម្ដងតែឃើញហ្នឹងនៅក្នុងលក្ខណៈដូចជារូបថត តែមែនទែនមិនសូវជួបទេឃើញតែអ្នកថតអ្នកសម្ភាស៍គាត់អញ្ចឹងគេទៅថតពីឯកសារជាកុនជាអីអញ្ចឹងទៅចុះទស្សនាវដ្ដី ។

ដានី៖ បានចុះទស្សនាវដ្ដីដែរ?

សែម៖ មានទស្សនាវដ្ដីដែរ! អញ្ចឹងរឿងហ្នឹងវាពាក់ពាន់រហូតដល់ទីនេះ មកទីនេះឃើញថាទំនាយវើបានតែប៉ុន្មានឆ្នាំ ៣ឆ្នាំ ក្រៅពីហ្នឹងមានអាសន្នរហូតមកដល់ដីនេះដែលគេហៅស្រុកម៉ាឡៃភូមិម៉ាលៃអីពីមុនអត់ដែលមានទេ!

ដានី៖ ចុះលោកពូដល់ពេលដែលយួនចូលឆ្នាំ៧៩ នៅភ្នំពេញយ៉ាងម៉េចដែរលោកពូនៅរោងច្រកបុក៏យ៉ាងម៉េច?

សែម៖ អត់ទេខ្ញុំចេញហើយនៅពេលនោះ!

ដានី៖ ពេល៧៩ ហ្នឹងចេញពីហើយ?

សែម៖ បាទ! ៧៩ ហ្នឹងខ្ញុំចេញហើយពេលដែលយួនចូលម៉ោហ្នឹង ខ្ញុំត្រូវជម្លៀសចេញ ។

ដានី៖ ជម្លៀសចេញទាំងអស់គ្នារ?

សែម៖ បាទជម្លៀសទាំងអស់គ្នាទូទាំងមួយភ្នំពេញ និយាយទៅម៉ាចំហៀងខាងលិចហ្នឹងម៉ោទាំងអស់!

ដានី៖ យ៉ាងម៉េចទៅពូអាចជួយរៀបរាប់ពីអ្វីដែលពូនៅចាំស្ថានភាពពេលហ្នឹង ពេលដែលពូចូលម៉ោហើយរត់ចេញទៅវិញ ហើយអ្នកណាជាអ្នកណែនាំឲ្យពូរត់កន្លែងណាទៅកន្លែងណា?

សែម៖ ពេលនោះខ្ញុំរត់ម៉ោគេហៅស្ទឹងនៅបច្ចឹម ហើយចេញពីហ្នឹងម៉ោវិញម៉ោខាងពោធិ៍សាត់នេះវិញ គេឲ្យធ្វើស្រែបានមួយរដូវដែរ ធ្វើស្រែពេលជម្លៀសម៉ោគេនៅកំពង់ឆ្នាំងហ្នឹងគេ

ជម្លៀសឲ្យខ្ញុំទៅនៅក្រាំងដេវ៉ាយ ទៅនៅក្រាំងដេវ៉ាយចេះតែរត់ៗម៉ោចូលទៅក្រាំងដេវ៉ាយហ្នឹងហើយបានចេញពីក្រាំងដេវ៉ាយម៉ោបានគេឲ្យម៉ោបរិលនេះ ម៉ោតាមស្ទឹងទ្រាម៉ោត្រង់រហូតម៉ោបានធ្លាក់ម៉ោកំពង់ឆ្នាំងនេះ អ៊ីចេញម៉ោដំបូងនៅត្រពាំងជហើយចេញម៉ោពីភ្នំប្រសិតម៉ោបានគេឲ្យខ្ញុំចាក់ទៅថ្នល់ជាតិលេខ៨វិញ ហើយខ្ញុំប្រុងឆ្លងទៅផ្ទះនោះតែទៅអត់រួចអ៊ីក្រាំងដេវ៉ាយហ្នឹង បានក្រោយម៉ោដឹងម៉េចទេអ្នកដឹកនាំហ្នឹងចេះតែដឹកនាំម៉ោថាផ្លូវនៅហ្នឹងអត់មានអីស៊ីទេមានតែទៅបាត់ដំបងទេ ទៅបរិលមានអីហូប បានធ្លាក់ទៅពោធិ៍សាត់ហើយពោធិ៍សាត់ធ្លាក់ម៉ោលាចនេះម៉ោបានម៉ោដល់បរិល ។

ដានី: ពីណាដឹកនាំកាលហ្នឹង?

សែម: អ្នកដឹកនាំកាលហ្នឹងអ៊ីមានតាម៉ុកគាត់ចេះតែប្រាប់ម៉ោ តែពួកអ្នកដឹកនាំនៅក្នុងក្រុមហ្នឹងផ្នែកៗហ្នឹងចាំអត់អស់ទេ ។

ដានី: កាលហ្នឹងមានតាម៉ុកដែរ?

សែម: ហ្នឹងអើយតាម៉ុកគាត់ចេះតែទាញឲ្យម៉ោ ម៉ោឌិវ៉ាល់អីហ្នឹងវាចាំមិនអស់កាលហ្នឹង ។

ដានី: ហេតុអីបានជាតាម៉ុកគាត់ទៅដឹកនាំទៅវិញ ព្រោះកាលហ្នឹងនៅរោងចក្ររោងអីហើយគាត់នៅភូមិភាគទេ ហើយយើងកាលហ្នឹងអ្នកនៅភ្នំពេញរោងចក្រផ្សេង ហើយភូមិភាគផ្សេង?

សែម: ពេលនោះវាបែកបាក់ក្នុងរយៈអ្នកដឹកនាំផ្នែកតូចៗ ដល់អញ្ចឹងគាត់ត្រូវការកម្លាំងរបស់គាត់ហ្នឹងជម្លៀសពីភ្នំពេញម៉ោហ្នឹង ព្រោះគាត់ត្រូវការយោធា ដល់អញ្ចឹងគាត់ត្រូវប្រើជម្លៀសគ្រប់បែបយ៉ាងទាំងអស់ គឺគាត់អ្នកដឹកនាំទាញឲ្យទៅនៅណារស់ណាស់រាប់នៅណាក៏ចេះតែទាញទៅ គាត់ចេះតែទាញកម្លាំងហ្នឹងម៉ោបានមកដល់នេះដល់រដូវប្រូតកាត់ ដល់អញ្ចឹងគាត់ដេថាឯងនៅសម្ងំដើរសុំអង្ករគេធ្វើអី នោះទៅប្រូតទៅអីស៊ីខ្លួនឯងនៅបរិលនោះ ទៅនៅហ្នឹងទៅអត់ចេះរកស៊ីខ្លួនឯងគិតតែដើរសុំអង្ករគេ ប្រជាជនគាត់បានអង្ករបុកហើយយើងអត់ដឹងថារកចេះតែសុំគាត់ទៅ ។

ដានី: ពូកាលហ្នឹងមានកងទ័ពអីអត់ទេ?

សែម: ពេលហ្នឹងចេះតែម៉ោព្រឹបៗដូចទឹកឡើងតិចៗចឹង ថយចេះតែថយទៅហើយយើងនៅបានពីរបីថ្ងៃឬមួយអាទិត្យមានបញ្ហាថយទៀតទៅ ចេះតែថយៗរហូតមកដល់បរិលបានម៉ោកាតាងវ៉ាងនេះកាលហ្នឹងខ្ញុំមានម៉ូតូមួយខ្ញុំធាក់រហូតធាក់ដូចកង់ ពីមុនវាមានសាំងដល់ពេលអស់សាំងទៅខ្ញុំដោះខ្សែពានទៅដាក់តែប្រវ៉ាក់ធាក់តែចឹងដូចកងណាំហើយខ្ញុំរហូតបោះចោលនៅកាតាងវ៉ាងនេះ ចោលនៅហ្នឹងដើម្បីយកពោះវៀនដើរវៃប្រគួតៗ ចេះតែម៉ោរសាត់អណ្តែតដូចចកចឹង

ណាំតាមតែអ្នកដឹកនាំទាញទៅណាទាញទៅហ្នឹង ប៉ុន្តែកាលហ្នឹងបើសិនជាគេកៀរយកបានក៏ទៅជាមួយគេដែរហើយ នៅចាំទេ បើគិតទៅយើងអត់មានដឹងអីទេ! អញ្ចឹងបានថារឿងតាមគ្នានេះមិនមែនធម្មតាទេ ឲ្យតែទៅខាងណាទៅខាងហ្នឹងហើយ ហើយយើងមានភាសាខុសគ្នាណាំបងប្អូនៗ យើងដឹងតែបងប្អូនបាត់ហើយមែនឪដូវណាំ ដល់អញ្ចឹងយើងម៉ោតាមបងប្អូនបាត់ហើយ ស្តាប់បានតែភាសាដូចគ្នាចេះតែទៅៗ ដល់មកដល់បរិលនេះប្រមូលបានទាំងឃុំាងៗទៅដាក់នៅកំពង់ឆ្នាំង ប្រមូលស្រូវពីភូមិតូចមកដាក់នៅភូមិធំនៅកំពង់ឆ្នាំង ។

ដានី: ទៅយកដល់ភូមិតូចភូមិធំហ្នង?

សែម: ហ្នឹងអើយគេហៅថាម្ចាស់ប៉ែកខាងណា?

ដានី: ហើយឆ្ងាយសីងអីហ្នឹង?

សែម: ឆ្ងាយហ្នឹងអើយគេឲ្យជញ្ជូនម៉ោ?

ដានី: កំពង់ឆ្នាំងម៉ោជិតភ្នំពេញវិញហើយហ្នឹង?

សែម: អត់ទេកំពង់ឆ្នាំងបរិលនេះ!

ដានី: អ៎!

សែម: វាមានកំពង់ឆ្នាំងហ្នឹងមួយ មិនមែនកំពង់ឆ្នាំងយើងនោះទេ! ហើយដល់បានច្រើនគេថាយួនម៉ោទៀតហើយរត់ប្រូចទៅដល់អំពិល៥ដើម ម៉ោអំពិល៥ដើមហើយ!

ដានី: អំពិល៥ដើមនៅណា?

សែម: អំពិល៥ដើមនៅខាងលិចបរិល! គេថាមិនកើតទេនាំគ្នាទៅស្វាយស្រម៉ក៏នាំគ្នាទៅស្វាយស្រម៉ទៀត ។

ដានី: នៅណាពូ?

សែម: ស្វាយស្រម៉នៅក្បាលខ្មោចនេះ ហើយដល់ម៉ោដល់ស្វាយស្រម៉នេះគេថារៀបចំធ្វើទ័ពហ្នឹងខ្ញុំហ្នឹងនឹកចង់ធ្វើទ័ពនឹងគេ គេក៏ចំអន់ថាឯងតូចណាស់ ហើយខ្ញុំថាមិនដឹងទៅណាទេឃើញតែផ្អើលចុះផ្អើលឡើងហើយអត់មានកាំភ្លើងអីផង! ដល់ពេលគេមិនឲ្យចូលទ័ពនឹងគេ ប៉ុន្តែគេថាចាំគេឲ្យធ្វើក្រោយគេយកធំៗទៅសិន ហើយខ្ញុំថាឲ្យខ្ញុំសុំទៅមួយផង ហើយគេថាអត់ទេអូនឯងចាំរៀបជើងក្រោយពួកធំៗគេយកទៅសិនក៏ទៅមួយសារទៅ ដល់ពេលហ្នឹងគេឲ្យម៉ោអូឡាំជិកជម្មៀសពីស្វាយស្រម៉ម៉ោអូឡាំជិក ។

ដានី: ស្វាយស្រម៉នៅខេត្តណា?

សែម: នៅខេត្តបាត់ដំបង!

ដានី៖ ជិតបរិលហ្នឹងដែរ?

សែម៖ បាទ! ប៉ុន្តែឥលូវគេរៀបចំមិនដឹងអីណាណីទេ ដល់ពេលម៉ោអូឡាំជិកហើយបានម៉ោអូកាច់នេះ ហើយថ្នល់ដែលដាច់ហ្នឹងគេហៅថាអូកាច់ថ្នល់ដាច់ៗ មកដល់កន្លែងហ្នឹងម៉ោបានគេឲ្យម៉ោហឹត អាហ្នឹងមានផ្ទះតិចតួច ដល់អញ្ចឹងគេរៀបទ័ពខ្ញុំនៅកន្លែងហ្នឹងទៅ ។

ដានី៖ បានចូលទ័ពនៅកន្លែងហ្នឹងទៅ?

សែម៖ ហ្នឹងអើយបានចូលនៅកន្លែងហ្នឹង លោកនាយកនហ្នឹងគាត់រៀបកម្លាំងហ្នឹង ដល់រៀបកម្លាំង ចាត់តាំងហើយឲ្យហាត់កាំភ្លើងបាញ់មួយគ្រាប់ៗ ឲ្យបាញ់ដាក់ចូលគ្រាប់ជាមួយយួន ដោយ បច្ចេកទេសយើងអត់គ្រាប់ផងអត់បង់ផងគេប្រើនយោបាយមួយហៅថាបាញ់មួយគ្រាប់ៗទៅ បានវាអត់ហ៊ាន វាឃើញមួយបាញ់មួយហើយដល់មួយដួលហើយយើងដាក់មួយគ្រាប់ទៀត វិធីហ្នឹងទីមួយទ្រូដងអត់ផងវាទៅតាមទិសសគ្រ្កាមឈ្លបហើយវ៉ៃឈ្នះមែន ដល់អញ្ចឹងគាត់យក ឡានម៉ោពីគេហៅឡានកាត់ដឹកខ្ញុំពីហឹតហ្នឹងកាត់ផ្លូវ៥០២ហ្នឹងទៅដល់កំរៀង ដល់កំរៀងហ្នឹងខ្ញុំ ទៅហ្នឹងគេចាត់តាំងឲ្យខ្ញុំកាន់ក្រុម ក្រុមខ្ញុំហ្នឹងតូចៗខ្ញុំក៏ប្រកែកថាកាំភ្លើងធំចង់ងាប់អាណាលីរួច ទេ អាណាអន្ទរផង អាណាទឹកផង អាណាគ្រាប់ផង ហើយចេះតែប្រកែកឲ្យតែឲ្យ ដល់ទៅ យកអាកាំភ្លើងយកម៉ោវាលចាប វាលចាបហ្នឹងនៅម្តុំប្រាំងហ្នឹងណា៎ ដើរកាត់អាហ្នឹងវាស្ទាក់ ស្ទើររៀងទៅកំពង់លៃ ហើយទៅកំពង់លៃដល់ចេញពីកំពង់លៃទៅកកោះ អាស៎ទៅភ្នំកុយ ដល់ចេញពីភ្នំកុយទៅវ៉ៃនៅកកោះ វ៉ៃកកោះហ្នឹងដើម្បីវ៉ៃទម្លាយហ្នឹងទៅនៅប៉ៃលិន ដល់ទៅវ៉ៃ ជាមួយយួនហ្នឹងចាញ់យួនរត់មកវិញមកនៅកំពង់លៃ មកនៅកំពង់យួនវាចូលមកវ៉ៃទៀតក៏រត់ មកប្រាំងនេះ ត្រលប់ត្រឡិនចុះឡើងៗក៏អន្តការនេះហ្នឹងនៅដូចថានៅតែក្នុងព្រៃរហូតដល់ ពេលមានអ្នកឈឺអញ្ចឹងក៏ជួយជូនអ្នកឈឺម៉ោអញ្ចឹងទៅ ដល់អញ្ចឹងគេអូសទាញខ្ញុំថាទៅនៅអីនាំ តែងាប់ទេឯង ទៅនៅថៃទៅ ទៅស៊ីឈ្នួលថៃទៅ ហើយខ្ញុំហ្នឹងមនុស្សវាមិនដែលស៊ីឈ្នួលគេ ហើយខ្ញុំមិនដែលធ្វើខ្ញុំអ្នកណានោះក៏ទឹកភ្នែកយំហូរព្រោះយើងកូនអ្នកធូធារដែរពីមុនដល់ពេល នឹកឃើញអារឿងដើមថាអារឿងខ្ញុំគេគេជៀលនោះខ្ញុំក៏ទឹកភ្នែករហូតថាអញតាំងពីតូចរហូត ដល់ប៉ុននេះអញមិនដែលទៅធ្វើខ្ញុំអាណាទេ ដល់អញ្ចឹងវាមិនយល់ ដល់អញ្ចឹងគេថាបើឯងចង់ ទៅងាប់វិញទៅងាប់ទៅយើងត្រលប់ម៉ោវិញដឹងតែគេវ៉ៃចោលហើយ យើងរត់ចោលគេណា៎ ខ្ញុំនៅជាមួយកងតាបៃ ។

ដានី៖ កងតាបៃ?

សែម៖ បាទ! កងតាបៃ! តែឥលូវគាត់ធ្វើក្រុមប្រឹក្សាក្រុម

ដានី៖	គាបែជាមួយគាដនអីហ្នឹង?

សែម៖	គាបែមិនមែនជាមួយគាដនទេ គាបែគាត់អនុវរៈសេនាធំកាលហ្នឹង!

ដានី៖	បាទ!

សែម៖	ខ្ញុំនៅជាមួយកាន់កាំភ្លើងធំកាលហ្នឹងទៅវៃអំពិល៥អិហ្នឹង ដល់ពេលកម្លាំងហ្នឹងអាញៀអាញៀក៏ចូលជំរុំទៅ ។

ដានី៖	ចូលជំរុំណា?

សែម៖	ចូលជំរុំស្រះកែវ!

ដានី៖	ឆ្នាំណាហ្នឹងពូ?

សែម៖	ឆ្នាំ៨០!

ដានី៖	អ៊ំអញ្ចឹងកាលពេលវៃហ្នឹងនៅឆ្នាំ៩៧នៅឡើយ?

សែម៖	នៅឆ្នាំ៩៧!

ដានី៖	អាពេលដើរវៃចុះឡើងៗហ្នឹងមែន?

សែម៖	បាទ! ហើយដល់ទៅជំរុំទៅក៏ជួបបងប្អូន ពូម្នាក់ឈ្មោះពូយេង!

ដានី៖	គាត់នៅណាពូ?

សែម៖	នេះនៅទួលសង្កែ!

ដានី៖	នៅទួលសង្កែ?

សែម៖	បាទទួលសង្កែនៅហួសស្ពានថ្មបន្តិចហ្នឹង គាយេងៗ!

ដានី៖	គាត់អ្នកស្រុកពូមែន?

សែម៖	បាទ! អ្នកស្រុកខ្ញុំឃើញខ្ញុំទៅសួរខ្ញុំថាឯងនៅរស់ទេ ហើយខ្ញុំថានៅរស់ ហើយគេសួរថាឯងនៅអង្គភាពណា ហើយខ្ញុំថាពីមុនខ្ញុំនៅរោងចក្រ ហើយគាត់ហ្នឹងនៅខាងជើងទឹក គាត់មនុស្សចាស់ធ្វើទូកធ្វើកសិកម្ម ដល់ពេលអញ្ចឹងទៅដើរៗនិយាយទៅវែងឆ្ងាយ ដើរៗទៅខ្ញុំនៅមួយផ្នែកដូចថាមនុស្សប្រុស៤នាក់មុនដំបូង ដល់នៅ៤នាក់មានម្នាក់នោះមិនដឹងឈ្មោះអីទេភ្លេចបាត់ហើយវាប៉ិនលួចគេពេក ។

ដានី៖	ប៉ិនលួចម៉េចទៅ?

សែម៖	ដូចថាលួចរបស់គេចូលម៉ោក្នុងផ្ទះយើងអញ្ចឹងណ៎ា ហើយយើងកំពុងតែរកសេចក្ដីសុខដង ដល់អញ្ចឹងលួចរបស់គេដូចជាប្រេង ម្សៅ អង្ករ ស្ករបស់ចិនៗដែលគេលក់យកមកជំរុំហ្នឹងណ៎ា!

ដានី៖	នៅក្នុងដីថៃ?

សែមៈ លួចនៅក្នុងជំរុំហ្នឹងណា៎!

ដានីៈ បាទ!

សែមៈ ដល់អញ្ចឹងខ្ញុំថាមនុស្សដែលមានចរិកចោរនៅជាមួយខ្ញុំអត់បានទេ! ព្រោះខ្ញុំមនុស្សត្រង់ មនុស្សខ្ញុំអត់ចេះលួចរបស់គេ ។

ដានីៈ បាទ!

សែមៈ ដល់អញ្ចឹងខ្ញុំខ្លាចគេតាមម៉ោវៃដល់ខ្ញុំដល់អិហ្នឹងវាខូចកិត្តិយសខ្ញុំ ដល់អញ្ចឹងទៅខ្ញុំក៏ប្រាប់ម្នាក់ទៀតថាបើបងឯងមាន បងហ្នឹងគឺគាត់ទៅនៅប្រទេសអាមេរិចណោះ គាត់ចេញទៅ ហើយខ្ញុំហ្នឹងមួយហើយមានមិត្តម្នាក់ទៀត ហើយម្នាក់ទៀតហ្នឹងខ្ញុំភ្លេចបាត់ហើយ ដល់ពេលអញ្ចឹងខ្ញុំថាឲ្យវាចេញទៅកាលណាបើវាមិនចេញខ្ញុំចេញព្រោះបើនៅជាមួយអញ្ចឹងខ្ញុំមិនឲ្យគេមកមើលងាយខ្ញុំទេ ។

ដានីៈ បាទ!

សែមៈ ដល់អញ្ចឹងខ្ញុំដើរៗទៅជួននឹងបងប្អូនហ្នឹងឈ្មោះគួយៗ ឥលូវគាត់ទៅកាណាដាហើយ ។

ដានីៈ ធ្វើការនៅណា?

សែមៈ គាត់នៅកាណាដា!

ដានីៈ អ៊ំ!

សែមៈ បាទគាត់ទៅប្រទេសកាណាដា គាត់បបួលទៅខ្ញុំដាច់ខាតអត់ទៅ ឲ្យខ្ញុំទៅបីដងដែរតែខ្ញុំអត់ទៅ ហៅទៅប្រទេសគេខ្ញុំមិនចេះនៅ ព្រោះខ្ញុំទីមួយវាអត់ចេះភាសាគេផង ហើយទីពីបើទៅអត់មានធ្វើអីទេមានតែធ្វើខ្ញុំកញ្ជះគេ ខ្ញុំមិនទៅតែម្តង ។

ដានីៈ បាទ!

សែមៈ វាមានចរិកមួយដូចថាមិនចូលចិត្តធ្វើខ្ញុំគេហ្នឹងបានអត់ទៅ ដល់ពេលអញ្ចឹងក្រោយម៉ោពូខ្ញុំនេះរកប្រពន្ធឲ្យ ប៉ុន្តែមុនរកប្រពន្ធខ្ញុំក៏និយាយប្រាប់គាត់ដែរថាមីងអើយពូអើយមានគេលើកកូនឲ្យខ្ញុំ ដល់អញ្ចឹងខ្ញុំវាឆោតមិនដឹងប្រាប់គាត់ថាម៉េចមានតែប្រាប់ត្រង់ចឹង អ៊ីបើគេលើកកូនឲ្យមែន! ហើយទៅពេលដែលខ្ញុំប្រាប់គាត់ៗថាអ៊ើអាណាគេ ស្អាតអត់ ហើយកូនចៅអ្នកណាអីអ្នកណើ ខ្ញុំថាទៅសួរកកូនចៅធ្វើអីយើងអ្នករត់ដូចតែគ្នា គ្រាន់ថាគេមានពូមានមីងដែរ អញអត់ឲ្យទេ ដូច្នេះចាំអញរកប្រពន្ធឲ្យវិញ គាត់សម្លឹងឃើញប្រពន្ធខ្ញុំរាល់ថ្ងៃហ្នឹងនៅជាមួយគាត់ចរិយាល្អ ចេះគោរពចាស់ទុំ ចេះធ្វើការងាររមាំមួនអញ្ចឹងម៉ោគាត់ក៏ទុកដាក់ឲ្យខ្ញុំ តែខ្ញុំអត់ស្គាល់គេទេ អត់មានបានទាក់ទងស្នេហាអីពីមុនម៉ោទេ គ្រាន់តែថាចាស់ឲ្យយកហ្នឹងក៏យកទៅតាម

មនុស្សចាស់ មុនដំបូងប្រកែកទៅតែដល់ពេលប្រកែកមិនឈ្នះគាត់ក៏ថាអញ្ចឹងស្រេចតែពូទៅចឹង ចុះបើយើងមនុស្សស្រីស្រលាញ់ច្រើន ហើយយើងក៏នៅឆោតច្រើន ដល់ពេលប្រកែកជាមួយគាត់ក៏គាត់ចេះតែប្រកែកទៅដល់ពេលគាត់ប្រកែកមិនឈ្នះយើងគាត់ក៏បន្ធូរវិញទៅ ដល់ពេលហើយគាត់ថាស្រេចតែឯង ដល់ពេលតែស្រេចតែឯងយើងវាអស់បង្គោលបាត់អញ្ចឹងតាមពូឯងទៅ ឲ្យខ្ញុំយកអាណាខ្ញុំយកអាហ្នឹង តាមចាស់ទុំទៅព្រោះអត់មានម៉ែឪហើយ ហើយមានតែគាត់ហ្នឹងទុកដូចជាម៉ែឪហើយ ដល់ហើយព្រមយកទៅ គេក៏មិនស្គាល់យើង យើងក៏មិនស្គាល់គេក៏យកទៅតាមដំណើរនៃជីវិតរបស់យើងទៅ ដូចគេថាកើតម៉ោត្រូវតែមានគូរ ៗ

ដានី: យើងការម៉េចទៅ?

សែម: ពេលមុនដំបូងហ្នឹងខ្ញុំមានទម្លាប់ល្អ ពេលហ្នឹងគេនៅមានរបៀបចរិកបដិវត្តន៍ដដែល នៅជុំហ្នឹងគេចងក្រងដោយចរិកកម្មុយនីសដដែល ត្បិតតែរត់ទៅតែគេចងក្រង មានលីម ៗ មួយថានៅសំឡូតហ្នឹងគាត់ទៅកាន់ប្រធានជុំហ្នឹងគាត់ចេះថៃផងហើយគាត់ទៅកាន់ជុំហ្នឹងហើយគាត់នៅតែរបៀបកុម្មុយនីសដដែល ហើយគិតគូរឲ្យដណ្ដឹង ឲ្យធ្វើរៀបចំធ្វើប្រវត្តិរូបតែដីគេទណ៌ឲ្យធ្វើប្រវត្តិរូបធ្វើអីហ្នឹងចូលដណ្ដឹងគេបានគេឲ្យ ដល់ពេលអញ្ចឹងខ្ញុំថាអេ៌..ដើរហត់ចុះហត់ឡើងហើយនៅធ្វើអញ្ចឹងទៀត ខ្ញុំថាខ្ជិលយកណាស់គ្រាន់តែយកប្រពន្ធប៉ុណ្ណឹងសោះដើរហត់ចង់ងាប់ ដល់ហើយគេថាឯងយកប្រពន្ធត្រូវតែហត់នឿយអញ្ចឹងហើយ ទម្រាំតែបាននោះមិនមែនស្រួលទេ ខ្ញុំថាឯកសារមិនចេះត្រូវសោះ គ្រាន់តែនៅដីថៃប៉ុណ្ណឹងសោះឯកសារនោះឯកសារហើយសួរប្រវត្តិរូបលម្អិតវាចង់បានខ្លួនវាហ្នឹងឯងវាមិនចង់ឲ្យខ្ញុំទេ ខឹងជាមួយមីងពូ ដល់ហើយមីងពូនិយាយថាគ្មានទេឯងចេះតែខឹងគេ ហើយយើងមិនខឹងម៉េចហត់ចង់ងាប់ម្ដងអត់ត្រូវពីដងអត់ត្រូវបីដងអត់ត្រូវហើយ ដល់ហើយគាត់លួងលោមថាទៅម្ដងទៀតទៅហើយខ្ញុំថាបាទ ៗ យើងទៅតែឯង យើងយកឯកសារទៅតែឯងវាអត់មានមនុស្សចាស់ទៅអមគេចង់បានមនុស្សចាស់ទៅអម បានខ្ញុំទៅលើកក្រោយខ្ញុំឲ្យមនុស្សចាស់ម្នាក់ជួយដូចថាទៅដណ្ដឹងគេអញ្ចឹងណ៌បានគេឲ្យ ចុះអ្នកណាដឹងកាលណ្ហឹងយើងក្មេងមិនសូវបានអប់រំ ៗ

ដានី: កាលណ្ហឹងអាយុប៉ុន្មាន?

សែម: អាយុ២០ឆ្នាំ!

ដានី: អាយុ២០ឆ្នាំ?

សែមៈ បាទ!

ដានីៈ នៅក្មេងដែរអញ្ចឹង?

សែមៈ នៅក្មេង!

ដានីៈ ចុះដល់ពេលការយ៉ាងម៉េច?

សែមៈ ការខ្ញុំគាត់ធ្វើត្រឹមត្រូវ គាត់មានភ្លេង កាលណ្ហឹងគេបើកឲ្យការហើយ គេមានភ្លេង មានភ្លួង មានអាចារ្យហើយអាចារ្យខ្លួនគាត់អ្នកធ្វើអាចារ្យពូយេងហ្នឹងគាត់ធ្វើអាចារ្យឲ្យទៀតហើយមាន មិត្តភ័ក្ត្រជួយកាលនោះវាមានរបបសាច់មាន់ ក្នុងមួយរបបមានបីដុំអីចឹងទៅ ហើយមានបន្លែ ដល់នេះគេជួយៗយកមកធ្វើជាបន្លែហ្នុងទៅ ធ្វើជាម្ហូបធ្វើជាអីទៅបានរួចទៅ ការនោះអត់ មានអស់លុយអីច្រើនផង អាភ្លួងក៏គេជួយអស់៣០បាតហើយទ្រស្តយីកេអីហ្នឹងគេជួយខាងពូ ខាងពូគាត់ជួយដូចថាខាងពូគាត់ខ្លាំងដាង ហើយគេជួយខាងភ្លេងតាប៉ុយ ដល់ពេលអញ្ចឹងគាត់ ជួយគាត់ជួយទៅបានជាគូរស្រករហ្នឹងម៉ោរហូត ចូលឆ្នាំហើយការខែបីថ្ងៃទី៨ឆ្នាំ៨០អត់ទាន់ ចូលឆ្នាំទេណា៎ អត់ទាន់ដាច់ឆ្នាំខ្មែរទេ បានដល់ចូលឆ្នាំហើយខ្ញុំម៉ោនេះខ្ញុំអត់ទៅអាមេរិចទេខ្ញុំ គេចម៉ោនេះ ។

ដានីៈ ម៉ោណា៎?

សែមៈ ម៉ោពីស្រះកែវហ្នឹងមកចូលនៅថបភីក!

ដានីៈ ដីថៃ?

សែមៈ ដីថៃហ្នឹង ប៉ុន្តែចុះម៉ោដីយើងចុះតាមច្រកថបភីកហ្នឹង!

ដានីៈ ចុះម៉ោកន្លែងណា?

សែមៈ ចុះម៉ោកន្លែងខ្មែរយើងគេហៅថាចំការចេក ដល់ពេលហ្នឹងនៅតំបន់១០៧នេះ ខ្ញុំនៅកន្លែងនេះ គេដាក់លេខ១០៧ហ្នឹង!

ដានីៈ បាទ!

សែមៈ មានបងលីមួយ បងលីហ្នឹងគាត់ធ្លាប់ទទួលខុសត្រូវខាងផ្នែកកសិកម្មញហ្នឹង គាត់ក៏ដឹងថា ពូយេងម៉ោអញ្ចឹងទៅ!

ដានីៈ ម៉ោជាមួយពូ?

សែមៈ ហ្នឹងអើយម៉ោជាមួយខ្ញុំដែរ ដល់ពេលអញ្ចឹងគាត់មួយក្រុមគ្នាគាត់ហ្នឹងក៏គេទៅយកដូចថាមាន ខ្សែចីងណា៎ ម៉ោៗនៅនេះម៉ោពីចំការចេកម៉ោនៅនេះ ដើរកាត់ព្រៃកាត់ផុកហ្នឹងម៉ោតែយើង ខ្លួនមួយ ។

ដានី: ម៉ោនៅនេះគេហៅកន្លែងអីគេ?

សែម: នៅនេះគេហៅតំបន់១០២!

ដានី: តំបន់១០២?

សែម: បាទ! កាលហ្នឹងគេចែកដីគ្នាពីចំការចេកហ្នឹងទៅនោះទៅត្បូងនោះ ទីនោះគេហៅតំបន់៣២ ហើយនេះគេហៅតំបន់១០២ចែកគ្នាអញ្ចឹង នេះកងពល៤៥០ ហើយនៅនោះកងពលប៉ុន្មានទេខ្ញុំភ្លេចបាត់ហើយ៥៣អីក៏ប៉ុន្មានទេ ដឹកនាំលោកសុភាព ។

ដានី: ចុះឆ្នាំណាពូម៉ោដល់ហ្នឹង?

សែម: ឆ្នាំ៨០ហ្នឹងខ្ញុំការបាន៣ខែ!

ដានី: ពេលពូម៉ោដំបូងយ៉ាងម៉េចដែរ?

សែម: ម៉ោដល់ដំបូងសុទ្ធតែព្រៃសុទ្ធតែម្ដង!

ដានី: សុទ្ធតែព្រៃ?

សែម: សុទ្ធតែព្រៃឬស្សីអត់មានដើមចេកដើមអីទេ ឈើអីបន្តិចក៏គ្មានដែរ!

ដានី: អត់វាលស្រឡះអញ្ចឹងទេ?

សែម: គ្មានទេសុទ្ធតែព្រៃសុទ្ធ ព្រៃធំហ្មង! មើលអត់ឃើញភ្នំអត់ឃើញថ្ងៃអីទេវាស្លុបពីលើទាំងអស់អញ្ចឹង!

ដានី: ចុះពេលយើងនៅៗយ៉ាងម៉េចទៅ?

សែម: យើងនៅយើងកាប់ ចង់ហាលខោអាវអីយើងកាប់វាឲ្យវាលអញ្ចឹងហើយហាលទៅ ហាលខោអាវហាលស្ងួទៅហើយយើងចេះតែវាទទៗវាទៅណា ហើយនៅជាយដែនយើងហូបទឹកអូរហ្នឹងទៅយើងអត់មានទឹកណាំនៅនោះ យើងនៅតែជាយៗជិតមាត់អូរនោះតាមព្រំដែនហ្នឹងហើយចេះតែនៅៗទៅបានពេលបានខាងអ្នកដឹកនាំអត់ទាន់ឲ្យការទេ ដល់អញ្ចឹងមានប្រពន្ធតែខ្ញុំហ្នឹងឯងហើយគេមានជឿថាខ្ញុំមានប្រពន្ធពីណា នៅនេះអត់ទាន់មានអ្នកណាមានប្រពន្ធណាព្រោះគេអត់ឲ្យទាក់ទងគ្នាទេ ដល់ពេលឆ្នាំ៨១ចាប់ផ្ដើមកម្លាំងកងទ័ពនោះគាត់ខឹងគាត់ដូចថាគាត់ចង់បានប្រពន្ធហើយអត់ឲ្យគាត់មានប្រពន្ធហើយគាត់អាយុចាស់ៗហើយ ខ្លះបែកប្រពន្ធអញ្ចឹងទៅដូចបងភាពអីគាត់អត់មានប្រពន្ធដែរហ្នឹង កាលខ្ញុំម៉ោគាត់អត់មានប្រពន្ធណាគាត់មានប្រពន្ធដែរតែប្រពន្ធគាត់នៅខត្តនោះ បងផុនអីប្រពន្ធគាត់នោះហ្នឹងមានបាននៅនេះណា ឆ្នាំ៨១ហ្នឹងបានគេដឹកប្រពន្ធឲ្យគាត់ហ្នឹង ដឹកយកពីនោះមកឲ្យវិញហ្នឹង ការតស៊ូទម្រាំបានប៉ុននេះ ។

ដានី: ចុះដល់ពេលពូម៉ោដំបូងពូចូលធ្វើកងទ័ពតែម្ដង?

សែមៈ ខ្ញុំម៉ោមុនដំបូងធម្មតាវាអត់មានកម្លាំងប្រជាជនទេ យើងម៉ោដល់យើងត្រូវការពារខ្លួនរហូត អញ្ចឹងបានន័យថាយើងចូលដល់អន្តរភាពមួយគេហៅកងឈ្លប កងឈ្លបនៅអន្តរភាពឈ្លបហ្នឹង គឺកងរបស់តាម៉ុន ។

ដានីៈ តាម៉ុនណា?

សែមៈ ម៉ឺ សាម៉ុនយើងអធិការចាស់ហ្នឹង!

ដានីៈ អ៊ឺ!

សែមៈ ដូច្នេះនៅជុំវិញគាត់ដឹកនាំហ្នឹងគាត់មានបីកងធំ ហើយកងគាត់គឺថាព័ទ្ធតាំងពីនោះម៉ោដើម្បីការពារខ្លួន ហើយរក្សានៅតំបន់បន្ថែកដែលយើងរស់នៅសព្វថ្ងៃនេះឯង អញ្ចឹងហើយបានគិតទៅកម្លាំងទាំងអស់សុទ្ធតែកម្លាំងសាមគ្គី ប្រជាជនកម្លាំងអារឈើដើម្បីសាងសង់ជាមន្ទីរ សាងសង់ជារោងប្រជុំ ហើយអត់មានអ្នកណាទំនេរទេ ហើយប្រជាជនមួយចំនួនទៀតគេធ្វើខាងក្រុមសាធារណការ គេចាត់ជាក្រុមសាធារណកាគឺកម្លាំងហ្នឹងសម្រាប់គេប្រើតែម្តង ប្រើឲ្យអារឈើ ប្រើឲ្យធ្វើនេះធ្វើនោះ ហើយដូចកម្លាំងទំនេរដូចខ្ញុំដូចអីអញ្ចឹងគឺសុទ្ធតែកងទ័ពទេអត់មានប្រជាជនទេ ដែលបានកើតស្រុកម៉ាឡៃសព្វថ្ងៃដែលបានមានផ្ទះថ្មផ្ទះឈើរាល់ថ្ងៃនេះ..!

ដានីៈ ពូមានដឹងថាម៉ាឡៃយើងហ្នឹងកាលពីមុននៅក្នុងស្រុកណា ខេត្តណាទៅ?

សែមៈ ម៉ាឡៃនេះ?

ដានីៈ បាទ!

សែមៈ ម៉ាឡៃនេះពីដើមនៅជាប់ភ្នំម៉ក់ហឺន ភ្នំម៉ក់ហឺនហ្នឹងគេហៅភ្នំយល់សបិ្ត ក្នុងផែនទីគេហៅភ្នំម៉ក់ហឺនតែយើងនេះគេហៅភ្នំយល់សបិ្ត ហើយម៉ោដល់ភូមិម៉ាឡៃនេះអាភ្នំធំនេះគេហៅភ្នំវ៉ាងអាតូចម៉ោទាបនោះបានគេហៅភ្នំម៉ាឡៃ តែក្នុងជួរហ្នឹងភ្នំម៉ាឡៃទាំងអស់ ប៉ុន្តែដល់យើងវៃទៅយើងឃើញដើមឈើធំយើងដាក់ដើមវ៉ាង ប៉ុន្តែខ្ញុំមិនដឹងដើមស្អីឲ្យតែធំគេហៅវ៉ាង ទម្រាប់នៅស្រុកនេះជាង២៤ខេត្តក្រុងដែលម៉ោតាមរួមខេត្តទាំងអស់ម៉ោមូលគ្នាស្រលាញ់គ្នានេះណា៎អ្នកខ្លះនិយាយអញ្ចេះទៅអ្នកខ្លះនិយាយអញ្ចោះទៅ ខ្លះក៏ឈ្លោះគ្នាទៅជជែកគ្នាទៅ ខ្លះមិនដែលហូបសម្ផូរផ្លែចេកក៏ជជែកគ្នាថាអញមិនដែលឃើញ ហើយអាមួយទៀតគេហៅថាផ្លែត្របែក ហើយអាខ្លះទៀតគេហៅថាផ្លែស្អីៗទេគេសួរហូបតាមតែតំបន់គេមួយហើយដល់ម៉ោជួបគ្នាវល់តែជជែកគ្នាឈ្លោះតែគ្នា ចេះតែនិយាយថាអាណាគេដែលហៅអញ្ចឹង អាណាគេដែលហូបអញ្ចឹង ល្មមតែបាននៅជាមួយគ្នាស្រួលហ្នឹងពិបាកណាស់ ។ អញ្ចឹងហើយបានមនុស្សសព្វថ្ងៃដែលនៅចេះស្រលាញ់គ្នាព្រោះកន្លងម៉ោរឿងដែលឈ្លោះគ្នាជជែកគ្នាហើយវា

ម៉ោស៊ីបាយជាមួយគ្នានិយាយខុសគ្នារហូត ខ្ញុំនិយាយរដឹនក៏មានហើយចេះតែនិយាយផ្ទាញ់គ្នាហើយសើចអញ្ចឹងទៅ ហើយដូនកាលឈ្លោះគ្នាអញ្ចឹងទៅ បោកចំបាប់ ខ្ញុំរកវៃគ្នាអញ្ចឹងទៅដល់ពេលការអប់រំយូទៅបានយល់ទៅចេះតែនៅជាមួយគ្នាស្រលាញ់គ្នាទៅ មិនមែននៅបានស្រួលដែរទេណាំរត់ម៉ោនៅហ្នឹង ទម្រាំបាននៅស្រុះស្រួលគ្នាដូចថាផ្នែកកំពង់ចាមគេនិយាយផ្នែកកំពង់ចាមទៅ ផ្នែកកោះធំគេនិយាយផ្នែកកោះធំទៅ ខាងពួកកំពង់ឆ្នាំងគេនិយាយផ្នែកកំពង់ឆ្នាំងទៅ គេយកតាមស្រុកគេដូចថាផ្នែកកំពង់ស្ពឺខាងកំពង់ស្ពឺ ខាងកំពតខាងកំពត ហើយនិយាយម៉ោផ្សេងនេះខាងបញ្ចឹម ហើយម៉ោខាងបាត់ដំបងនេះគេនិយាយផ្សេងទៅ ហើយម៉ោអន្លុង់វែងនេះគេនិយាយផ្សេងទៀតទៅ ។

ដានី: ចុះម៉ាជំនៀរម៉ាឡៃហ្នឹងនៅក្នុងស្រុកកាលមុនយើងមកនៅ?

សែម: ពីមុនដូចនៅបាត់ដំបងដែរ ព្រោះបាត់ដំបងគេយកម៉ោពីនេះទាំងអស់គេភ្ជាប់ពីប៉ោយប៉ែតម៉ោបើសិនជាតាមទម្លាប់ខ្មែរក្រហមពីមុនគេហៅថាស៊ីសុផុនខាងត្បូង ហើយបើទៅខាងផ្លូវជាតិលេខ៥គេហៅស៊ីសុផុនខាងជើងគេចែកគ្នាម្នាក់មួយផ្លូវ ហើយខ្ញុំអត់ដឹងថានៅស្រុកណាទេដល់ពេលខេត្តមានជ័យបង្កើតម៉ោបានគេចំនុះចូលខេត្ត កាលពីមុនគេហៅស៊ីសុផុនខាងជើងអាហ្នឹងជាទម្លាប់ខាងខ្ញុំណាំ ។

ដានី: កាលពីមុនម៉ោសុទ្ធតែព្រៃ?

សែម: ព្រៃ! កាលពីមុនមានតាថៅកែយ៉មួយដែលកាប់ព្រៃជួញទៅថៃនោះដែលគេហៅថាផ្ទះថៅកែយ៉ៗនោះ គាត់កាប់ដើមឈើធំៗប៉ុនៗពាងនេះគាត់ដឹកយកទៅថៃនោះហើយខ្ញុំវាមិនដឹងដែរទេតែឃើញរត់ម៉ោហ្នឹងចូលម៉ោក្នុងព្រៃហ្នឹងឃើញដើមឈើវាដួល ហើយគេតាំងនាមថាតាថៅកែយ៉ហ្នឹង កាលជំនាន់ហ្នឹងវាមានអ៊ុន តាំម៉ោដីហ្នឹងណាំ!

ដានី: អ៊ុន តាំ?

សែម: ហ្នឹងអើយអ៊ុន តាំម៉ោហ្នឹងគាត់មកនៅជ្រកក្រោមព្រៃតាថៅកែយ៉ហ្នឹង ។

ដានី: កាលជំនាន់ណាហ្នឹង?

សែម: ជំនាន់វៃបែក៧៩ហើយគាត់មកនៅហ្នឹងហើយយើងអត់ដឹងទេ ហើយខ្ញុំក្តីតាមគេទេអាហ្នឹងតែអារឿងដូចថាអូពិលអីហ្នឹងសុទ្ធតែពួកខ្ញុំអ្នកដាក់ទេ អូរពិល អូរខ្វង អូរស្រម៉ោច បឹងស្រម៉ោច បឹងខ្វង ភ្នំវែង ភ្នំខ្ទីអីហ្នឹងអាហ្នឹងសុទ្ធតែនាមរបស់ពួកយើងដាក់ថ្មីហ្នឹង ។

ដានី: ទើបតែថ្មីៗនេះទេ?

សែម: បាទ!

ដានី៖ ចុះគេថាភ្នំអីគេ....?

សែម៖ ភ្នំទឹកចេញ!

ដានី៖ ភ្នំទឹកចេញពីរូង?

សែម៖ អាហ្នឹងទើបតែដាក់នាមក្រោយនេះទេ អាហ្នឹងសុទ្ធតែទំនៀមទម្លាប់បុរាណទេព្រោះយើងដើរកាត់ទៅឃើញទឹកវាចេញ តែដូរភ្នំម៉ាខ្លៃតែមួយទេ!

ដានី៖ ដូរភ្នំម៉ាខ្លៃ?

សែម៖ បាទ! ហើយភ្នំរូងនោះវាមានរូង ពីមុនគេហៅភ្នំបឹងត្រគួនដល់យួនចូលម៉ោទៅគេចោះអាភ្នំហ្នឹងធ្វើជារូងបានគេដាក់ភ្នំរូងវិញ ពីមុនគេហៅភ្នំបឹងត្រគួន អតីតវាអញ្ចឹង ។

ដានី៖ ឈ្មោះភ្នំមួយចំនួនយើងដាក់ឈ្មោះខ្លួនឯង?

សែម៖ យើងបង្កើតក្រោយនេះទេ!

ដានី៖ ចុះភូមិដូង?

សែម៖ ភូមិដូងហ្នឹងពីដើមឡើយទាំងអស់នេះគេហៅភូមិដូង ប៉ុន្តែភូមិមានដូងម៉ោពីណាយកដើមដូងពីដីថៃយកមកដាក់ឈ្មោះទេ វាជាប់ពីដីថៃទេថាអាហ្នឹងភូមិដូង យើងមានដូងណាមួយដើមដល់ពេលយើងនៅហ្នឹងយើងចែកថាមួយកាណាត់នោះភូមិដូង ហើយអានោះភូមិបាតស្ពានវាមានស្ពានមួយ អានោះភូមិកណ្ដាលវានៅកណ្ដាលគេ ហើយអានោះភូមិថ្មីទើបបង្កើតក្រោយៗចឹងទៅ ។

ដានី៖ ចុះវាលរហាត់?

សែម៖ វាលរហាត់ហ្នឹងអញ្ចេះប្រវត្តិវាលរហាត់ចាំខ្ញុំនិយាយប្រាប់ឲ្យប្អូនយល់ថា វាលរហាត់ហ្នឹងពីមុនមូលហេតុអីបានគេហៅវាលរហាត់ វាលហ្នឹងមិនមែនវាលរហាត់ទេណា៎វាលហាត់!

ដានី៖ វាលហាត់?

សែម៖ បាទមិនមែនវាលរហាត់ទេ! វាលហាត់ហ្នឹងគឺកងទ័ពហាត់ អាកន្លែងដីហ្នឹងគឺដីល្បាយខ្សាច់ដោយសារពេលនោះយើងអត់មានកន្លែងណាហាត់ទេ ហើយកន្លែងជាកន្លែងទ័ពគេថាហាត់ គេឯកភាពដូចថាហាត់ជារបៀបកងឈ្លប កងប្រយុទ្ធ ដល់អញ្ចឹងគេហាត់នៅកន្លែងហ្នឹងបានជាកើតវាលហាត់ហ្នឹងមិនមែនវាលរហាត់ទេសូមជំរាបឲ្យច្បាស់ថាវាលហាត់ ។

ដានី៖ ហាត់ឆ្នាំណា?

សែម៖ ហាត់នៅឆ្នាំ៨១,៨២,៨៣ ហើយពេលនោះមានគ្រូបង្ហាត់ម៉ោពីចិន គ្រូបង្ហាត់ហ្នឹងខ្មែរយើងទៅរៀនជាមួយបាទបីឆ្នាំហ្នឹង គេទៅរៀនដល់ទៅរៀនក្រោយម៉ោគេចេះតែឲ្យម៉ោស្រុកវិញ

ម៉ោ ត្រូវធហ្នឹងគាត់ហាត់ខាងបច្ចេកទេសដូចជាចាប់ខ្មាំង ចាប់ចងខ្មាំងអញ្ជឹងទៅណា៎ គេហាត់របៀបយោធាប្រយុទ្ធអស់គ្រាប់កាំភ្លើងត្រូវចាក់ចំពុះទង់ម៉េច ត្រូវការពារខ្លួន ។

ដានីៈ អញ្ជឹងកន្លែងនោះវាលហ្មង?

សែមៈ វាល កន្លែងវាលខ្សាច់នោះដូចថាវាមានអាសីខាងទៅវាមានវាល មានវាលទៅយើងកាប់វាថែមទៀតដើម្បីឲ្យវាវាលកាន់តែធំ ហើយមានរៀនបាញ់កាំភ្លើង រៀនផ្ទុះគ្រាប់បែក រៀនចាប់ខ្មាំងសត្រូវរបៀបអត់ខ្សែ របៀបចងជាល្បិច!

ដានីៈ គេហៅវាលហាត់អញ្ជឹង?

សែមៈ បាទ!

ដានីៈ ឆ្នាំ៨០ ម៉ោ?

សែមៈ បាទឆ្នាំ៨០ ម៉ោ!

ដានីៈ ចុះភូមិដូងហ្នឹងតាំងពីហ្នឹងម៉ោដែរ?

សែមៈ ភូមិដូងហ្នឹងគេយកដីថៃទេ យកឈ្មោះពីដីថៃពីចំការតាសៅព្រោះវាដើមដូងច្រើន ដល់អញ្ជឹងយើងយកចំនុចហ្នឹងម៉ោដាក់នេះ យកចំនុចគេទេយកមកដាក់ឈ្មោះហ្នឹង!

ដានីៈ ចុះគេហៅតាំងពីអន្កាល់?

សែមៈ ហៅតាំងពី៨០ ដែរ!

ដានីៈ ចុះក្បាលស្ពាន?

សែមៈ ក្បាលស្ពានយើងទើបតែដាក់ទេព្រោះយើងទើបកសាងនៅឆ្នាំប៉ុន្មានទេភ្លេចបាត់ហើយ!

ដានីៈ មុនសាមារន្ទកម្មឬក៏ក្រោយ?

សែមៈ មុន! មុនហើយយើងចែកភូមិក្បាលស្ពានហ្នឹងយើងយកគោលអីមួយៗហ្នឹងចឹងទៅណា៎ភូមិមួយៗ ។

ដានីៈ យូហើយឬក៏មិនសូវយូទេ?

សែមៈ សាមារន្ទកម្មនៅឆ្នាំ៩៦នេះតើ!

ដានីៈ តែដែលគេហៅភូមិក្បាលស្ពានហ្នឹងហៅតាំងពីមុនហ្នឹងយូហើយ?

សែមៈ អត់ទេទើបតែក្រោយដែរតែខ្ញុំអត់ចាំ!

ដានីៈ ចុះពូកណ្តាល?

សែមៈ អញ្ចេះទើបតែសាមារន្ទកម្មហើយទេចាត់តាំងហ្នឹងណា៎!

ដានីៈ ប៉ុន្តែគេហៅដូចថាក្បាលស្ពាន...?

សែមៈ ទើបចាត់តាំងក្រោយម៉ោទេ សាមារទ្ធកម្មហើយយើងចែក យើងចែកជាភូមិដើម្បីងាយស្រួលក្តាប់មិនមែនមុនទេ ក្បាលស្ពានហ្នឹងយើងហៅរួមពីមុនហ្នឹងហៅភូមិដូងទាំងអស់ នៅម៉ាភូមិម៉ាខ្សែហ្នឹងគេហៅភូមិដូង ដល់ពេលសាមារទ្ធកម្មរួចហើយបានយើងចែក យើងចែកឲ្យវាស្រួល ។

ដានីៈ អញ្ចឹងម៉ាខ្សែហ្នឹងដំបូងគេហៅភូមិដូង?

សែមៈ បាទ!

ដានីៈ ដល់ក្រោយម៉ោគេចែកជាថី?

សែមៈ បាទ!

ដានីៈ ដូចថាកន្លែងម្តុំនេះវាលហាត់អញ្ចឹងដាក់វាលរហាត់ទៅ ម្តុំក្បាលស្ពានដាក់ក្បាលស្ពានទៅហើយភូមិដូងពីមុនម៉ោរួមតូចទៅ?

សែមៈ នៅមានដែរពួកភូមិដូងនៅចែកនោះ រំលងមួយផ្លូវចេញពីក្បាលស្ពានទៅខាងត្បូងហ្នឹងគេហៅភូមិដូង ហើយម៉ោនេះមួយផ្លូវងាកទៅខាងនេះគេហៅភូមិកណ្តាល ។

ដានីៈ ភូមិកណ្តាលហ្នឹងដោយសារវានៅកណ្តាលគេ?

សែមៈ បាទ! ភូមិឬស្សីជ្រូកវានៅជាប់មាត់អូរអានេះកណ្តាល! ដល់វានៅកណ្តាលដាក់កណ្តាលហ្នុង!

ដានីៈ ចុះឬស្សជ្រុំ?

សែមៈ ឬស្សីជ្រុំពីមុនវាសំបូរដើមឬស្សី ដល់សំបូរអញ្ចឹងទៅគេហៅឬស្សីជ្រុំ ដល់ហៅលេខៗពីមុនគេហៅក“១៥”ទេ ក“១៥”ហ្នឹងអ្នកដឹកនាំនៅនេះជាអ្នកដាក់ទេ ក“១៥”កន្លែងអ្នកពិការកន្លែងប្រពន្ធខ្ញុំដាំបាយឲ្យអ្នកពិការហូបនៅហ្នឹង តែក្រោយម៉ោយើងដាក់ថាឲ្យវាច្បាស់ថា ឲ្យវាមានឈ្មោះរបស់វាឲ្យច្បាស់ទៅក៏ដាក់ឬស្សីជ្រុំទៅ ហើយដំបូកវិលនោះអតីតដំបូកហ្នឹងកងទ័ពដូចថាកន្លែងស្នាក់របស់កងទ័ព ហើយដល់អញ្ចឹងកងទ័ពហ្នឹងគាត់អត់ការងារធ្វើគាត់នៅយាមកន្លែងផងគាត់ធ្វើចង់ឲ្យស្រីៗអង្គុយលេងដែលដឹកជញ្ជូនទៅម៉ោវិញចង់អង្គុយលេងគាត់ធ្វើរានពីអាសីព្រោះកន្លែងហ្នឹងអាសីហើយមានដំបូកមួយធំ ដល់អញ្ចឹងគាត់យកអាចបហ្នឹងកាប់ធ្វើជាជណ្តើហើយអង្គុយលេងហើយដាក់ពាងទឹកមួយដើម្បីនារីដឹកជញ្ជូនហ្នឹង
ធម្មតាមនុស្សប្រុសយើងចង់ញ៉ែស្រីធ្វើទាក់ទងទាក់ទាញម៉េចឲ្យអ្នកដើរហ្នឹងមកអង្គុយលេងហ្នឹងទៅបាននិយាយគ្នាលេងណាំព្រោះពេលនោះគេអត់ចង់ឲ្យនិយាយគ្នាទេ ដល់អញ្ចឹងកងទ័ពហ្នឹងគាត់ចេះតែកាប់ម្តងបន្តិចៗយូៗគាត់កាប់ឡើងមូលអាដើងដំបូកហ្នឹងគាត់កាប់ឡើងមូលហើយ

កាប់ទម្លាក់អញ្ចឹងម៉ោហើយបានគេហៅដំបូកវិល  ហើយដល់ពេលក្រោយម៉ោយើងចង់ដាក់ភូមិហ្នឹងដាក់ភូមិដំបូកវិលតែម្តងទៅ  ពីមុនពីឆ្នាំ៨១ហ្នឹងដំបូកវិលកើតនៅឆ្នាំ៨១ហ្នឹង ។

ដានីៈ ពេលដាក់ឈ្មោះពេលសាមារន្ទកម្មហើយ?

សែមៈ បាទ! ដាក់ឈ្មោះហ្នឹងក៏យកដំបូកវិលហ្នឹងទៅភូមិដំបូកវិលហ្នឹងទៅ!

ដានីៈ ចុះភូមិវត្តចាស់?

សែមៈ ភូមិវត្តចាស់គឺវត្តចាស់!

ដានីៈ បង្កើតពីអង្កាល់?

សែមៈ ឆ្នាំ៨២យើងបង្កើតវត្ត!

ដានីៈ បាទ! ហើយវត្តអត់មានព្រៃទេ?

សែមៈ អត់ទេវាលអស់ហើយយើងកាប់វាលអស់ហើយកាលហ្នឹង  កាប់វាលរហូតម៉ានៅហ្នឹង  តែនៅនោះទេនៅព្រៃ  តែដោយយើងបង្កើតវត្តហ្នឹងដោយសារអី  កាលនោះយើងចចារគ្នាពីទីក្រុងប៉ារីសដែលរឿងកៅអី ដល់អញ្ចឹងយើងត្រូវការឲ្យប្រជាជនយើងកែប្រែដាកម្មុយនីស ។

ដានីៈ ចចារឆ្នាំណា?

សែមៈ ចចារឆ្នាំ៩២!  ឆ្នាំ៨២ហ្នឹងមិនមែនចចារជាមួយខាងនេះទេណា៎  មិនមែនរដ្ឋាភិបាលទេណា៎ ចចារដើម្បីយកកៅអីគឺឆ្នាំ៨២  ដែលបោះឆ្នោតនៅតំនាងសហប្រជាជាតិគាំទ្រខ្មែរក្រហមឆ្នាំ ៨២  ហើយកៅអីរបស់ខ្មែរក្រហមនៅដដែល  ហើយដល់អញ្ចឹងសម្តេចកាលហ្នឹងស្ពាននៅនោះទេ  ខ្ញុំទទួលសម្តេចនៅឆ្នាំ៨២ហ្នឹងឯង!  ៨២សម្តេចគាត់ម៉ោ  ហើយវត្តយើងបង្កើតវត្តនេះដើម្បីឲ្យយើញមានស្តេចដងហើយយើងលុបកម្មុយនីសចោលខ្លះលែងមានបក្សលែងមានអីទៀតហើយយើងកម្ពុជាប្រជាធិបតេយ្យតែអត់មានបក្សមានអីទៀតទេ  ដូច្នេះវត្តនេះកកើតកាលហ្នឹង  ដល់អញ្ចឹងកកើតវត្តហើយ  សម្តេចលោកបានយាងទៅដល់វត្តហ្នឹងគាត់បានបញ្ចុះសីមាទៀតវត្តចាស់ហ្នឹងណា៎  បានរហូតគេហៅថា  រួចដល់យើងចូលម៉ោម្តងទៀតយើងចេញម្តងហើយពេលគេធ្វើហើយយើងចេញដែលយួនដេញពួកខ្ញុំទៅនៅដីថៃនៅឆ្នាំ៨៥
ខ្ញុំទៅនៅដីថៃ  ដល់ទៅនៅដីថៃម៉ោវិញនៅឆ្នាំ៩០នេះខ្ញុំម៉ោវិញដល់អញ្ចឹងទីតាំងវត្តនេះវាត្រូវរលាយអស់ហើយ  អញ្ចឹងដូច្នេះទីតាំងវត្តនេះដែលបងប្អូនធ្លាប់គោរពហ្នឹងក៏គេចង់វិញ  ចង់យកធ្វើវិញ  ប៉ុន្តែពេលដែលយើងម៉ោហ្នឹងចេះតែយកដីជុំវិញហ្នឹងចង់អស់ហើយដល់ពេលអញ្ចឹងគេថាអាវត្តនៅសព្វថ្ងៃនេះវត្តម៉ាឡៃនេះកន្លែងហ្នឹងវាមានទីតាំងធំដល់អញ្ចឹងវាទូលាយ  ដល់ទូលាយអញ្ចឹងទៅគេខាងអាចារ្យខាងឧបាសកឧបាសិកាដែលគេអ្នកចេះដឹងខាងពុទ្ធសាសនា

គាត់ថាយកទៅដាក់ហ្នឹងទៅវាស្រឡះ ហើយឯកភាពគ្នាវាទៅផុតពីភូមិឆ្ងាយបន្តិចដើម្បីយកទីលានវត្តឲ្យធំណាក៏ទៅដាក់ហ្នឹងទៅបានគេហៅភូមិវត្តចាស់នេះ ។

ដានី: កាលពីមុនម៉ោវត្តហ្នឹងមានលោកមានអីទេ?

សែម: មានលោកក្រោយពី៨៥ហ្នឹងដែលត្រូវយួនវៃពួកខ្ញុំខ្ចាតទៅនោះទៅ ខ្ញុំក៏នៅនោះទៅវត្តហ្នឹងក៏គ្មានហើយលោកមិនលោយ ។

ដានី: កាលនោះមានលោកច្រើនទេ?

សែម: លោកកាលនោះគ្រាន់ថាមានគេគោរពមិនទាន់មានអ្នកណាបួសច្រើនទេ លោកមាន៥អង្គ ។

ដានី: លោកហ្នឹងយើងអ្នកនៅក្នុងហ្នឹងអ្នកបួសឬក៏....?

សែម: យើងនៅក្នុងហ្នឹងអ្នកបួស! បើអ្នកណាស្ម័គចិត្តបួសក៏បួសទៅ អ្នកណាធ្លាប់បួសក៏ទៅបួសហើយពេលនោះក៏ខ្ញុំចាំមិនអស់ដែរ នេះកន្លែងទីតាំងចាស់ដែលខ្ញុំថត នេះជិះម៉ូតូនេះ!

ដានី: អញ្ចឹងចន្លោះឆ្នាំ៧៩,៨០,៨១,៨២,៨៣,៨៤,៨៥ហ្នឹងកាលហ្នឹងយ៉ាងម៉េចដែរការរស់នៅរបស់យើងមានលក្ខណៈដូចជា ភូមិ ស្រុក ប្រជាជនអីយ៉ាងម៉េចដែរដូចថាគេបង្កើតវត្តចាស់អីដូចពូរៀបរាប់មេញណា កាលនោះយើងរស់នៅជារបៀបកងទ័ពឬក៏របៀបប្រជាជន?

សែម: ពេលនោះមានរបៀបប្រជាជនខ្លះហើយភាគច្រើនកងទ័ព ប៉ុន្តែយើងមានប្រជាជនហ្នឹងយើងបង្កើតដូចថាបងប្អូនម៉ោពីត្បូងខ្លះ ម៉ោពីខត្តរខ្លះ ម៉ោពីខត្តរអញ្ចឹងទៅមានមនុស្សចាស់ចាត់ទុកថាគាត់ជាប្រជាជនធម្មតាទៅព្រោះគាត់ចាស់ហើយ!

ដានី: បាទ!

សែម: ហ្នឹងអើយ! មានចាស់ៗតិចណាស់ ប៉ុន្តែឥលូវនេះបើជិនាន់ខ្ញុំវិញវាច្រើនណាស់ រកកន្លែងចូលវត្តតូចតាចហ្នឹងចូលណែនអស់ហើយ អានេះដល់ស្រុកខ្ញុំចូលវត្តវិញ ប៉ុន្តែរាល់ថ្ងៃនេះអង្គុយអត់ឈប់ទេ!

ដានី: ប្រហែលជា៥ឆ្នាំ!

សែម: អត់ទេរយៈពេល១០តទៅមុខ ១៥ឆ្នាំទៀតអានោះគ្មានទេ និយាយទៅតែ១០ឆ្នាំទៀតបានហើយព្រោះ១០ឆ្នាំទៀត៦០ហើយ!

ដានី: ចុះពូកាលជំនាន់នោះយើងមានផ្ទាំងដែលយើងធ្វើផ្ទះឬក៏យ៉ាងម៉េចដែរ កាលពីជំនាន់ឆ្នាំ៨០, ៨១,៨២?

សែម: ធ្វើពីសរសរមូល ពេលនោះយើងកាប់សរសរដើមអីក៏ដោយ យើងអត់មានប្រកាន់ដើមអីជាដើមអីទេ ហើយយើងចង់ដឹងថាការរស់នៅគឺវាច្រើនដើមរងៀង ដើមកូនស្រឡៅតូចៗប៉ុនៗ

ភ្លៅទេណ៎ហើយលុញជាដុំមូលហើយយើងយកមកបកស្របកវាទៅ ហើយអាកូនឈើដែរតូចមូលទាំងអស់យើងយកមកវៃអញ្ចឹងទៅយើងគងៗដាក់គ្នាអញ្ចឹងទៅ ពេលមុនដំបូងអត់មានដែកគោលទេចងលាក់ហើយចង យកផ្តៅចង វល្លិ៍គេចងខាងលើអាក្រោមគេចងផ្តៅព្រោះផ្តៅវាជាប់ គេចងទម្លាក់វា ទម្លាក់ដាក់ទៅភ្ជឹប អាចងវាមានអីសំខាន់ៗអាលាក់នោះ កុំឲ្យវាគំលាតចេញពីគ្នា ដល់អញ្ចឹងទៅយើងលាក់វាពាក់កណ្តាលទៅអានោះគេលាក់ដែរម៉ោចូលគ្នាភ្ជឹប ក្រោយម៉ោគេយកដែកដើងមីន ដែកដើងមីងហ្នឹងអូនដែលឃើញទេ?

ដានី: អត់!

សែម: ដែកដើងមីនគឺមីនរបស់ចិន ពេលហ្នឹងមីនចិនគេម៉ោមានតាំងពីមីនហើយគេឆ្លុកវាហើយវៃជាប់នឹងដី តែហើយគេយកដើងមីនយកមកកាត់វាធ្វើជាដែកគោល កាត់ប្រវែងនេះម៉ោវៃ ជូនគេកាត់ឲ្យវែងជួនគេកាត់ឲ្យខ្លីហើយគេវៃវា តែអានៅលើតូចៗហ្នឹងចងដដែល ។

ដានី: កាលហ្នឹងផ្ទះតូចៗល្មមទេ?

សែម: ល្មមៗ៤ម៉ែត្រ៤ជ្រុងអញ្ចឹងទៅ ៣ម៉ែត្រ ៤ម៉ែត្រ ២ម៉ែត្រទៅ៣ម៉ែត្រ ចុះខ្ញុំម៉ោមានទាន់មានកូនណាដេកមានតែពីរនាក់ប្តីប្រពន្ធ យើងអត់មានអីត្រូវធំដុំណា គេថានៅស្បែងមួយតូចណ៎វាអត់ទាន់មានស្បែងធំទេណា!

ដានី: ធ្វើនៅតាមផ្ទះយើងរាល់ថ្ងៃឬធ្វើនៅតាមកន្លែងណាផ្សេង?

សែម: ពីដើមវាអញ្ចេះវាចែកកាលពីមុនមិនមែនផ្លូវនេះទេផ្លូវខាងនោះកាលមិនទាន់រត់នោះណ៎ ផ្លូវវាខាងនោះដល់ពេលអញ្ចឹងភូមិវាចាក់ម៉ោខាងនេះ នៅជិតមាត់អូរវាអត់ឆ្ងាយទេព្រោះយើងជីកអណ្តូងអត់ចេញទេយើងប្រើទឹកអូ កាលណាទឹកអូរនៅឆ្ងាយពេកយើងអត់ងាយរែកទេ អញ្ចឹងនាំគ្នារស់នៅតែជិតមាត់អូរទេ កន្លែងនេះសុទ្ធតែព្រៃ ដល់ពេលយើងចេះតែរីករាលដាលបន្តិចៗទៅយើងចេះតែទាក់ទងទៅថៃអញ្ចឹងទៅដូចដែកគោលអញ្ចឹងអីយកមក ហើយយើងចេះអារឈើលក់អញ្ចឹងទៅបានលុយហ្នឹងទិញដែកគោល ទិញអាណារ មុនដំបូងអ្នកដែលចេះធ្វើទ្រូក្រងបិទអាសីហើយលក់ឲ្យថៃ អ្នកចេះលក់ទ្រូធ្វើទ្រូ អ្នកលក់កៅអីធ្វើកៅអីទៅ ហើយគេចេះបច្ចេកទេសអញ្ចឹងទៅយកទៅលក់កៅអីអញ្ចឹងទិញជាសំពត់ ក្រម៉ាអត់ជាយ ហើយក្រម៉ាអត់ជាយគឺក្រម៉ាដែលអត់ជាយ យល់ក្រម៉ាអត់ជាយទេ?

ដានី: បាទ!

សែម: ហ្នឹងអើយក្រម៉ាល្អិតជួនកាលយកមកបង់អញ្ចឹងទៅស្រីៗ ដល់អញ្ចឹងទៅប្រុសៗចេះតែរកថ្នេប្រឌិតហើយដើម្បីឲ្យស្រីៗស្រលាញ់ទាល់តែខំធ្វើវិធីដូចជាបាញ់សត្វយកសត្វទៅលក់ ដាក់

អន្ទាក់យកសត្វទៅលក់បានគូរមួយអញ្ចឹងទៅយកទៅលក់ហើយគ្មានដឹងថាអ្វីជាអ្វីទេ អ្វីដែលខាតដែលចំនេញអីអត់ដឹងទេ!

ដានី: យើងលក់ហ្នឹងយកដីទុកខ្លួនឯង?

សែម: បាទ! យើងធ្វើបានយើងយកទៅលក់ បើយើងធ្វើរួមដាក់ជារួមបើយើងធ្វើជាឯកជនដាក់ជាឯកជន បើយើងពីរនាក់ទៅដាក់អន្ទាក់កាប់ចំការអីបានអញ្ចឹងយើងលក់ទៅចែកគ្នាទៅ ទិញជាពិលប្រើ ទិញម៉ាញ៉េស្លាប់ អ្នកអារឈើបានដូចថាពួកអា៤៥,៦២ហ្នឹងម៉ាញ៉េវាស្អាតៗណាស់ គេអាចធ្វើអញ្ចឹងបានគេធ្វើអញ្ចឹងទៅ គេធ្វើក្តាធៀបានមួយម៉ែត្រអីអញ្ចឹងទៅគេលក់បានមួយចឹងទៅ អាហ្នឹងវាចេះតែរីកទៅៗអញ្ចឹងហើយវាអត់មានរួមទេវារីកទៅពេលនោះវាធ្វើម៉េចដឹងតែឲ្យបានរស់ហើយឲ្យបានស្រួល តែរឿងបង្ហិនទ្រព្យសម្បត្តិជាតិអត់គិតទេ ពេលនេះយើងអត់មានគិតអីទេមែនដូចឥលូវយើងថែរក្សាព្រៃឈើថែរក្សាសត្វព្រៃអត់ទេ ផាកបន្តិចទៅព្រៃ ផាកបន្តិចទៅសត្វៗ

ដានី: អញ្ចឹងស្រួលដែរ!

សែម: កាលជំនាន់នោះគ្មានចេកគ្មានអំពៅស៊ីទេ បើប្រពន្ធឃ្លានម្ទូរដូចប្រពន្ធខ្ញុំឃ្លានអំពិលដើរតាំងពីរផ្ទះនៅនោះមកដល់នេះហើយទាក់ទងទៅថៃទម្រាំតែបានអំពិលយកទៅឲ្យគាត់ហូប ព្រោះយើងមានដើមអំពិលម៉ោពីណាយើងមានតែផ្លែឈើ បើថាម្ទូរមានតែស្លឹកថ្មីងដល់ពេលឃ្លានអំពិលយើងពិបាកហ្មង តែបើថាម្ទូរល្មមម្ទូធម្មជាតិដែលមានអាហ្នឹងយើងរកបាន!

ដានី: ដូចជាស្វាយអីហ្នឹងមែនពូ?

សែម: អត់មាន!

ដានី: មានតែថៃ?

សែម: ថៃកាលហ្នឹងក៏ថៃក្រទាក់ទងគ្នាអត់បានទេ! យើងមិនឆាយទៅទាក់ទងគ្នាផ្ទេះផ្ទាស ទីមួយអត់ចេះភាសាគេ!

ដានី: ចុះកាលហ្នឹងដូចជាម្ហូបអាហារ ដូចជាអង្ករ ដូចជាម្ហូបអីយើងបានម៉ោពីណាម៉ោ?

សែម: ម្ហូបហ្នឹងគឺជំនួយ អាហ្នឹងគេហៅខាងអង្គការជួយ!

ដានី: កាកបទក្រហម?

សែម: បាទ! អង្គការគាត់ជួយឬអ្នកដឹកនាំ ខ្មែរក្រហមហ្នឹងគេរកឲ្យ ហើយយើងដឹងតែពីទៅវ៉ៃ ទៅប្រយុទ្ធទៅមានសភាពការណ៍អីសួគេទៅ ហើយពេលហ្នឹងមានជប៉ុន មានចិន មានបារាំងអី

ម៉ោ ម៉ោរឿយម៉ោតាំងពីឆ្នាំ៨០ ម៉ោចេះតែសួនាំដូចអូនឯងមកសួនាំខ្ញុំអញ្ចឹង ដើរកាត់ព្រៃកាលនោះមានដំរីជូនភ្ញៀវជូនអីអញ្ចឹងណា៎ចេះតែដើរទៅៗ ។

ដានីៈ ចុះដំរីទៅណាអស់ទៅ?

សែមៈ ដំរីងាប់អស់ហើយ វានឿយហត់វាដែរ!

ដានីៈ បាទ!

សែមៈ ដំរីបានជូនដល់សម្ដេចដល់អីដែរ!

ដានីៈ ដំរីច្រើនក្បាលដែរពូ?

សែមៈ ដំរីកាលហ្នឹងប្រហែលជា៥ទេ ហើយងាប់ដោយសារជាន់មីនផងវាឈឺផងហើយគេលួចអស់មួយ!

ដានីៈ គេលួច?

សែមៈ បាទ!

ដានីៈ ដំរីព្រៃឬក៏ដំរីស្រុក?

សែមៈ ដំរីស្រុក!

ដានីៈ ដំរីហ្នឹងគេយកមក...?

សែមៈ ដូចថាគេជម្លៀសហើយវាចេះតែរត់តាមម៉ោអញ្ចឹងណា៎! វាមានគ្រប់តែអត់មានអាត្រាក់មួយទេក្រៅពីហ្នឹងមានដូចជាឡានអីមាន!

ដានីៈ បាទ! កាលជំនាន់ហ្នឹងបើវៃជាមួយខាងកងទ័ពយួនខាងកងទ័ពរដ្ឋកម្ពុជាកាលហ្នឹងវៃរាល់ថ្ងៃឬក៏មិនសូវវៃទេ!

សែមៈ វៃរាល់ថ្ងៃគឺមិនឲ្យស្ងាត់ហ្មង!

ដានីៈ យើងអ្នកវៃ?

សែមៈ យើងអ្នកវៃយើងអ្នកអត់មានផ្ទះនៅអត់មានដីនៅមានបទបញ្ជាដូចថាស្មោះមិនឲ្យអ្នកឯងដេកបានស្រួល!

ដានីៈ ដូចឈ្លបអញ្ចឹង?

សែមៈ ហ្នឹងអើយាសគ្រាមឈ្លបហ្នឹង យូៗបាញ់មួយទូងហើយដាក់មីនឲ្យដាច់ដៃដាច់ជើងអញ្ចឹងទៅ!

ដានីៈ បានន័យថាយើងចែកកម្លាំងគ្នាម្ដងក្រុមនេះទៅធ្វើម្ដងក្រុមនោះទៅធ្វើមិនមែនយើងចេញវៃទាំងអស់គ្នាទេ?

សែមៈ អត់ទេ!

ដានី:	អញ្ចឹងអ្នកអត់ធ្វើនៅក្រោយអញ្ចឹង?

សែម:	អ្នកអត់ធ្វើទៅបិទចំរូងអញ្ចឹងទៅ ដូចថាឥលូវក្រុមនេះក្រុមមួយទៅឆ្នក់ចំនួនប៉ុន្មានគ្រាប់ ហើយក្រុមពីរទៅយាមល្បាតក្រែងលោខ្មាំងចូលម៉ោទៅមើលដានមើលអីគេរៅវៃយើង១ រៅវៃគេមើលកន្លែងណាមិនស្រួលយើងចាំស្ទាក់ មើលកន្លែងណាមិនស្រួលយើងដាក់មីនចោល ។

ដានី:	ចុះកាលហ្នឹងមេៗគាត់នៅកន្លែងណាទៅ?

សែម:	មេៗគាត់នៅនេះ នៅខាងនោះនៅម្តុំផ្ទះតាណាល់!

ដានី:	ម្តុំផ្ទះតាណាល់?

សែម:	បាទ!

ដានី:	មានមន្ទីរគេមួយនៅហ្នឹង?

សែម:	ហ្នឹងអើយមន្ទីរក្នុង!

ដានី:	មន្ទីរក្នុង?

សែម:	បាទមន្ទីរដែលខ្ញុំយាមខ្ញុំការពារ!

ដានី:	អ៊ំ!

សែម:	ខ្ញុំនៅឆ្នាំ១៩៨៥ហ្នឹងគឺខ្ញុំចេញពីនេះទៅគឺខ្ញុំអត់ទៅវៃណាទេគឺខ្ញុំនៅតែក្នុងមន្ទីរទេខ្ញុំនៅយាម!

ដានី:	នៅយាមមន្ទីរហ្នឹង?

សែម:	បាទ!

ដានី:	យាមមេៗ?

សែម:	បាទ! ដល់ពេលខ្ញុំទៅនោះទៅបានខ្ញុំអស់ដីហើយបានខ្ញុំមកជួយរួមគ្នាវៃ ដល់ខាងលើគាត់រៀបចំកង១៨៥ឲ្យទៅជួយវៃខាងជើងហើយខ្ញុំខាងនេះមិនសូវបានវៃទេ!

ដានី:	អញ្ចឹងនៅឆ្នាំ៨៥យួនហើយខាងរដ្ឋកម្ពុជាគេចូលម៉ោដល់?

សែម:	ចូលម៉ោដល់នេះ ដល់ចូលម៉ោដល់នេះគេធ្វើរបងព័ទ្ធដីណាំតាមមាត់អូរកុំឲ្យពួកខ្ញុំចូល គេធ្វើរបងហើយគេដាក់មីន ។

ដានី:	ហើយយើងខាងខ្មែរក្រហមរត់ទៅដីថៃអស់?

សែម:	បាទយើងទៅដីថៃទៅនៅជម្រកដីថៃ សុំដីគេនៅកំនត់ខែកំនត់ថ្ងៃ ។

ដានី:	គេហៅជំរុំអីគេ?

សែម:	គេហៅជំរុំ៨៥!

ដានី:	ជំរុំ៨៥?

សែមៈ បាទ!

ដានីៈ ទៅនៅហ្នឹងយូដែរអញ្ចឹង?

សែមៈ នៅ៨៥ ម៉ោ៩០ បាន៥ឆ្នាំ

ដានីៈ ៥ឆ្នាំ?

សែមៈ បាទ!

ដានីៈ ហើយដូចថាយើងប្រុសៗ ធ្វើម៉េចទៅនៅស្មៀមប្តូកំធ្វើម៉េចដែរ ប្តូមួយក៏ឆ្លៀតចូលម៉ោវៃឆ្នក់?

សែមៈ នៅហ្នឹងគឺគ្រាន់តែផ្ញើប្រពន្ធកូនទុកទេ ក្រៅពីហ្នឹងប្តីៗចូលម៉ោវៃនេះ ។

ដានីៈ ចូលម៉ោវៃតាមណា?

សែមៈ លួចចូលកន្លែងណាដែលស្ងាត់ចល័តកម្លាំងចូលភ្នក ចូលទៅនៅក្រោយខ្មាំងវិញ ខ្មាំងនៅមុខនេះហើយយើងទៅនៅខាងក្រោយមើលកន្លែងណាដែលស្ងាត់ដែលយើងអាចនៅបានដូចជាបឹងខ្សែដែលគេនិយាយថាបឹងខ្សែបឹងស្រម៉ោចហ្នឹងព្រោះបឹងហ្នឹងវាមានខ្សែច្រើន ហើយបឹងប្រាច់មានប្រាច់ច្រើន ហើយបឹងមួយទៀតសំបូរដោយស្រម៉ោចដល់ហើយគេហៅថាបឹងស្រម៉ោចទៅព្រះនាមហ្នឹងគឺវាចេញម៉ោពីអញ្ចឹងទេ ហើយដូចអូរកាច់អូរលោតអីវាគ្រាន់ថាអូរហ្នឹងវាតូចគេខ្ជិលលោតដល់ហើយគេហៅអូរលោតហ្នឹងទៅ អាហ្នឹងព្រះនាមវាអញ្ចឹងទេ ហើយអូរជ្រៅអូរហ្នឹងវាជ្រៅ គេថាទៅម្តុំកន្លែងអូរជ្រៅអូរធំ អូរណាធំអូរណាជ្រៅ ហើយទៅស្ពានយោលម៉ោពីស្ពានហ្នឹងដើរទៅវាយោល ដល់ពេលវាយោលអញ្ចឹងមិនដឹងរកឈ្មោះអីដាក់ក៏ដាក់ស្ពានយោលអញ្ចឹងទៅ កាត់តាមនេះទៅតាមនោះទៅវៃនោះទៅអាហ្នឹងព្រះនាមវាអញ្ចឹង!

ដានីៈ វៃរយៈពេល៥ឆ្នាំ?

សែមៈ បាទ! រយៈពេល៥ឆ្នាំហ្នឹងគឺប្រទាញទៅអស់មួយរយៈទៅហើយយួនដកទៅដល់ក្រោយម៉ោនៅរដ្ឋកម្ពុជា ពេលនោះគេឲ្យខ្ញុំប្តេជ្ញាចិត្ត គេឲ្យខ្ញុំមានចាប់អារម្មណ៍ក្នុងឋានៈយើងជាអ្នកដឹកនាំមួយតូចល្មមគឺថាឲ្យចាប់អារម្មណ៍ថាតើក្រោយពីខ្មាំងយួនដកចេញទៅនៅជាមួយពួកខ្មែរនេះតើយើងមានអារម្មណ៍ថាយ៉ាងម៉េច ពិបាកស្រួលយ៉ាងម៉េចក្នុងការប្រយុទ្ធនេះ ហើយខ្ញុំក៏មានមតិថា បងសាមននោះគាត់សួរខ្ញុំថាម៉េចហើយមិត្តសែមមានចាប់អារម្មណ៍ ហើយរឿងលំបាកស្រួលម៉េច នៅចំនុចថៅកែយ៉ាអីហ្នឹង ដល់ហើយខ្ញុំថាចំពោះអាខ្មាំងយួនមិនអីទេព្រោះយើងបាញ់ទៅវាអត់ញញើតដៃទេ យើងចរិកជាខ្មែរយើងអ្នកស្នេហាជាតិពិតប្រាកដ យើងអត់មានថាឃើញខ្មែរហ្នឹងចង់តែបាញ់ យើងថាខ្មាំងយួនវាស្រួលបាញ់ទេទោះវាខ្លាំងប៉ុណ្ណាក៏ដោយ

តែវាស៊ូជាមួយយើងយ៉ាងណាក៏ដោយ យើងវ៉ៃជាមួយវាលំបាកយ៉ាងណាក៏ដោយក៏យើងបាញ់ទៅអត់ញញើតដៃដែរ! តែចំពោះអាខ្មាំងខ្មែរនិយាយទៅជាមួយអាខ្មាំងខ្មែរនៅអន្លុងប្រជុំគេសើចវាមិនដែលមានអ្នកណានិយាយអញ្ចឹង(សើច) យើងហៅតែអាយ៉ងៗ ដល់ពេលអញ្ចឹងខ្ញុំហៅអាខ្មាំងខ្មែរវាប្លែកបន្តិចនៅអន្លុងប្រជុំណា៎ វាអស់សំណើចបន្តិចហើយយើងចាប់អារម្មណ៍ថាចំពោះអាខ្មាំងខ្មែរពិបាកណាស់ បានគេសួថាម៉េចបានមិត្តពិបាក បងឯងគិតមើលទៅពួសូគេដើរម៉ោគេនិយាយគ្នាពួថាអ្នកខ្លះនៅកំពង់ឆ្នាំង អ្នកខ្លះនៅកំពង់ធំ អ្នកខ្លះនៅកំពង់ចាម ហើយបើយើងបាញ់ទៅមិនដឹងជាបងប្អូនយើង មិនដឹងជាអ្នកណាមួយ មិនដឹងជាជីដូនមួយយើងប៉ុក៏អ្នកណាយើងម៉េចដឹង ស្រួលបាញ់ណាស់យើងទៅលបស្តាប់វាថាវាទៅខាងជើងយើងដឹងថាវាទៅខាងជើង អញ្ចឹងអាខ្មាំងយួនយើងអត់ដឹងថាវាទៅណាទេ យើងស្តាប់វាអត់បានអាហ្នឹងយើងប្រែវាអញ្ចឹងទៅហើយគេក៏យល់ថាអ៊ើបើយើងមិនបាញ់គេគេបាញ់យើងគេចាត់ទុកថាយើងហ្នឹងជាសត្រូវជាមួយគេហើយឥលូវយើងធ្វើយ៉ាងម៉េច ខ្ញុំថាឥលូវយើងត្រូវរកវិធីទៅរកវិធីវ៉ៃផងដោះស្រាយបញ្ហាផង វ៉ៃផងពិសោធន៍ផង ហៅមេបញ្ជាការទាំងអស់ពិសោធន៍ថាតើមិត្តជាអ្នកដឹកនាំក្នុងការប្រយុទ្ធនេះតើយើងចាប់អារម្មណ៍យ៉ាងម៉េច ហើយឲ្យខាងថ្នាក់លើជួយវិភាគ បើយើងវិភាគមិនចេញឲ្យថ្នាក់លើវិភាគ ថ្នាក់លើវិភាគទៅឲ្យយើងធ្វើយើងអ្នកដែលធ្វើជាក់ស្តែងទៅបើឃើញថាលំបាកយើងឲ្យមតិម៉ោខាងលើវិញ គេប្តូរផ្លាស់គ្នាអញ្ចឹងណា៎ ខ្ញុំថាយើងសូមឲ្យខាងលើគិតគូរទៅយើងរកវិធីអីក៏ដោយព្រោះយើងស្តាប់គ្នាបានអញ្ចឹងក្រោយម៉ោបានគេយកអាឃោសនានេះថាពួកដែលនៅក្នុងមែនតែអត់បានស្រួលទេពួកហ្នឹងវានៅតែក្នុងព្រៃដូចតែពួកយើងដែរ! វាគ្មានសេរីភាពជាងយើងទេព្រោះវានៅកន្លែងណានៅកន្លែងហ្នឹងសូម្បីតែស្រីមិនដែលឃើញផង សក់ក៏គ្នាមិនដែលបានកាត់ផង យើងវិភាគទៅវាឃើញអស់ហើយ ហើយក្អកខេះៗនៅតែក្នុងព្រៃស៊ីសុទ្ធតែស៊ី ស៊ីសុទ្ធតែសាច់ ហើយយើងមានការផ្លាស់ប្តូរគ្នា ចុះវាអត់មានការផ្លាស់ប្តូរផងវានៅតែលើភ្នំហើយយើងមានថ្នាំលេបចំនែកវាអត់មានថ្នាំលេបទេ!

ដានី: បាទ!

សែម: ហើយគិតមើលរឿងស្អីអញ្ចឹងឃោសនាទៅឲ្យវារត់ទៅកុំឲ្យវាបម្រើគេទៀត ដល់អញ្ចឹងខាងលើហ្នឹងក៏យកមតិហ្នឹង ដល់ហើយគាត់ទិញមេក្រូឲ្យមួយហើយប្រដាប់ចាក់ម៉ាញ៉េតូចហ្នឹងមួយដែលយើងស្តាយបានគាត់ឲ្យឃោសនាទៅ ចាក់ចម្រៀងកំសត់ៗទៅរឿងស្អីមិនបោលទៅផ្ទះដល់កំសត់ទឹកភ្នែកហើយដល់ទឹកភ្នែកនឹកឃើញកន្ទុយគោហើយ ដល់នឹកឃើញកន្ទុយគោនឹក

ឃើញស្រណោះខ្លួន ហើយកាលនោះខ្ញុំតខ្សែទូរស័ព្ទហើយយើងនិយាយគ្នាថាម៉េចហើយអាឡូ ដល់ថាអាឡូអញ្ចឹងគេដឹងតែគ្នាហើយណ៎ទូរស័ព្ទហើយយើងមានទូរស័ព្ទដែរ!

ដានី: បាទ!

សែម: ដល់ហើយថាអាឡូគេសួថាអ្នកណា ដល់ហើយខ្ញុំថាខ្ញុំណ៎ ហើយគេថាអ្នកណាខ្ញុំហ្នឹង? ខ្ញុំអ្នកនៅព្រៃហើយគេថាអ្នកនៅព្រៃម៉េចបាននិយាយម៉ោនេះ អ៎និយាយម៉ោមិនបាច់ទៅនិយាយគ្នាច្រើនទេខ្ញុំចង់ទាក់ទងជាលោកឯងបានទេ ព្រោះលោកឯងជាខ្មែរដូចគ្នាយើងល្មមឈប់វ៉ៃគ្នានូវ ដល់ហើយគេថាអ៎ឈប់ម៉េចបើខាងលើគេមិនឲ្យឈប់ផង ហើយខ្ញុំថាឯងខ្លាំងណ៎ហើយឯងក៏ថាអញខ្លាំងដែរណ៎ ដូចច្នេះឥលូវនេះអាណាដេកស្រួលអាណាដេកមិនស្រួលគេនោះគេបញ្ឈរក្បាលពីនោះម៉ោពីភ្នំពេញម៉ោឲ្យឯងដេកក្នុងព្រៃ ហើយអញគេឲ្យអញម៉ោគេឲ្យអញយកដីអញវិញអញមិនឲ្យយួនយកទេ អញ្ចឹងបើលោកឯងកាលហ្នឹងគេហៅមិត្តផងហៅលោកផងយើងដូចថាការប្រើពាក្យមិនទាន់បានពិរោះនៅឡើយទេ មិនដឹងថាត្រូវប្រើម៉េចឲ្យបានគួសមទេ ឥលូវអញ្ចេះទៅយើងកុំបាញ់គ្នាទៅហើយលោកឯងទៅផ្ទះលោកឯងទៅទុកឲ្យខ្ញុំនៅដីនេះផងទៅ ខ្ញុំនៅនេះខ្ញុំការពារនេះហើយលោកឯងទៅវិញទៅ ដល់ពេលនិយាយបែបនេះគេថាអាចម៍ទេហ្ន៎អត់ដីនៅម៉ោធ្វើលួងអញអីណ៎ អាកាលទទួលមនោគមន៍វិជ្ជាវានៅខ្លាំងហើយយើងចេះតែលួងទៅ ចេះតែនិយាយទៅព្រោះអត់ជម្រក ប៉ុន្តែនៅជាន់ដីនេះហើយដល់ពេលចេះតែនិយាយមួយថ្ងៃមួយថ្ងៃទៀតខ្ញុំចាក់មេក្រូ អញ្ចឹងឯងចង់ស្តាប់មេក្រូទេអញចាក់មេក្រូឯងស្រណោះប្អូនអត់ និយាយពីរឿងការស្រណោះ និយាយពីរឿងអត់មានស៊ីនិយាយពីរឿងកំសត់ហើយឯងអាណិតខ្លួនឯងអត់ឯងនៅហ្នឹង ដល់ហើយគេថាអញនៅនេះមិនដែលបានឃើញស្រីម្តងទេអញនៅជិតមួយឆ្នាំហើយ ដល់ទទួលអាពាក្យហ្នឹងម៉ោយើងបញ្ចូលពាក្យហ្នឹងទុក!

ដានី: អញ្ចឹងយើងទាក់ទងគ្នា?

សែម: ទាក់ទងគ្នាក្រោយពីយួនដកទៅទាក់ទងគ្នាតាមទូរស័ព្ទហើយនឹងដាក់មេក្រូនិយាយគ្នា អារឿងមានរាំវង់សព្វថ្ងៃគឺវាលរបស់ខ្ញុំ វាលកងខ្ញុំអ្នករាំហ្នឹងអត់ដុះស្មៅដល់សព្វថ្ងៃអាហ្នឹងខ្ញុំឮគេប្រាប់!

ដានី: វាលរាំវង់?

សែម: បាទ! ដែលឮគេថាទេ?

ដានី: អត់!

សែមៈ វាលរាំវង់គឺពួកខ្ញុំជាអ្នករាំហើយអត់មានទឹកមានអីទេ គ្រាន់តែរាំលេងដូចថាកុំឲ្យបោះបង់ចោល នៅរដូវចូលឆ្នាំ អញ្ចឹងបាននិយាយថានែ៎កុំឲ្យរំខានយើងឯងនៅលើភ្នំហ្នឹងក៏នៅទៅ ឯង សប្បាយៗអញមិនធ្វើអីឯងទេ ហើយឯងហ្នឹងក៏កុំរំខានអញដែរ និយាយអត់សូវមាន សុជីវធម៌ដូចគ្នាគោរពគ្នានូវការនិយាយគ្នា អាសុភាពរាបសារនូវមិនទាន់មាននៅឡើយទេ អញ្ចឹងបានថាកុំឆាឆៅគ្នា បើឆាឆៅគ្នាៗក៏មិនអនុគ្រោះឲ្យឯងដែរ ហើយទៅលបបាញ់ស្នាន ហ្មានក៏បានពួកវាដេកមិនបានសុខទេ ដល់អញ្ចឹងពួកគេក៏មិនឆាឆៅយើងៗក៏ឆាឆៅគេបានន័យ ថាអ្នកហ្នឹងនៅស្ដាប់គ្នាបាន!

ដានីៈ គេនៅស្ដាប់គ្នាបាន?

សែមៈ អញ្ចឹងបានថាខ្មែរវាស្រួលអញ្ចឹង ស្រួលនិយាយគ្នាអញ្ចឹងបើយួនវាអត់ដឹងទេ វាម៉ោពីស្រុកវា ម៉ោអញ្ចឹងបានថាវាពិបាកៗ

ដានីៈ ខ្មែរយើងវាស្រួលស្ដាប់!

សែមៈ ក្រោយម៉ោទៀតមានបងម្នាក់ឈ្មោះស្រី សុបិន្ត!

ដានីៈ ស្រី សុបិន្ត?

សែមៈ បាទ! ស្លាប់ហើយ គាត់ៗរអ៊ូហើយគាត់ចាស់ហើយ ដើរៗគាត់ហត់គាត់ បងស្រីសុបិន្តគាត់ តែងតែទៅទន្លេសាបនោះតស៊ូនៅទន្លេសាបនោះ គាត់ទៅរាប់ឆ្នាំចោលប្រពន្ធចោលកូននៅនេះ ដល់ពេលខាងលើដកកងគាត់មកនៅនេះគាត់ទៅវៃនៅទំនប់ល្ហុងនេះគាត់ថាអើយដូចជាហត់ នឿយណាស់ខ្ជិលដល់ហើយធ្វើសង្គ្រាមយូៗ ហើយខ្ញុំបើកឡានហើយកាលហ្នឹង ដល់ពេល អញ្ចឹងខ្ញុំថាល្មមហើយបង អាហ្នឹងខ្ញុំដាច់ដើងហើយណា៎ យើងចង់ថាឲ្យគាត់ហ្នឹងព្រោះគាត់ជា អ្នកដឹកនាំយើងហើយមេកងពល ល្មមហើយបង! ចុះបើគាត់រអ៊ូមុនយើងមិនថា ហើយខ្ញុំ កាលនោះមនុស្សដឹកស្រាសផងហើយបើកឡានទៀតមានចេះខ្លាចអ្នកធំណាមួយអៀកទេ ចរិកខ្ញុំហ៊ានថាហ៊ានធ្វើ ដល់ពេលអញ្ចឹងគាត់ក៏មិនហ៊ានមាត់កដែរ ហើយខ្ញុំចេះតែនិយាយថា តស៊ូយូៗវៃតែខ្មែរគ្នាឯងហើយគ្មានរបៀបរកចចារចអីគ្នាទេអី ចចារទៅនិយាយគ្នាទៅ ដល់ ហើយគាត់ថាក្រែងគេមិនអនុគ្រោះឲ្យយើង អញ្ចឹងហើយបានជាមុនយើងផ្ដាច់ខ្លួននេះបាន សម្ដេចលោកយកភាសាមួយមិនមែនគាត់មិនដឹងខ្មែរដូចគ្នាពិភាក្សាមិនឲ្យមានឈ្នះមិនឲ្យមាន ចាញ់ គឺថាឲ្យចាញ់មួយឈ្នះមួយគឺវាអត់សុខចិត្តទេ គាត់ដឹងតែគាត់ឈ្នះខ្ញុំហើយ តែគាត់នៅ តែខ្ញុំក៏មិនសុខចិត្តចាញ់គាត់ដែរ ដល់អញ្ចឹងគាត់ប្រើពាក្យមួយថាសមារន្ទកម្មហ្នឹងមិនចាញ់មិន ឈ្នះ ដល់អញ្ចឹងអាមិនចាញ់មិនឈ្នះនេះហើយដែលមានគេហៅថាប្រជាជន ទាហ៊ាន កងទ័ព

ទាំងអស់នេះគឺថាគាត់យកបានទទួលបាន បើឈ្នះបានទៅអ្នកណាហើយបើចាញ់បានទៅអ្នកណាបើខ្មែរដូចគ្នាហ្នឹង បើយើងសាមគ្គីគ្នាវាមិនល្អ ។

ដានីៈ ហើយកាលហ្នឹងនៅឆ្នាំ៩០ពេលដែលយួនចេញទៅយើងខាងខ្មែរក្រហមចូលម៉ោភ្លាមឬក៏យ៉ាងម៉េច?

សែមៈ ពេលណា?

ដានីៈ កាលឆ្នាំ៩០ពូមានប្រសាសន៍ថាកាលឆ្នាំ៨៥ពូទៅនៅដីថៃហើយនៅឆ្នាំ៩០ពូម៉ោវិញ?

សែមៈ បាទខ្ញុំម៉ោវិញ!

ដានីៈ ម៉ោទាំងអស់ទាំងប្រពន្ធទាំងកូន?

សែមៈ បាទ!

ដានីៈ ពេលនោះយ៉ាងម៉េច?

សែមៈ ពេលនោះគ្មានយ៉ាងម៉េចខ្ញុំមកកសាងផ្ទះវិញ កសាងផ្ទះដោយឡែកៗ ដោះមីនផងមកភាវមីនផងក្នុងមួយគ្រួសារពីគ្រួសារដែលយើងសហការណ៍ដោះមីនដើម្បីធ្វើផ្ទះនៅធ្វើតូចៗនៅដើម្បីជ្រកសិនហើយបានយើងដើរកាប់ឈើយកមកធ្វើទៀត ប៉ុន្តែយើងកសាងលឿនទេក្រោយម៉ោដែលយើងចេះដឹងអារឿងការកសាងផ្ទះសំបែងហ្នឹង យើងម៉ោវិញអញ្ចឹងអ្នកដែលទៅវៃនៅតែទៅវៃហើយអ្នកនៅក្រោយគឺមានអាកម្លាំងមួយសម្រាប់ជួយ ដូចខ្ញុំពិការអញ្ចឹងគេកាប់ឈើឲ្យព្រោះក្នុងឋានៈយើងជាអ្នកដឹកនាំមួយដែរ!

ដានីៈ កាលនោះយើងវៃបានហ្នឹងហើយបានយើងនាំប្រពន្ធកូនម៉ោ!

សែមៈ បាទ! វៃបានហើយបាននាំប្រពន្ធកូនម៉ោ ហើយវាដល់អាណាគត្តិដែរហើយ ហើយយើងក៏វៃបានដែរ ដឹកប្រពន្ធកូនពីនោះម៉ោយកមកដាក់នៅដីនេះ ដូច្នេះបើរាល់ដីតូចៗដែលយើងធ្វើផ្ទះមួយហ្នឹង បើនៅផ្ទះគេយើងដាំដំនាំអីក៏គេនៅតែថាដីគេៗ ហើយបើថាផ្ទះយើងសូម្បីតែប្រពន្ធកូនយើងបោសៗបន្តិចក៏នៅតែបានអីស៊ី ហើយយើងដាំអីមួយអាហ្នឹងរបស់យើងហើយ

ដានីៈ ពូមានប្រសាសន៍មេញថាទាក់ទងគ្នាតាមគេអូហ្នឹងនៅខាងណាវិញ?

សែមៈ ខ្ញុំនៅភ្នំយល់សប្តិ ដែលខ្ញុំទាក់ទងគឺនៅភ្នំយល់សប្តិ!

ដានីៈ ប៉ុន្តែកាលហ្នឹងទាហ៊ានយួននឹងទាហ៊ានរដ្ឋកម្ពុជាគេចេញពីហ្នឹងទៅនៅខាងក្នុងវិញអស់ហើយ?

សែមៈ ខ្ញុំនៅពីក្រោយនៅកន្លែងវាលហើយគាត់នៅក្នុងព្រៃនោះ ហើយខ្ញុំទៅយកអន្តរពីវាលមកវិញចូលម៉ោក្នុងព្រៃនេះ យកពីអូរជ្រៅមកវិញយកមកហូបម៉ោហើយវៃចូលខាងនេះវិញ ហើយ

ការដឹកជញ្ជូនក៏ដឹកពីនេះទៅតែយើងបើកផ្លូវ យើងលួចបើកផ្លូវអញ្ចឹងទៅ យាមអញ្ចឹងទៅឲ្យកម្លាំងដឹកជញ្ជូនយកទៅឲ្យយើងទៅ យកមកយើងហូបបានមួយខែពីរខែអញ្ចឹងទៅ ។

ដានីៈ អញ្ចឹងកាលយើងឆ្នាំ៩០ម៉ោវិញហ្នឹងកន្លែងហ្នឹងពិបាកទេដូចថាមានអីច្រើនចឹង?

សែមៈ ពិបាកណាស់ព្រោះមានមីនច្រើនណាស់ ដាច់ជើងស្លាប់ អាទៅវ៉ៃមិនស្លាប់មកដោះមីនឲ្យប្រពន្ធនៅហ្នឹងក៏ស្លាប់

ដានីៈ ចុះពូពិការហ្នឹងដោយសារពេលទៅវ៉ៃឬក៏ដោយសារអី?

សែមៈ ពេលដែលវ៉ៃហ្នឹងអត់មានអីទេ ដល់ពេលថយទៅកម្លាំងដែលវ៉ៃហ្នឹងគេដាក់មីនទៅដូចថាទៅការពារទឹកដីហ្នឹងទៅក៏ជាន់!

ដានីៈ ជាន់មីនគ្នាឯងឬក៏...?

សែមៈ ជាន់មីនគ្នាឯង!

ដានីៈ ជាន់មីនគ្នាឯង!

សែមៈ បាទ! អាហ្នឹងនិយាយដោយស្មោះអញ្ចឹងហ្នងអត់មាននិយាយពន្លើសអីទេ! ធ្វើម៉េចគឺថាអញ្ចឹង

ដានីៈ កាលនោះពូទៅព្យាបាលនៅណា?

សែមៈ ព្យាបាលនៅស្រុកវិញ!

ដានីៈ ព្យាបាលនៅស្រុក?

សែមៈ ម៉ោ៨៥ ចុះបើយើងអត់ទាន់បានដីនៅណាគេអត់ទាន់ដកចេញណា មានទាន់វ៉ៃដេញគេចេញណាយើងនៅដាច់ជើងនៅឡើយ

ដល់អញ្ចឹងទទួលពេលខ្ញុំដាច់ជើងយើងវ៉ៃយើងចេះតែដេញអស់ទៅបានគេយកប្រជាជនម៉ោនេះម៉ោខ្ញុំក៏នៅព្យាបាលហ្នឹងក៏គេយកមកព្យាបាលនៅនេះវិញទៀត មន្ទីរពេទ្យក៏លើកម៉ោនេះវិញដែរ!

ដានីៈ ព្យាបាលរយៈពេលប៉ុន្មានដែរបានជា?

សែមៈ រយៈពេល៣ខែ!

ដានីៈ ៣ខែយើងជាបានដើរបានអីដែរ?

សែមៈ ជាគ្រាន់បានរៀនដើរ!

ដានីៈ បានរៀនដើរ?

សែមៈ បាទ!

ដានីៈ ពេលណាបានយើងអាចដើរបានធម្មតា ហើយធ្វើការធ្វើអី?

សែមៈ អាហ្នឹងតាមសាច់មនុស្សដែរ ៣ខែអ្នកខ្លះដើរបាន អ្នកខ្លះដើរអត់ទាន់បានទៅ អ្នកខ្លះនៅរបួសតិចរបួសច្រើន ខ្ញុំក្នុង៣ខែហ្នឹងក៏ដើរអត់ទាន់ស្រួលព្រោះខ្ញុំបាក់នៅក្នុងទៀត បាក់ខាងនេះបាក់ខាងនេះ ដូច្នេះអាកន្ទែងឆ្អឹងបាក់នៅក្តៅនៅឡើយទេ ហើយអាដាច់ម៉ោនេះខ្ញុំមិនថាអីទេឃើញតែប៉ុណ្ណឹងទៅ វាត្រូវដាច់ជើងទាំងពីរប៉ុន្តែដល់ពេលការខំព្យាបាលរបស់គ្រូពេទ្យដែលជាពេទ្យដ៏ល្អ ពេទ្យដ៏ស្មោះសជាមួយអ្នកប្រយុទ្ធគេខំឲ្យថ្នាំដើម្បីព្យាបាលអាការៈរោគតរបស់យើងទៅវាឆាប់ជាដែរ!

ដានីៈ កាលហ្នឹងតា ជុំ ជឿន គាត់នៅហ្នឹងដែរ?

សែមៈ បាទនៅហ្នឹង!

ដានីៈ ដល់ក្រោយម៉ោពូពិការពូធ្វើកងទ័ពទៀតឬក៏ឈប់?

សែមៈ យើងធ្វើទ័ពតែទ័ពពិការនៅក្រោយ តែក្រោយម៉ោខ្ញុំចេះបើកឡានខ្ញុំបើកឡានដឹកជញ្ជូនទៅទៀត!

ដានីៈ ពូបើកឡានដឹកជញ្ជូន?

សែមៈ បើកឡានដឹកជញ្ជូន! យើងដើរអត់រួចយើងបើកឡានឲ្យគេ!

ដានីៈ កាលហ្នឹងពូឋានៈអីគេ?

សែមៈ ខ្ញុំកងធំ!

ដានីៈ កងធំ?

សែមៈ បាទ!

ដានីៈ ដល់ចាប់ពី៩០ម៉ោគេឲ្យយើងម៉ោកសាងថ្មីអញ្ចឹងយើងចាប់ផ្តើមធ្វើផ្ទះ បង្កើតភូមិអីឬក៏នៅជាលក្ខណៈកងទ័ពនៅឡើយនៅឆ្នាំ៩០ពេលដែលយើងចូលម៉ោនៅវិញពេលដែលយួនដកថយអស់?

សែមៈ យួនដកថយអស់ពេលដែលយើងម៉ោនេះហ្នឹងមែន?

ដានីៈ បាទ!

សែមៈ ម៉ោនេះខ្ញុំរៀបចំចេះតែដេញទៅធ្វើម៉េចពង្រីកដី!

ដានីៈ ពង្រីកដី?

សែមៈ បាទពង្រីកដី! ហើយទៅវៃទៅជិតស្ពានតាខ្វា ទៅហួសតាគង់ទៀតតាគង់ក៏អត់មានដែលយើងចេះតែដេញទៅដើម្បីពង្រីកឲ្យវាទល់ត្រឹមថ្នល់ជាតិទៅយើងនៅនេះស្រួល យើងធ្វើម៉េចកុំឲ្យកាំភ្លើងធំដល់យើង ហើយទិសដៅរបស់យើងយើងត្រូវថាចង់វៃហ្នឹងគឺវៃដើម្បីដូចថា

ឲ្យឈ្នះចាញ់តែមិនសាយឈ្នះចាញ់ទេព្រោះដីគេនោះវាធំហើយដីខ្ញុំវាតូច ប៉ុន្តែបើធ្វើខ្ញុំក៏មិនសាយបែកដែរ វាមិនសាយថាអាមាន់ជុលពូជជុលដូចគ្នាវាមិនសាយ យើងនិយាយថាខ្មែរដូចគ្នាមិនមែនស្រួលទេ!

ដានីៈ អញ្ចឹងរហូតដល់ឆ្នាំប៉ុន្មានទៅបានយើងចាប់ផ្តើមមានដូចថាយើងចចា?

សែមៈ ចចានៅថ្ងៃ១៥ខែ៨ ពេលដែលខ្ញុំទៅចចាខ្ញុំជិះកប៉ាល់ហោះទៅ ទៅនៅបន្ទាយទីមួយ ហើយខ្ញុំចចាហ្នឹងខ្ញុំបានជិះកប៉ាល់ហោះទៅលេងកូនដីរីដែរ!

ដានីៈ ជាមួយពីណាខ្លះ?

សែមៈ ជាមួយម៉ៃ សេងហ៊ិន!

ដានីៈ ម៉ៃ សេងហ៊ិន?

សែមៈ ម៉ៃ សេងហ៊ិននៅកងពល៥១! កាលនោះខ្ញុំអត់ទាន់ស្គាល់គេអីទេ ប៉ុន្តែគេម៉ោបន្ទាយទីមួយគេចុះម៉ោហ្នឹងបើកឡានទៅគេទៅចចារ តែថ្ងៃ១៥ហ្នឹងថ្ងៃសម្រេចខែ៨

ដានីៈ ១៥ខែ៨?

សែមៈ ហ្នឹងអើយ ដូច្នេះអាការចចាគ្នាហ្នឹងខ្ញុំអរណាស់ព្រោះបានត្រូវគ្នា!

ដានីៈ ចុះដល់ពេលយើងចចាហើយយើងផ្តើមរៀបចំមូលដ្ឋានយើងរៀបចំយ៉ាងម៉េចទៅ ដូចថាយើងចាប់ផ្តើមចចាដល់ពេលចចារត្រូវយើងចាប់ផ្តើមរៀបចំផ្លាស់ប្តូរយ៉ាងម៉េចភូមិសាស្ត្រយើងនៅម៉ាឡៃហ្នឹង?

សែមៈ យើងរៀបចំជាភូមិក្រុមដើម្បីឲ្យសាយយល់ប្រជាជនដែលនៅតស៊ូនេះពន្យល់ពីរឿងច្បាប់ទម្លាប់ព្រោះវាប៉ុន្មានរយៈប៉ុន្មានឆ្នាំ៣០ជាងគ្មានចូលក្នុងច្បាប់អីទេជាទម្លាប់ទេ ដល់អញ្ចឹងទៅបានគេរៀបចំប្រព័ន្ធខាងច្បាប់ចេញពីលើម៉ោបានយើងរៀបចំភូមិមានជាភូមិក្បាលស្ពានអីចឹងណា៎!

ដានីៈ ជាភូមិជាឃុំអញ្ចឹង?

សែមៈ ហ្នឹងអើយជាភូមិជាឃុំ!

ដានីៈ ហើយមានស្រុកដែរ?

សែមៈ បាទមានស្រុក អញ្ចឹងហើយបានយើងធ្វើតាមច្បាប់រដ្ឋាភិបាល រដ្ឋាភិបាលឲ្យយើងធ្វើម៉េចយើងធ្វើអញ្ចឹង!

ដានីៈ កាលហ្នឹងគេមានចាត់ចែងមនុស្សដូចថាគ្រប់គ្រងភូមិមួយៗ ឃុំស្រុកអីយើងចាត់ចែងយ៉ាងម៉េចយើងដាក់ម៉ោឬក៏បោះឆ្នោត?

សែមៈ	យើងរៀបចំអញ្ចេះឧទាហរណ៍ថាគាត់មើលម៉ោខ្ញុំនេះដូចថាមានសមត្ថិភាពដឹកនាំបានយើងដាក់ទៅ យើងតាមសង្កេតមើលថាយើងរៀបដូចមេខ្យល់ មុនដំបូងយើងអត់ដឹងទេយើងថាអ្នកគស៊ូទាំងអស់គ្នាប៉ុន្តែយើងមើលចរិកមនុស្សហ្នឹងថាតើអាចដឹកនាំគេបានឬអត់ ដល់អញ្ចឹងយើងមើលឃើញមនុស្សកហ្នឹងអាចដឹកនាំគេបានហើយដាក់ឲ្យគាត់ហើយក៏ហៅម៉ោ ម៉េចហើយយើងសម្រេចឲ្យគាត់ធ្វើឬអត់ហើយបើថាសម្រេចហើយយើងទះដៃទៅព្រមព្រៀងគ្នា គាត់ហ្នឹងគាត់ថាអញអត់ធ្វើទេដល់ហើយខ្ញុំថាអ៊ើអត់ធ្វើម៉េចបើគេយល់ថាបងឯងចាស់ទុំអាចមើលការខុសត្រូវក្នុងភូមិនេះបានហើយធ្វើទៅខុសត្រូវអីគេមិនថាអីទេគេចេះតែជួយថាគ្នាទៅ ក៏ស្ម័គ្រចិត្តធ្វើទៅ ហើយឃុំក៏យើងចាត់តាំងដែរដូចថាសមត្ថិភាពអ្នកហ្នឹងធ្វើបានឲ្យធ្វើបានក្រោយម៉ោគេបោះឆ្នោត ដែលថាតាមច្បាប់រដ្ឋាភិបាលអាហ្នឹងគឺបោះឆ្នោតហើយ ។

ដានីៈ	បើដំបូងគេចាត់តាំង?

សែមៈ	ដំបូងគេចាត់តាំង ចាត់តាំងហ្នឹងគេចាត់តាំងជ្រើសរើសដូចតែបោះឆ្នោតដែរទេ ជ្រើសរើសអ្នកមានសមត្ថិភាព មែនយកមនុស្សដែលល្ងង់ដែលមិនដឹងអីយកទៅធ្វើម៉េចហ្នឹងកើត ។

ដានីៈ	ចុះឃុំនេះដំបូងពីណាគេអ្នកមើលការខុសត្រូវ?

សែមៈ	ឃុំនៅម៉ាឡៃនេះមុនដំបូងអាហ្នឹងបោះឆ្នោត អាហ្នឹងស្ងួត ភាព!

ដានីៈ	ចុះមុន មុនដែលយើងចាត់តាំង?

សែមៈ	មុនដែលយើងចាត់តាំងនោះមាន អាហ្នឹងគេនិយាយជារួមអញ្ចេះវិញ ដូចថាម៉ានៅម៉ាឡៃចេះគេនិយាយជាតំបន់អាហ្នឹងបើយើងនិយាយមុនរដ្ឋាភិបាលវិញអាហ្នឹងវាផ្សេង តែអានេះយើងនិយាយនេះនិយាយក្រោយទេណ៎ា យើងចូលជាមួយរដ្ឋាភិបាលហើយ កាលមុននោះមានអ៊ីយ៉ែមមានអ៊ីយែមគាត់ទទួលក្នុងតំបន់ក្នុងស្រុកហ្នឹងក្នុងស្រុកម៉ាឡៃហ្នឹងណ៎ាទាំងមូលហ្នឹងនិយាយតាំងខ្លាមាត់ បឹងបេងហ្នឹងគាត់រ៉ាប់រ៉ងទាំងអស់ ហើយគាត់រើសយកមនុស្សមួយចំនួនដែលនេះហ្នឹងខ្ញុំចាំមិនអស់ទេតែនិយាយរួមគឺមានអ៊ីយ៉ែម ក្រោយម៉ោបានតានី ដល់ចាត់តាំងកើតជាស្រុកទៀតរំលែកបោះឆ្នោតជាឃុំអាហ្នឹងបានមានតទៀតអាហ្នឹងក្រោយម៉ោជាប់រដ្ឋភិបាលអ្នកដែលធ្លាប់ដឹកនាំនៅតែដឹកនាំដដែលហើយអ្នកដែលមិនធ្លាប់ដឹកនាំគឺនៅតែអត់ អ៊ីដែលគេថាបទពិសោធន៍ បើអ្នកណាមានបទពិសោធន៍គឺត្រូវតែយកអ្នកហ្នឹងឯង! ហើយយកអ្នកដែលអត់មានបទពិសោធន៍ក៏មិនដឹងយកធ្វើអីដែរយកម៉ោមីងមាំងៗ ។

ដានីៈ	ចុះឈ្មោះយ៉ែមមេញឥលូវគាត់នៅណា?

សែមៈ	គាត់ស្លាប់បាត់ហើយ!

ដានី៖ ស្លាប់ហើយ?

សែម៖ បាទ!

ដានី៖ ចុះឈឹម ប៊ុននីគាត់នៅណា?

សែម៖ គានីគាត់នៅស្វាយ!

ដានី៖ គាត់កងទ័ពឬក៏...?

សែម៖ គាត់អ្នកពិការដែរតែគាត់នៅទទួលខាង... ខ្ញុំអត់ដឹងដែរព្រោះការងាររបស់គាត់ដឹងតែនៅខេត្ត តែមិនដឹងគាត់ទទួលខាងអី! តែកាលដែលខ្ញុំទៅខេត្តហ្នឹងខាងអ្នកពិការគាត់អាចជំនួយ ទៅខាងសង្គមកិច្ច ។

ដានី៖ ខាងសង្គមកិច្ច?

សែម៖ បាទ! ឃើញគាត់ប៉ុន្តែមិនដឹងតួនាទីគាត់ជាស្អីពិត!

ដានី៖ ចុះកាលហ្នឹងពេលដែលចាប់ផ្តើមធ្វើសាមាគ្គីហើយ ដូចថាយើងមានការផ្លាស់ប្តូរយ៉ាងម៉េច កាលពីមុនៗសាមាគ្គីយើងតស៊ូយើងវៃដងយើងប្រកបមុខរបរដាំអី យើងធ្វើអីបានលក់ដូររបស់របរ ធ្វើរបស់របរឲ្យគ្រួសារឬក៏ស្រីៗដែលយើងចូលចិត្តអញ្ចឹងណា៎ ដល់ពេលក្រោយម៉ោបន្ទាប់ពីធ្វើសាមាគ្គីហើយយើងមានការផ្លាស់ប្តូរយ៉ាងម៉េច?

សែម៖ ពេលដែលធូធារពីមុនដូចថាឥលូវគេកាប់តាំងពីទំពាំង តាំងពីធ្វើទ្រូ ធ្វើលប ធ្វើកៅអី កាប់ឈើលក់ កាប់ឬស្សីលក់ ដល់ក្រោយម៉ោទៀតនេះសម័យរដ្ឋាភិបាលអានេះបងប្អូនយើងគាត់ចាំពាក្យមួយម៉ាត់ម៉ោថា «មានតែដីទេ»!

ដានី៖ បាទ!

សែម៖ មានតែដីទេ អញ្ចឹងបានថាបងប្អូនយើងចចារនេះអ្នកដឹកនាំខាងនេះគាត់មានគំនិតមួយថាយើងទៅណាក៏មិនបានដែរ យើងនៅកន្លែងណានៅកន្លែងហ្នឹងទៅ គ្រាន់តែចចារថាឲ្យត្រូវគ្នាតែ យើងនៅកន្លែងណាយើងនៅកន្លែងហ្នឹងទៅ ដូច្នេះយើងត្រូវចាត់តាំងថាដីមួយព្រៃកន្លែងផ្នែកនេះឲ្យអង្គភាពនេះយើងចាប់ផ្តើមចែកដីហើយណា!

ដានី៖ បាទ!

សែម៖ ចែកព្រៃ!

ដានី៖ ចែកព្រៃ?

សែម៖ ចែកព្រៃឲ្យកាប់យកដី អ្នកដឹកនាំនេះគាត់ឆ្លាតដែរ គាត់ថាមានតែដីទេទឹកដីនេះឯងដែលធ្វើឲ្យយើងរស់នៅបានស្រួល បើយើងអត់កាប់ព្រៃហ្នឹងឲ្យកើតជាដីធ្លីទេយើងចេះតែចង់ទៅនៅនេះ

ចង់ទៅនៅនោះ ហើយទៅនៅស្រុកកំណើតវិញក៏អត់បានអីដែរ ព្រោះយើងតស៊ូនៅដីនេះ យើងត្រូវយកដីនេះធ្វើជាបង្អែក ដល់អញ្ចឹងទៅចែកព្រៃ ចែកហ្នឹងគឺមិនមែនចែកជាបុគ្គលទេ ចែកជាអន្តភាពកម្លាំងធំអញ្ចឹង បានកម្លាំងផ្នែកដឹកជញ្ជូនហ្នឹងពីមុនហ្នឹងផ្នែកកងទ័ពហ្នឹងម៉ាប្លង់ចទៅ កងទ័ពហ្នឹងវាមានលេខវា មាន១៨៥គេឲ្យផ្សេងទៅ ១០៨គេឲ្យផ្សេងទៅ ១០៧គេឲ្យផ្សេងទៅតាមសញ្ញារបស់យើងកាន់កាប់ ហើយឲ្យចែកគ្នាលំអិតទៀតទៅតាមខ្លួនឯងកងខ្លួនឯងហ្នឹងធ្វើទៅ!

ដានី: បាទ!

សែម: ចែកគ្នាបាន៦០ម៉ែត្រ ក្បាលអញ្ចឹងបណ្ដោយ១០០,២០០ហ្នឹងស្រេចតែលើអន្តភាពគេណាប៉ះដីទូលាយ ដល់កាប់អាព្រៃហ្នឹងទៅត្រូវអាណាអារ១ទៅ ដល់អញ្ចឹងយើងបានដីផងបានយកឈើលក់ផង!

ដានី: បាទ!

សែម: យើងចេះតែបង្កើត១ទៅបានជាចំការហើយព្រៃវាលអស់រលីង!

ដានី: ពេលយើងកាប់យើងកាប់តាមសមត្ថិភាពបានប៉ុន្មានយកប៉ុណ្ណឹងឬក៏កាបតែអ្វីដែលគេចែកឲ្យចែកឲ្យយើង?

សែម: អ្នកខ្លះលោភអញ្ចឹងទៅលួចទៅកាប់កន្លែងផ្សេងទៀត!

ដានី: អ៎លួចទៅកាប់កន្លែងផ្សេងទៀត?

សែម: ហ្នឹងអើយ! លួចកាប់កន្លែងផ្សេងដូចថាផ្លូវគេចែកកន្លែងនេះ៦០ម៉ែត្រ ដល់ហើយដូចថាមិនគ្រប់ទេយើងចង់បានពីបីហិចតាទៀត ពួសូនោះគេមានព្រៃវាលអញ្ចឹងទៀតមានព្រៃធំអញ្ចឹងក៏សុំគេទៅកាប់អញ្ចឹង អាហ្នឹងចំពោះអ្នកដែលលោភលន់ណា៎!

ដានី: បាទ!

សែម: អ្នកដែលចង់បានច្រើន ហើយដូចខ្ញុំមានសមត្ថិភាពអីគេចែកប៉ុន្មានយកប៉ុណ្ណឹង ព្រោះខ្ញុំទៅអត់រួច!

ដានី: ពូបានប៉ុន្មាន?

សែម: ខ្ញុំបានមួយហាត់ ប៉ុន្តែដីស្រែ!

ដានី: ដីស្រែយើងបានយកមកប្រកបមុខរបរគ្រប់គ្រាន់ដែរឬទេ?

សែម: គ្រប់គ្រាន់បានក្នុងមួយរដូវ! មួយរដូវហ្នឹងគឺហូបពីរដូវ ព្រោះខ្ញុំធ្វើបានមួយតោនពីតោនដែរ!

ដានី: បាទ! ចុះចំការ?

សែមៈ ចំការខ្ញុំវាអត់មានទេ ព្រោះកាលដែលគេចែកកូនខ្ញុំនៅតូចៗ!

ដានីៈ អ៊ំអញ្ចឹង!

សែមៈ ហើយដល់អញ្ចឹងខ្ញុំដើរអត់រួច ហើយការធ្វើស្រែធ្វើចំការហ្នឹងសឹងតែជាកម្លាំងប្រពន្ធទេ ដល់អញ្ចឹងទៅពេលនោះខ្ញុំរកលុយបានដោយសារខ្ញុំដឹកឈើដឹកអីទេណ៎កាលជំនាន់នោះ ខ្ញុំក៏អត់បានដែរឲ្យប្រពន្ធនោះអ្នកធ្វើ!

ដានីៈ ចុះបើតាមពូវិញបទពិសោធន៍របស់ពូពូគិតថាតាំងពីសាមារន្ធកម្មម៉ោយើងរស់នៅ ជីវភាពផ្ទះអីយើងធ្វើដោយខ្លួនឯងក្នុងក្រុមគ្រួសារយើង ហើយកាលពីមុនសាមារន្ធកម្មយើងមានរបបមានអី បើតាមពូវិញពូគិតថាម៉េចដែរពូរស់នៅឥលូវហ្នឹងប្រសើជាងមុនឬក៏មុនស្រួលជាង?

សែមៈ អារឿងពីមុននោះគេឲ្យតែម៉ារស់ទេ តែយើងធ្វើហ្នឹងទៅតាមអ្នកណាឆ្លាត អ្នកណាវៀងវៃក្នុងការប្រកបរបរធ្វើអាជីវកម្ម ដូច្នេះវាអត់មានថាអ្នកណាស្រួលជាងអ្នកណាទេ ព្រោះកាលនោះបើចែកប៊ីចេងៗ ទឹកដោះគោៗ ស្ករៗ ឥលូវនេះបងប្អូនណាពូកែជាងគេទៅទិញឡានទិញអាត្រាក់អីអញ្ចឹងទៅ ហើយដល់ស៊ូគេចេះតែស៊ូអញ្ចឹងទៅ ហើយបងប្អូនណាកម្លាំងទន់ខ្សោយដូចជាខ្ញុំអីវាចេះតែទ្រុឌទ្រោមទៅៗតាមហ្នឹង ដូច្នេះវាតាមគ្រួសារនីមួយៗទេបើយើងចាប់អាជីបអីបានស្រួលទៅវាចេះតែកើនទៅណាយើងមិនអាចកំណត់ថាអ្នកខ្វះហ្នឹងថាអញយ៉ាប់យឺនណាស់បើរកស៊ីរកស៊ីមិនរស់ទេព្រោះធ្លាប់គេឲ្យស៊ី ដល់ពេលគេលែងឲ្យស៊ីទៅអញមិនដឹងពឹងអ្នកណាអាហ្នឹងអញ្ចឹង អញ្ចឹងបានថាក្នុងរយៈពេលដែលការរកស៊ីខ្លួនឯងនេះវាប្រឹងណាស់ហើយសន្សំសំចៃណាស់មិនមែនចេះតែចាយវាយតាមតែចិត្តបានទេ កាលពីមុនអាហ្នឹងវាទម្លាប់វាមិនស្រួលទេ ណាមួយគេឲ្យត្រឹមម៉ារស់តើ! រស់រាប់ឆ្នាំម៉ោតាំងពីចុងជើងដល់ក្បាលគេចិញ្ចឹម តាំងពីស្បែកជើងរហូតដល់កាបូប ដូច្នេះខោអាវខ្មៅខោអាវវែងមានទាំងអស់ទាំងស្រីទាំងប្រុសតែដល់ពេលហូបគេឲ្យហូបតែមួយឆ្អែតគេមិនមែនឲ្យយើងធ្វើអ្នកមានណ៎!

ដានីៈ ចុះពូដល់ឆ្នាំណាបានគេឲ្យពូទៅលេងស្រុក?

សែមៈ ខ្ញុំឆ្នាំប៉ុន្មានទេនែក៎ ដូចជាជំនាន់អ៊ុនគាក់ខ្ញុំទៅលេងស្រុក!

ដានីៈ មុនសាមារន្ធកម្ម?

សែមៈ បាទ! អាហ្នឹងមួយសារហើយ ហើយបានមួយសារទៀត!

ដានីៈ អញ្ចឹងកាលពីពូបែកពីផ្ទះតាំងពីឆ្នាំ ដូចថាតាំងពីតស៊ូម៉ោរហូតដល់ឆ្នាំសម័យអ៊ុនគាក់ហ្នឹងបានពូបានទៅលេងផ្ទះវិញ តែក្នុងចន្លោះពេលហ្នឹងពូមានបានដឹងពីក្រុមគ្រួសាររបស់ពូនៅស្រុកដែរអត់?

សែមៈ អត់ដឹង!

ដានីៈ អត់ដឹងទេ?

សែមៈ អត់ដឹងទាល់តែសោះ! ហើយអ្នកគ្រួសារក៏អត់ដែលដឹងខ្ញុំដែរ គេថាតែខ្ញុំស្លាប់ទេប៉ុន្តែដោយសារអបិយជំនឿគាត់ទៅរកនាក់ ឪពុកគាត់ហ្នឹងជាអ្នលទស្សន៍ទាយដែរ ឪពុកខាងប្រពន្ធខ្ញុំហ្នឹង ដល់ម៉ែខ្ញុំហ្នឹងគាត់ទៅសួថា កុនៗឯងចេះទាយមើលកូនខ្ញុំមើលវាបាត់យូហើយតាំងពីឆ្នាំ៧៤ ចុងឆ្នាំ៧៣ម៉ោតើវានៅរស់ឬក៏ស្លាប់ ដល់គាត់មើលគាត់ថាកូនហ្នឹងអត់ស្លាប់ទេកូនហ្នឹងនៅជាមួយគេអ្នកស្លាប់រហូត កូនហ្នឹងអត់ពិបាកទេ ហើយដណ្តងគ្នាគាត់ហ្នឹងគាត់អត់ដឹងទេ អត់ដឹងថាពីរនាក់ហ្នឹងនៅជាមួយគ្នាទេ!

ដានីៈ អញ្ចឹងពូនៅជាមួយគ្នាអញ្ចឹង?

សែមៈ គាត់នៅព្រែកអំបិលខ្ញុំនៅកោះធំ! មួយនៅលើមួយនៅក្រោម!

ដានីៈ ដល់ទៅរកគ្រូទាយប៉ះចំគ្នា?

សែមៈ ដល់ម្តាយខ្ញុំទៅរកគ្រូទាយឪពុកគេហ្នឹងគាត់ចេះទាយ!

ដានីៈ ចៃដន្យអញ្ចឹងទៀតណា៎! តែអត់ដឹង?

សែមៈ អត់ដឹងទេ! ហើយគាត់ស្លាប់ក៏អត់ដឹងដែរ?

ដានីៈ គាត់ហ្នឹងអត់ដឹងថាកូនគាត់នៅ....?

សែមៈ គាត់ថានៅខាងលិច ទាយថានៅខាងលិច ប៉ុន្តែនៅហ្នឹងនៅជាមួយគេអ្នកខ្ពង់ខ្ពស់ហើយអត់មានពិបាកអីទេ ហើយគាត់ទាយហ្នឹងក៏ត្រូវដែរព្រោះខ្ញុំនៅជាមួយអ្នកធំមែនៗ

ដានីៈ ចុះដល់ពេលពូបែកពីផ្ទះយូអញ្ចឹងពូលើកទីមួយពូទៅដល់ផ្ទះ កាលពីមុនយើងនៅស្រុកនៅភូមិយើងនៅតូចនៅជាមួយឪពុកម្តាយមានមិត្តភ័ក្រ្តមានអី ដល់ពេលជំនាន់អ៊ុនតាក់ពូទៅលេងផ្ទះលេងលើកទីមួយ អញ្ចឹងពេលដំបូងពេលពូទៅដល់ផ្ទះក្នុងអារម្មណ៍យើងដូចថាបែកពីផ្ទះយូអញ្ចឹងកាលហ្នឹងមានអារម្មណ៍យ៉ាងម៉េចដែរ?

សែមៈ រំភើបឥតឧបមាទេ ដូចថាវាអស្ចារ្យហ្មង ជីវិតយើងមិនគួររស់បានមកជួបជុំឪពុកម្តាយវិញទេ ការតស៊ូត្រឡប់ត្រឡិនរបស់យើងតាំងពីចេះកើតម៉ោកាលណាមិនដែលមានសេចក្តីសុខសោះមិនដែលបានសប្បាយសោះ ដូច្នេះវាកើតតែសង្រ្គាមរហូតវិនាសកម្មរហូត អញ្ចឹងដល់ពេលទៅដល់ផ្ទះស្អីក៏អស់ៗហើយវាកើតអាផ្ទះថ្មីម៉ោវិញនោះ ហើយយើងហ្នឹងអត់ដឹងថាគាត់ហ្នឹងជម្លៀសទៅណានោះអត់ដឹងទេ ដល់ពេលយើងទៅៗមានតែការអោបរឹត ការយំស្រែកដោយការនេះក៏សើចផងយំផងពេលហ្នឹងដូចថាវារញ៉េរញ៉ៃវាមិនអាចនិយាយបានៗ

ដានី៖ ទៅបានរយៈពេលប៉ុន្មានថ្ងៃ?

សែម៖ ទៅបានរយៈពេល៣ថ្ងៃអញ្ចឹងទៅយើងក៏ម៉ោវិញម៉ោ ព្រោះអីកាលណាយើងទៅឆ្ងាយហើយ ទៅយូវាអស់សោហ៊ុយច្រើន ហើយកាលណាយើងទៅចោលផ្ទះការងារដីកឈើដីកអីអញ្ចឹងទៅយើងខាត ដូចថាអត់យើងពីផ្ទះអញ្ចឹងទៅវានៅតែកូនតូចៗក្នុងផ្ទះ អញ្ចឹងបើយើងទៅយូទៅ មានតែជូនដាបច្ច័យដល់ឪពុកម្ដាយយើងធ្វើបុណ្យធ្វើទានហើយទៅតាមរយៈបងប្អូនយើងខ្លះទៅហើយសល់ប៉ុន្មានយើងម៉ោវិញម៉ោ!

ដានី៖ ចុះដូចថាមិត្តភ័ក្រ្តដែលនៅជិតខាងកាលហ្នឹងពេលដែលពូទៅគេនៅស្គាល់ពូទេ?

សែម៖ គេនៅខ្លះចាំខ្លះអត់ចាំទេ គ្រាន់តែគេប្លែកត្រង់ថាពេលនោះគេថាស្មានតែឯងងាប់បាត់ហើយ ប៉ុន្តែម៉ែធ្វើបុណ្យពីរបីដងឲ្យហើយ ដល់អញ្ចឹងអាហ្នឹងជាវាសនា វាសនាយើងបានត្រឹមប៉ុណ្ណា ដូច្នេះអស្ចារ្យដែលជីវិតពួកខ្ញុំបានតាំងចេញពីផ្ទះម៉ោរហូតដល់រស់នៅបានមកជួបម៉ែវិញគេថាអស្ចារ្យណាស់ ព្រោះវាមិនងាយរស់ទេតាំងពីរត់ម៉ោអត់បាយដាច់បាយក្រហាយទឹក ជួនកាលដាច់បាយឡើងមួយអាទិត្យ ហើយនៅក្នុងព្រៃដើរគាស់ថ្មគាស់អី អញ្ចឹងបានថាវាអស្ចារ្យណាស់!

ដានី៖ ហើយមួយទៀតខ្ញុំចង់ដឹងពីអារម្មណ៍មនោសញ្ចេតនារបស់ពូដូចថាពូបែកពីផ្ទះយូ ដូចថាមនោសញ្ចេតរបស់ពូបែកពីស្រុកភូមិយូអញ្ចឹង សាច់ញាតិបងប្អូនដូចថាកាលពីមុនពូមានការស្និទស្នាលដល់ពេលក្រោយម៉ោពូម៉ោនៅនេះតាំងពីឆ្នាំ៨០ម៉ោ ដល់មកនៅហ្នឹងដូចថាពូមានញាតិមិត្ត មិត្តភ័ក្រ្តអីស្និទស្នាលមានលក្ខណៈខុសគ្នាយ៉ាងម៉េចនៅផ្ទះនៅម៉ាឡៃស្រុកកំណើតហាក់ដូចជាមានលក្ខណៈខុសគ្នាយ៉ាងម៉េច?

សែម៖ បាទវាខុសគ្នាឆ្ងាយណាស់ ពីមុនយើងដាន់ដីពីមុខផ្ទះយើងដល់កំពង់ទឹកឆ្ងាយណាស់ តែដល់ពេលយើងទៅកាលនោះវាតូចហើយយើងវាធំហើយទីធ្លាផ្ទះយើងចង្អៀតហ្មង ដល់ពេលហ្នឹងមើលទៅចង្អៀតហើយខ្លីហើយចេះតែឆ្ងល់ថាម៉េចផ្ទះយើងហ្នឹងម៉េចក៏ជិតម្លេះឬក៏មិនមែនទេដឹងឆ្ងល់ដែរប៉ុន្តែលក្ខណៈដែលស្រុកភូមិយើងនៅបានតិចដាងនៅនេះ នៅតិចណាស់យើងតិចបំផុតព្រោះយើងនៅបានត្រឹមតែ១០ឆ្នាំ ដល់ពេលយើងនៅនេះយូឆ្នាំដាង ហើយដល់ពេលដែលមិត្តភ័ក្រ្តនៅនោះឃើញយើងទៅដល់ដូចថាគាត់អញ្ចឹងទៅមើលសាច់ពូទូលាយអញ្ចឹងថាយើងហ្នឹងវាគ្រាន់បើអីអញ្ចឹងទៅណ៎ា គេដូចថាគេមានលក្ខណៈមួយខុសប្លែកដែរ គេថាឯងអើយនៅនោះគេវាធូធាតែគេនោះគេអត់ដឹងថាយើងវេទនាប៉ុណ្ណាទេ អញ្ចឹងបានថាយើងគេនិយាយម៉ោដាក់យើងក៏អត់ត្រឹមត្រូវដែរព្រោះគេដឹងតែថាយើងសប្បាយ ឃើញយើងសាច់

ទូលាយបាត់ទៅហើយ ឃើញយើងដឹងតែយើងមានបាត់ទៅហើយ ដល់គេអត់ដឹងថាការដែលយើងតស៊ូវេទនាគេអត់ដឹងទេ!

ដានី: បាទ!

សែម: អញ្ចឹងបានថាជួបទៅវារកនិយាយមិនត្រូវ មិនត្រូវត្រង់ថាវាយតំលៃនៃការដែលគេថាយ៉ាងម៉េចដែលស្និទស្នាលនោះគេខ្លាចយើងវិញ!

ដានី: បាទ!

សែម: គេខ្លាចចិត្តយើងដូចថាយើងហ្នឹងវាខ្ពង់ខ្ពស់ យើងហ្នឹងវាមាន បើនិយាយភាសាសាមញ្ញជាងគេអញ្ចឹងទៅ!

ដានី: ចុះដូចថាភាពស្និទស្នាលបានន័យថាវាពន្លាត់ៗ?

សែម: គេហ្នឹងគន្លាតខ្លះប៉ុន្តែយើងដែលនៅឆ្ងាយហ្នឹងយើងនឹកគេខ្លាំងណាស់ តែគេក៏នឹកយើងដែរតែគេវាចេះគម្លាតគេមិនសូវហ៊ាននៅជិតយើងទេ តែគ្រាន់ថាអ៊ើៗឯងអីចេះចឹងបានមួយភ្លែតគេចេញទៅហើយ ហើយគេនោះក៏គេមិនបានស្និទស្នាលជាមួយយើងយូដែរព្រោះគេក៏មានប្រពន្ធតែយើងបានហៅអញ្ជើញគេម៉ោ សព្វថ្ងៃយើងទៅជួបគ្នាច្រើនតែហូបអី!

ដានី: បាទ!

សែម: ហូបអីលេងអញ្ចឹងទៅ ហៅគ្នាមកសំណេះសំណាលអញ្ចឹងទៅហើយលេងគ្នាក៏ក្នុងឋានៈមួយខ្លាចគ្នាដែរ! វាមិនមែនដូចយើងសិក្សាទេណា៎ ដល់យើងបានធ្វើការខ្ពស់អញ្ចឹងទៅហើយយើងទៅជួបគ្នាអ្នកដែលនេះហ្នឹងគ្នាក៏មិនហ៊ានលេងយើងស្និទដែរ គឺថាមានភាពមួយគម្លាតគ្នាបន្តិចដែរ!

ដានី: ចុះបើនៅនេះវិញ?

សែម: បើនៅនេះវិញវារាល់ថ្ងៃ មិត្តភ័ក្រ្តនៅនេះវារាល់ថ្ងៃហើយដឹងថាយើងចូលចិត្តហូបអី យើងចូលចិត្តយ៉ាងម៉េច យើងមានចរិកមួយអីមិនឆ្អើងឆ្អែគេដឹងយើងហើយ ដូចថាយើងចូលចិត្តញាតិសណ្តានញាតិមិត្តអញ្ចឹងគេចូលចិត្តម៉ោ ហើយយើងចូលចិត្តទៅគេ វាទៅនេះធំជាងទៅនោះ!

ដានី: ធំជាង?

សែម: បាទ!

ដានី: ទោះបីជាកន្លែងនេះយើងម៉ោពីកន្លែងផ្សេងៗគ្នាក៏ដោយ ដូចម៉ោពី២៤ខេត្តក្រុងដូចពូមានប្រសាសន៍ថាម៉ោពីកន្លែងផ្សេងៗគ្នាតែយើងនៅជាមួយគ្នាយូៗទៅវាស្និទគ្នា!

សែម: វាទៅជាបងប្អូនជិតស្និទជាងនៅនោះ!

ដានី៖ បាទ!

សែម៖ យើងសាមគ្គីគ្នាហ្នឹងវាអស្ចារ្យណាស់ដូចថាយើងសាមគ្គីគ្នាបានតែធ្វើនៅក្នុងជីវិតយើងនេះ ជីវិតខ្ញុំនេះបានកសាងមិនកេត្តិ៍អាករពីដូនតាទេគឺកសាងដោយខ្លួនឯង ដោយញើសដោយឈាមខ្លួនឯង ជាស្រុកជាភូមិជាឃុំរហូតប៉ុណ្ណឹងម៉ោតកូនតចៅមានកូនមានចៅទៀត ដូច្នេះយើងយកនោះមកប្រៀបនេះអត់បានទេ!

ដានី៖ បាទ!

សែម៖ យើងការគោរពកន្លែងទឹកដែនដីទឹកន្លែងកំណើតរបស់យើងគឺថាឪពុកម្ដាយយើងនៅទេ តែបើអស់ពីឪពុកម្ដាយយើងៗចប់ហើយ!

ដានី៖ បាទ!

សែម៖ ដែលធំបំផុតដែលយើងយកដៃយើងទៅចូលទៅថ្វាយបង្គំគាត់ហ្នឹងគឺថាព្រះនៅហ្នឹង ព្រះបង្កើតយើងនៅហ្នឹង ខុសគ្នាប៉ុណ្ណឹងទេ បើថាចង់ទៅនោះគ្មានទេសូម្បីតែកូនខ្ញុំទៅស្រុកក៏វាមិនចង់ទៅផងវាអត់ដឹងថាពិបាកយ៉ាងម៉េចទេ វាដូចថាវាអត់ដូចនៅនេះ ។

ដានី៖ ពូបានទៅលេងផ្ទះប៉ុន្មានដងដែរពូ?

សែម៖ មិនដឹងប៉ុន្មានទេខ្ញុំភ្លេចបាត់ហើយ ដូចជា៧ដងដែរ!

ដានី៖ ច្រើនដងដែរ!

សែម៖ បាទច្រើនដង!

ដានី៖ តែទៅទាំងមីងទាំងពូ?

សែម៖ ទៅទាំងអស់គ្នាទាំងកូនតូចៗ!

ដានី៖ អញ្ចឹងបងប្អូនពូគាត់មានធ្លាប់មកលេងពូទេ?

សែម៖ ម៉ោ! តែអ្នកមិនធ្លាប់ម៉ោក៏នៅតែមិនម៉ោ!

ដានី៖ ប៉ុន្តែអត់មានពីណាមកនៅនេះទេ?

សែម៖ អត់ព្រោះគេមានប្ដីមានប្រពន្ធគេនៅនោះដែរ!

ដានី៖ បាទ!

សែម៖ ហើយគេមានដីកេត្តិ៍អាករគេឪម៉ែគេ!

ដានី៖ ចុះពូអត់មានទេ?

សែម៖ យើងអត់ដែលមានទេកេត្តិ៍អាករអីបន្តិចទេ!

ដានី៖ បាទ!

សែមៈ តែយើងក៏មិនប្រណែនគេដែរ!

ដានីៈ បាទ!

សែមៈ ដោយសារយើងការថែរក្សាម្ដាយឪពុកយើងវាគម្លាតឆ្ងាយពេក!

ដានីៈ បាទ!

សែមៈ ហើយយើងក៏មិនដណ្ដើម តែអ្នកខ្លះគេបានគេត្អូញត្អែរតែដូចថាម្ដាយឪពុកគេធូធារគេទុកឲ្យពួកយើងនៅនេះអញ្ជឹងនៅផ្ទះគេអញ្ជឹងគេឲ្យ ដូចអ្នកនៅសៀមរាបគេបានដីបានអីអញ្ជឹងទៅលក់ទិញឡានទិញអីជិះ តែខ្ញុំគ្មានទេដីនៅកោះវាមានដីពីណាធំហើយក៏អត់មានតំលៃដែរ!

ដានីៈ បើមានៗតែដីចំការអីហ្នឹង?

សែមៈ មានក៏មានអត់មានតំលៃដូចគេដែរ!

ដានីៈ បាទ!

សែមៈ អញ្ជឹងហើយមានតែយើងហ្នឹងម្ចាស់ការខ្លួនឯង មានដីប៉ុណ្ណឹងឲ្យកូនរៀន ការបានពីរដែរហើយខ្ញុំ!

ដានីៈ ការបានពីរហើយ?

សែមៈ អានេះមួយមិញហើយមីមួយស្រី!

ដានីៈ ប្រុសអាយុប៉ុន្មាន?

សែមៈ វាឆ្នាំរការអញ្ជឹងវា២៧ហើយ!

ដានីៈ ចុះកូនពៅពូ?

សែមៈ កូនពៅអាយុ១៩ហើយ! កូននេះកូនស្រីខ្ញុំ ហើយអានោះកូនប្រុសខ្ញុំ! អ៊ីពីមុនវាអញ្ចេះដែរវាបំបែកមួយក្ដានោះហើយទៅស្រុកទៅ!

ដានីៈ ជិះឡានទៅខ្លួនឯង?

សែមៈ ពេលខ្លះខ្ញុំយកឡានទៅខ្លួនឯង តែលើកនេះខ្ញុំអត់បានយកទៅទេ!

ដានីៈ ចុះពូសព្វថ្ងៃពូមានដែលឮអំពីតុលាការដែលគេបង្កើតសម្រាប់កាត់ទោសទេ?

សែមៈ កាត់ទោសហ្នឹងមែន?

ដានីៈ បាទពូមានដែលឮទេ?

សែមៈ ឮដែរ តាមមើលរហូតដែរហ្នឹង!

ដានីៈ ពូតាមមើលរហូតដែរ!

សែមៈ ពេលខ្លះខ្ញុំមើលហើយពេលខ្ញុំខានដែរហ្នឹង!

ដានី: ចុះពូយល់យ៉ាងម៉េចដែរតុលាការដែលគេកាត់ទោសហ្នឹង?

សែម: តុលាការកាត់ទោសហ្នឹងខ្ញុំមិនថាអីទេអ្នកកាត់ហ្នឹង ក៏ប៉ុន្តែគ្រាន់ថាចេះយើងវាធ្វើបាបតែអ្នកទន់ខ្សោយនិយាយមួយម៉ាត់ទៅ!

ដានី: បាទ!

សែម: ហើយអ្នកដែលមានធ្វើបាបតែអ្នកក្រ!

ដានី: បានន័យថាយើងអត់មានកម្លាំងផ្ទាល់ដៃអីទេ?

សែម: ហ្នឹងអើយអាហ្នឹងខ្ញុំនិយាយមួយម៉ាត់ខ្លីអញ្ចឹងចុះ!

ដានី: បាទ!

សែម: វាដូចតែក្មេងវៃរន្ទាលថ្ងៃអញ្ចឹង! ប្រៀបទៅខ្ញុំថាក្មេងវៃរន្ទាលថ្ងៃហ្នឹងកូនអ្នកធំហ្នឹងវាមានលុយហើយឲ្យអាមួយប៉ុនវៃហ្នឹងឲ្យលុយវាទៅហើយប្រាប់ឲ្យផឹកស៊ីទៅហើយទៅវៃអានោះមួយទៅខ្ញុំប្រៀបទៅអញ្ចឹងវិញ! ខ្ញុំមានប្រកាន់ទេព្រោះខ្មែរដូចគ្នាគ្មានអ្នកណាចង់សម្លាប់ខ្មែរដូចគ្នាតែគ្រាន់បានថាខ្មែរគ្នាយើងច្រើនតែអញ្ចឹង ដល់ពេលគេធ្វើបាបខ្លួនទៅបានខឹងគេ ដល់ពេលខឹងគេហ្នឹងទៅវៃគេឈ្នះវិញទៅបានចាញ់បោកគេទៀតទៅ អញ្ចឹងបានមួយជីវិតរបស់ខ្ញុំមើលៗដូចជាអយុត្តិធម៌ណាស់ ហើយចំពោះអ្នកដែលខឹងគាត់ចេះតែខឹងទៅព្រោះតែប៉ះសាច់យើងៗឈឺហើយ ប៉ុន្តែដូចតាឌុចបើគាត់មិនធ្វើគេសម្លាប់គាត់ដដែល ។

ដានី: កាលជិនាន់បីឆ្នាំពូជឿថាមានការសម្លាប់ដែលគេនិយាយថាជិតពីរលាន?

សែម: ខ្ញុំមិនបដិសេដទេអីដែលគេធ្វើនោះពេលដែលគេធ្វើគេថាគេត្រូវ ហើយអ៊ីដែលថាគេអ្នកមិនធ្វើនោះហើយត្រូវទទួលទារុណកម្មនោះ បើគេថាគេទៅកើតហើយយើងទៅកើតនឹងគេទៅវាមិនអីទេដូចខ្ញុំនិយាយខាងដើមអញ្ចឹង ដូចគេឲ្យធ្វើការធ្វើទៅម៉ោងប៉ុន្មានឈប់ៗនឹងគេទៅ ប៉ុន្តែចិត្តមនុស្សយើងម្នាក់ៗវាគិតខុសគ្នា ខ្ញុំនិយាយចង់បកស្រាយបន្តិចកាលនោះការតស៊ូវៃចក្រព័ទ្ធអាមេរិចមូលធន វៃកាលនោះគឺវៃសម្លាប់តែបងប្អូនឯងអ្នកមានដែលមូលធន ដែលជាអ្នកដែលមានជិះជាន់ដល់អ្នកក្រីក្រ អញ្ចឹងបានថាអស់លោកអើយដែលក្លាយជាអ្នកមានសព្វថ្ងៃកុំសូវមើលងាយគេអ្នកក្រពេក ព្រោះថាបើមិនឲ្យគ្នាស៊ីកុំថាកុំឌៀលឲ្យគ្នាដើរហួសក៏ហួសទៅអាហ្នឹងជាការឈឺចាប់កន្ទងម៉ោ វាវណ្ណៈ ដល់វាផ្អែកចូលអាកន្លែងវណ្ណៈហើយមានអ្នកជួយពីក្រោយម៉ោទៀតទៅវាកាន់តែខ្លាំងឡើង អាហ្នឹងហើយបានវាកើតបញ្ហា ហើយដល់កើតបញ្ហាអាខ្លួនធ្លាប់ជិះឡាន ធ្លាប់ផឹកកាហ្វេឲ្យអត់ហ្នឹងម៉េចព្រម!

ដានី: បាទ! តវ៉ា?

សែមៈ	តវ៉ាដល់តវ៉ាគេថាឯងអត់ក៏គេអត់បានដឹកអត់បានស៊ីអត់បានឡានជិះដូចឯង! គេដើរៗនឹងគេទៅ ហើយថាម៉េចនឹងសុខចិត្តឈឺជើងចង់ងាប់ មនុស្សមានឡានជិះស្បែកជើងស្អីងហ្នឹង ដល់អញ្ចឹងដើរឈឺជើងដល់ឈឺជើងនឹង ដល់ពេលនឹងអត់ធ្វើ អារឿងហ្នឹងវាទាក់ទងច្រើនណាស់ បើយើងនិយាយទៅ អញ្ចឹងបានថាខ្ញុំអ្នករងគ្រោះដូចជាធ្វើទារុណកម្មហ្នឹងក៏ខ្ញុំមិនថា ព្រោះអីទាខុចបើគាត់មិនធ្វើតាមគេក៏ងាប់ដែរនិយាយតែមួយម៉ាត់អញ្ចឹងទៅ ហើយខ្ញុំមិនដឹងថាយកអ្នកណាខុសអ្នកណាត្រូវទេខ្ញុំមើលទៅ!

ដានីៈ	ចុះដូចជាគាត់អ្នកដឹកនាំប្រទេសដូចជានួនជា អៀង សារី, ខៀវ សំផនហើយប្រពន្ធគាត់ អៀង ធារិទ្ធអីចឹងពួយល់ថាត្រឹមត្រូវដែរឬក៏អត់?

សែមៈ	យល់ឃើញយ៉ាងម៉េច?

ដានីៈ	ដូចថាតុលាការគេចាប់គាត់ទៅដើម្បីកាត់ទោសត្រឹមត្រូវដែរឬទេ?

សែមៈ	អារឿងហ្នឹងទៅតាមអ្នកដែលចេះដឹងទៅ អ្នកដែលចេះដឹងគាត់ធ្វើម៉េចក៏ធ្វើទៅ ព្រោះពួកទាំងអស់ហ្នឹងសុទ្ធតែអ្នកចេះដឹង!

ដានីៈ	បាទ!

សែមៈ	មិនមែនអ្នកល្ងង់ទេ!

ដានីៈ	បាទ!

សែមៈ	បើអ្នកក្រោមៗខ្ញុំជឿថាអ្នកល្ងង់ ហើយដូចជួគាត់នេះគាត់ដឹកនាំប្រទេសអញ្ចេះគឺសុទ្ធតែអ្នកចេះ អញ្ចឹងបានថាគេអ្នកចេះហើយ ហើយយើងអ្នកល្ងង់មិនអាចវិភាគពីគាត់បានទេ!

ដានីៈ	បាទ!

សែមៈ	ហើយគ្រាន់តែយល់ថាយើងអនុវត្តខុសហើយគេយកទៅនិយាយអីជារឿងការអីមួយដែលមានប្រវត្តកន្លងម៉ោធ្វើបាប់ប្រជាជនឯងអាហ្នឹងវាតាមអតីតកាលរបស់គាត់ទៅ ព្រោះអីគាត់អនុវត្តម៉ោគាត់វាមិនសមទេ ដូចថាយើងនៅក្នុងផ្ទះមួយដូចកូនខ្ញុំ៩នាក់ ហើយកូនខ្ញុំអាមួយនៅអាមួយនៅនោះ ចុះបើវាទៅវិលទៅខូចឬវាទៅណាទៅណីយើងម៉េចដឹង តែឲ្យតែមានញាតិសណ្តានជិតខាង តែឯងអ្នកដឹកនាំប្រទេសមានដែរដូចថាគាត់ទន់ខ្សោយត្រង់ថាឲ្យមនុស្សទៅធ្វើការមនុស្សហ្នឹងមិនស្មោះនឹងគាត់ មិនមែនគាត់ចង់សម្លាប់ប្រជាជនឯងទេ មែនតើខ្ញុំថាអ្នកដឹកនាំខ្មែរណាមួយចង់សម្លាប់ខ្មែរទេ ប៉ុន្តែនិយាយទៅវាពិបាកនិយាយណាស់ និយាយវាមិនកើតចាំប្រវត្តសាស្ត្រនឹងវិនិច្ឆ័យចុះ ដូចខៀវ សំផនគាត់ថាទឹកថ្លាមិនមើលឃើញត្រីណា៎

ទឹកល្អក់មើលមិនឃើញទេ     អាហ្នឹងបានគុលាការធ្វើម៉េចក៏ធ្វើទៅខាងបរទេសលោកមានលុយច្រើនចេះតែឲ្យបងប្អូនធ្វើកាត់ទោសស្រេចតែគាត់អ្នកចេះដឹងទេ ។

ដានីៈ     បាទសូមអរគុណ!

«ចប់»